ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

# សៀវភៅគោលការណ៍ណែនាំស្ដីពី កិច្ចការពារផ្លូវច្បាប់សម្រាប់សិទ្ធិស្ត្រី និងកុមារ នៅកម្ពុជា

ឆ្នាំ ២០១៦

បោះពុម្ពលើកទីពីរ

ឧបត្ថម្ភ ដោយ៖

Australian Aid

អនុវត្តដោយ៖

giz

@ រក្សាសិទ្ធិដោយ ក្រសួងកិច្ចការនារីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៦

សៀវភៅណែនាំ ដែលបានបោះពុម្ពផ្សាយនេះ ត្រូវបានរៀបរៀងឡើង ជាផ្នែកមួយនៃគម្រោងលទ្ធភាពទទួលបានយុត្តិធម៌ សម្រាប់ស្ត្រី ដែលបានអនុវត្តរួមគ្នាដោយក្រសួងកិច្ចការនារីនៃព្រះរាជាណាចក្រកម្ពុជា និងសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ក្រោមការជួយឧបត្ថម្ភថវិកាពីក្រសួងអភិវឌ្ឍ និងសហប្រតិបត្តិការសេដ្ឋកិច្ចនៃសាធារណរដ្ឋ សហព័ន្ធអាល្លឺម៉ង់ (BMZ) និងនៅក្នុងរយៈពេលរវាង ឆ្នាំ ២០១០ និងឆ្នាំ ២០១៣ ក្រោមការសហការផ្តល់ថវិកាពីទីភ្នាក់ងារអេស្ប៉ាញ សម្រាប់សហប្រតិបត្តិការ និងអភិវឌ្ឍអន្តរជាតិ (AECID) និងបោះពុម្ពលើកទី២ ក្រោមជំនួយក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT)។

# មាតិកា

**ពាក្យកាត់** ........ **៥**

**អារម្ភកថា** ........ **៦**

**សេចក្តីផ្តើម** ........ **៨**

**ជំពូកទី ១** - សិទ្ធិស្ត្រី ........ ៩

**ជំពូកទី ២** - មន្ត្រីសំខាន់ៗ ........ ១៦

**ជំពូកទី ៣** - ការណែនាំអំពីច្បាប់ព្រហ្មទណ្ឌ ........ ២៨

**ជំពូកទី ៤** - នីតិវិធីព្រហ្មទណ្ឌ ........ ៣៦

**ជំពូកទី ៥** - បណ្តឹងរដ្ឋប្បវេណី នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ........ ៧៤

**ជំពូកទី ៦** - អំពើហិង្សាក្នុងគ្រួសារ ........ ៧៧

**ជំពូកទី ៧** - ដីកាការពារ ........ ៨៣

**ជំពូកទី ៨** - អាពាហ៍ពិពាហ៍ និងការលែងលះគ្នា ........ ៨៧

## ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី ១** - ឯកសារយោង ............ ១០១

**ឧបសម្ព័ន្ធទី ២** - រចនាសម្ព័ន្ធរបស់តុលាការ ............ ១០៣

**ឧបសម្ព័ន្ធទី ៣** - ឋានានុក្រមច្បាប់ ............ ១០៤

**ឧបសម្ព័ន្ធទី ៤** - តារាងលំហូរនៃនីតិវិធីព្រហ្មទណ្ឌ (ករណីមិនជាក់ស្តែង) ............ ១០៥

**ឧបសម្ព័ន្ធទី ៥** - តារាងលំហូរនៃនីតិវិធីព្រហ្មទណ្ឌ (ករណីជាក់ស្តែង) ............ ១០៦

**ឧបសម្ព័ន្ធទី ៦** - លិខិតបញ្ជាក់ពីគ្រូពេទ្យ ............ ១០៧

**ឧបសម្ព័ន្ធទី ៧** - ពាក្យស្នើសុំដីកាការពារ ............ ១១៥

**ឧបសម្ព័ន្ធទី ៨** - ទម្រង់ពាក្យបណ្តឹងរបស់ជនរងគ្រោះ ............ ១១៧

**ឧបសម្ព័ន្ធទី ៩** - ទម្រង់លិខិតអន្តរាគមន៍របស់លោកជំទាវរដ្ឋមន្ត្រី ............ ១២១

# ពាក្យកាត់

| | |
|---|---|
| CPC | ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ |
| DV Law | ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ |
| JPO | មន្ត្រីនគរបាលយុត្តិធម៌ |
| JPO-MoWA | មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី |
| MoWA | ក្រសួងកិច្ចការនារី |
| Pro Deo | ដោយឥតគិតថ្លៃ ( ពាក្យឡាតាំង ) |

សូមអនុវត្ត ចំពោះសញ្ញានេះ √

សូមយកចិត្តទុកដាក់ ចំពោះសញ្ញានេះ !

សូមកុំអនុវត្ត ចំពោះសញ្ញានេះ ✕

ការប្រើពាក្យថាមន្ត្រីនគរបាលយុត្តិធម៌កិច្ចការនារីនៅក្នុងសៀវភៅនេះ គឺយោងលើច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ ប៉ុន្តែជាក់ស្តែងយើងហៅថា ភ្នាក់ងារនគរបាលយុត្តិធម៌កិច្ចការនារី។

# អារម្ភកថា

*សៀវភៅគោលការណ៍ណែនាំស្តីពីកិច្ចការពារផ្លូវច្បាប់ សម្រាប់សិទ្ធិស្ត្រី និងកុមារ នៅកម្ពុជា* នេះ គឺជាឯកសារដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០១៤។ សៀវភៅគោលការណ៍ណែនាំនេះមានគោលបំណងធ្វើឱ្យការឆ្លើយតបរបស់ស្ថាប័នរដ្ឋ និងមិនមែនស្ថាប័នរដ្ឋកាន់តែមានភាពល្អប្រសើរជាងមុន នៅក្នុងករណីដែលមានអំពើហិង្សាលើស្ត្រី និងកុមារកើតឡើង ជាពិសេស ការឆ្លើយតបផ្លូវច្បាប់។

ប្រទេសកម្ពុជាមានក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាតិ ដែលមានលក្ខណៈល្អប្រសើរ ដើម្បីឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី ដូចជា ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (២០០៥) ក្រមនីតិវិធីព្រហ្មទណ្ឌ (២០០៧) ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ(២០០៨) ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ (២០១៤-២០១៨) និងផែនការយុទ្ធសាស្ត្រជាតិស្តីពីសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី (២០១៤-២០១៨) ទី ៣ ដែលហៅថា នារីរតនៈ ៤។

ទោះបីជាមានច្បាប់ និងគោលនយោបាយទាំងនេះក៏ដោយ ក៏អំពើហិង្សាលើស្ត្រីនៅតែជាបញ្ហាមួយ ក្នុងសង្គមកម្ពុជា ដោយសារតែទំនាក់ទំនងអំណាចមិនស្មើគ្នាកន្លងមក រវាងបុរស និងស្ត្រី និងដោយសារតែមានការបន្តការរើសអើងលើស្ត្រី ទាំងនៅទីសាធារណៈ និងឯកជន។ បើតាមការអង្កេតថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រី (២០១៥) ធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដោយប្រើប្រាស់វិធីសាស្ត្ររបស់ WHO ដែលមានការគាំទ្រហិរញ្ញវត្ថុពីក្រសួងការបរទេស និងពាណិជ្ជកម្មរបស់អូស្ត្រាលី (DFAT) បានរកឃើញថាក្នុងចំណោមស្ត្រីអាយុ ១៥ ដល់ ៦៤ ឆ្នាំ ៥ នាក់ ដែលធ្លាប់មានទំនាក់ទំនងពួកគេមាន១នាក់បានរាយការណ៍ថា ធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ និង/ផ្លូវភេទ ពីដៃគូស្នេហាណាម្នាក់ ក្នុងមួយជីវិតរបស់ពួកគេ។ ការអង្កេតនេះក៏បានរកឃើញផងដែរថា ក្នុងចំណោមស្ត្រីខ្មែរ ៤ នាក់ ដែលធ្លាប់ទទួលរងអំពីហិង្សាផ្លូវកាយ និង/ឬផ្លូវភេទពីដៃគូរបស់ខ្លួន មាន ៣ នាក់ ធ្លាប់ទទួលរងអំពើធ្ងន់ធ្ងរ ពោលគឺមិនមែនត្រឹមតែទង្វើហិង្សាតិចតួចនោះទេ។

*សៀវភៅគោលការណ៍ណែនាំស្តីពីកិច្ចការពារផ្លូវច្បាប់សម្រាប់សិទ្ធិស្ត្រី និងកុមារ នៅកម្ពុជា* នេះ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែង ក្រោមការដឹកនាំរបស់ក្រសួងកិច្ចការនារីនៃប្រទេសកម្ពុជា និងដៃគូរបស់យើង ក្នុងការធ្វើឱ្យការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី និងកុមារមានលក្ខណៈស្តង់ដា ដើម្បីបំពេញទៅតាមតម្រូវការរបស់ស្ត្រី និងកុមារឱ្យកាន់តែមានប្រសិទ្ធភាព ជម្រុញឱ្យ

អ្នកផ្តល់សេវាអនុវត្តការងារឱ្យបានត្រឹមត្រូវ និងប្រកបដោយវិជ្ជាជីវៈ ក៏ដូចជាកំណត់ការឆ្លើយតបរបស់អ្នកផ្តល់សេវា ឱ្យស្របតាមច្បាប់ជាតិ ក៏ដូចជាច្បាប់អន្តរជាតិ និងស្តង់ដានានា។ គោលការណ៍ណែនាំក៏ត្រូវបានបំពេញបន្ថែមដោយគោលការណ៍ណែនាំផ្សេងទៀត ដែលត្រូវបានអនុម័តដោយក្រសួងកិច្ចការនារី ដូចជា បទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រី និងក្មេងស្រីជាជនរងគ្រោះដោយអំពើហិង្សា និងគោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

ខ្ញុំសង្ឃឹមជឿជាក់យ៉ាងមុតមាំថា *សៀវភៅគោលការណ៍ណែនាំស្តីពីកិច្ចការពារផ្លូវច្បាប់ដល់សិទ្ធិរបស់ស្ត្រី និងកុមារ នៅកម្ពុជា ដែលបោះពុម្ពលើកទី២* នេះ ជាឯកសារដ៏មានប្រយោជន៍ដើម្បីជួយមន្ត្រីអនុវត្តច្បាប់ និងភ្នាក់ងារសង្គមកិច្ច ក្នុងការផ្តល់ជំនួយយ៉ាងមានប្រសិទ្ធភាពដល់ស្ត្រី និងកុមារ ដែលរងគ្រោះដោយសារអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ។ គោលការណ៍ណែនាំនេះ នឹងរួមចំណែកកសាងសង្គមកម្ពុជាឱ្យកាន់តែមានយុត្តិធម៌ និងសុខុដុមរមនាបន្ថែមទៀតផងដែរ។

ចុងក្រោយ ខ្ញុំសូមថ្លែងនូវសេចក្តីអំណរគុណជាថ្មីម្តងទៀត ដល់ GIZ ដែលបានផ្តល់ជំនួយបច្ចេកទេស និងថវិកា សម្រាប់ការរៀបចំបោះពុម្ពលើកទី២ គោលការណ៍ណែនាំនេះ ក៏ដូចជារដ្ឋាភិបាលអាល្លឺម៉ង់ អូស្ត្រាលី និងអេស្ប៉ាញ ដែលបានផ្តល់ការគាំទ្រហិរញ្ញវត្ថុ។

រាជធានីភ្នំពេញថ្ងៃទី ០១ ខែ [illegible] ឆ្នាំ២០១៦

ជ. រដ្ឋមន្ត្រី

អនុរដ្ឋលេខាធិការ

ឆែស ច័ន្ទសារឿន

# សេចក្តីផ្តើម

សៀវភៅគោលការណ៍ណែនាំស្តីពីកិច្ចការពារផ្លូវច្បាប់ សម្រាប់សិទ្ធិស្ត្រី និងកុមារ នៅកម្ពុជានេះ (ក្រសួងកិច្ចការនារីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៤) គឺជាឯកសារសម្រាប់ភ្នាក់ងារនគរបាល យុត្តិធម៌ ប្រើប្រាស់ក្នុងការបណ្តុះបណ្តាល ដល់សិក្ខាកាម ដែលជាភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី ឬធ្វើជាសេចក្តីណែនាំដល់ភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី ឬមន្ត្រីរាជការស៊ីវិល ឬអ្នកផ្តល់សេវាដទៃទៀត ដែលធ្វើការងារដើម្បីការពារសិទ្ធិស្ត្រី និងសិទ្ធិកុមារ និងជាពិសេសរឿងក្តីអំពើហិង្សាលើស្ត្រីនៅក្នុងប្រទេសកម្ពុជា។

សៀវភៅណែនាំនេះ បានរៀបរាប់អំពីសិទ្ធិរបស់ជនរងគ្រោះ និងវិធីល្អៗ ដែលអ្នកផ្តល់សេវាទាំងឡាយអាចជួយជនរងគ្រោះឱ្យទទួលបានយុត្តិធម៌។ ជាពិសេស សៀវភៅណែនាំនេះ គឺជាឧបករណ៍មួយដ៏មានតម្លៃ ដែលជួយឱ្យភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី បានយល់ដឹងកាន់តែប្រសើរឡើងអំពីប្រព័ន្ធច្បាប់ និងធ្វើឱ្យពួកគេមានលទ្ធភាព នៅក្នុងការតាមដានឱ្យបានត្រឹមត្រូវនូវរឿងក្តីអំពើហិង្សាលើស្ត្រី។

សៀវភៅគោលការណ៍ណែនាំស្តីពីកិច្ចការពារផ្លូវច្បាប់ សម្រាប់សិទ្ធិស្ត្រី និងកុមារ នៅកម្ពុជានេះ ត្រូវបានរៀបរៀងឡើងដោយផ្អែកទៅលើវគ្គបណ្តុះបណ្តាលចំនួន ៩ វគ្គ ដែលបានរៀបចំឡើងដោយក្រុមមេធាវី និងអ្នកសម្របសម្រួលវគ្គ ដែលបានផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្គោលចំនួន ១១ រូប ដែលជាភ្នាក់ងារនគរបាល យុត្តិធម៌នៃក្រសួងកិច្ចការនារី ដើម្បីឱ្យពួកគេមានលទ្ធភាពបើកវគ្គបណ្តុះបណ្តាលបន្ត ដល់ភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារីទាំងអស់ដោយខ្លួនឯង។ ការបណ្តុះបណ្តាលគ្រូបង្គោលចំនួន ១១ រូបត្រូវបានរៀបចំធ្វើឡើងចាប់ពីខែធ្នូ ឆ្នាំ ២០១២ ដល់ខែតុលា ឆ្នាំ ២០១៣ នៅក្នុងក្របខ័ណ្ឌនៃគម្រោងលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រី ដែលបានអនុវត្តដោយក្រសួងកិច្ចការនារីនៃព្រះរាជាណាចក្រកម្ពុជា និងសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ក្រោមការជួយឧបត្ថម្ភថវិកាពីក្រសួងអភិវឌ្ឍ និងសហប្រតិបត្តិការសេដ្ឋកិច្ចនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (BMZ) និងទីភ្នាក់ងារអេស្ប៉ាញ សម្រាប់សហប្រតិបត្តិការ និងអភិវឌ្ឍអន្តរជាតិ (AECID)។

សៀវភៅគោលការណ៍ណែនាំស្តីពីកិច្ចការពារផ្លូវច្បាប់ សម្រាប់សិទ្ធិស្ត្រី និងកុមារ នៅកម្ពុជានេះ ត្រូវបានរៀបចំចងក្រងដោយ លោក ឃ្លោក តារា ទីប្រឹក្សាច្បាប់ និង លោកស្រី Dorine van der Keur ដែលជាមេធាវី និងមានការត្រួតពិនិត្យ និងកែសម្រួលដោយក្រុមការងារភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី។

# ជំពូកទី ១ - សិទ្ធិស្ត្រី

## សេចក្តីផ្តើម

ជាញឹកញាប់ នៅក្នុងប្រទេសកម្ពុជា សិទ្ធិស្ត្រីបានទទួលរងការរំលោភបំពាន ហើយកិច្ចការពារសិទ្ធិរបស់ពួកគេ នៅមិនទាន់មានភាពល្អប្រសើរនៅឡើយ។ អំណាចនៅក្នុងតួនាទីផ្នែកយេនឌ័រខុសគ្នា ត្រូវបានគេបែងចែកដោយមិនស្មើគ្នាឡើយ ពោលគឺស្ត្រីមានអំណាចតិចតួច ឧទាហរណ៍ នៅទីកន្លែងធ្វើការជាដើម។ ស្ត្រី កម្រនឹងទទួលបានការកាន់កាប់មុខងារជាន់ខ្ពស់ នៅក្នុងក្រុមហ៊ុននានា និងស្ថាប័នទាំងឡាយរបស់រដ្ឋាភិបាលណាស់។ ជាទូទៅមានការគោរពសិទ្ធិស្ត្រីតិចតួច ហើយទាំងបុរស និងស្ត្រីនៅក្នុងប្រទេសកម្ពុជា មានជំនឿថា បុរសមានសិទ្ធិដើម្បីរំលោភបំពានទៅលើសិទ្ធិរបស់ស្ត្រី។ មានការរំលោភបំពានទៅលើសិទ្ធិស្ត្រី និងកុមារ ជាច្រើនប្រភេទខុសៗគ្នា ប៉ុន្តែ ការរំលោភបំពាន ដែលគួរឱ្យស្អប់ខ្ពើមជាងគេបំផុតនោះ គឺ អំពើហិង្សាលើស្ត្រី ដែលកើតឡើងជាញឹកញាប់ជាងគេនៅក្នុងប្រទេសកម្ពុជា រួមមាន៖

- អំពើហិង្សាក្នុងគ្រួសារ
- អំពើរំលោភសេពសន្ថវៈ
- អំពើជួញដូរមនុស្ស - អំពើធ្វើអាជីវកម្មផ្លូវភេទ និងអំពើធ្វើអាជីវកម្មកម្លាំងពលកម្ម
- អំពើបៀតបៀនផ្លូវភេទ នៅទីកន្លែងធ្វើការ។

កិច្ចការពារស្ត្រីពីការរំលោភបំពានទាំងអស់នេះ ទើបតែត្រូវបានទទួលការយកចិត្តទុកដាក់ នៅក្នុងរយៈពេល ១០ ឆ្នាំ កន្លងទៅនេះតែប៉ុណ្ណោះ នៅក្នុងពេលដែលរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ បានចាប់ផ្តើមពង្រឹងភាពអង់អាចក្លាហានដល់ស្ត្រី។

ប៉ុន្តែ ស្ត្រីដែលចង់ក្រោកឈរឡើង ដើម្បីទាមទារសិទ្ធិរបស់ពួកគេ ជាញឹកញាប់ ពួកគេជួបប្រទះការលំបាក នៅក្នុងការទទួលបានយុត្តិធម៌។ ប្រពន្ធ ដែលមានប្តីជាជនប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ត្រូវបានគេនិយាយប្រាប់ឱ្យបន្តរស់នៅជាមួយប្តីរបស់ខ្លួនតទៅទៀត ដោយសារតែការលែងលះគ្នា នៅមិនទាន់ត្រូវបានសង្គមទទួលយកនៅឡើយ នៅក្នុងវប្បធម៌របស់ប្រទេសកម្ពុជា។ ជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ កម្រនឹងបានឃើញសវនាការនៅក្នុងតុលាការណាស់។ ជាធម្មតា ជនល្មើសបានដោះស្រាយរឿងក្តី នៅក្រៅប្រព័ន្ធតុលាការ ដោយបង់ជាសំណងរដ្ឋប្បវេណី ហើយរឿងក្តីនោះត្រូវបានច្រានចោល ដោយមន្ត្រីនគរបាល និង

ព្រះរាជអាជ្ញាដោយខុសច្បាប់។ ករណី ដែលកាន់តែអាក្រក់ជាងនេះទៅទៀតនោះ គឺគ្រួសាររបស់ជនរងគ្រោះ ចង់ឱ្យជនរងគ្រោះរៀបការជាមួយជនល្មើស ដើម្បីស្តារកិត្តិយសរបស់នាងឡើងវិញ។

នាពេលបច្ចុប្បន្ននេះ ប្រព័ន្ធត្រួតពិនិត្យតាមដានមួយ ដែលកំពុងតែដំណើរការបង្កើតឡើង នៅឡើយនោះ នឹងផ្តល់នូវការឆ្លុះបញ្ចាំងមួយអំពីការរីករាលដាលនៃការរំលោភបំពានទាំងអស់នេះ នៅក្នុងប្រទេសកម្ពុជា។

ខាងក្រោមនេះ គឺជានិយមន័យមួយចំនួន ដែលទាក់ទងនឹងកិច្ចការពារសិទ្ធិស្ត្រី៖

យេនឌ័រ គឺជាការកំណត់ និងឱកាសក្នុងសង្គម ដែលពាក់ព័ន្ធជាមួយនឹងការធ្វើជាមនុស្សប្រុស និងមនុស្សស្រី និងទំនាក់ទំនងគ្នារវាងស្ត្រី និងបុរស និងរវាងក្មេងស្រី និងក្មេងប្រុស ក៏ដូចជា ទំនាក់ទំនងគ្នារវាងស្ត្រី និងស្ត្រី និងរវាងបុរស និងបុរសគ្នាឯង។ ការកំណត់ឱកាស និងទំនាក់ទំនងគ្នាទាំងនេះ ត្រូវបានបង្កើតឡើងនៅក្នុងសង្គម ហើយត្រូវបានគេចាប់រៀនសូត្រតាមរយៈដំណើរការនៃការធ្វើទំនាក់ទំនងគ្នានៅក្នុងសង្គម។ កត្តាទាំងនេះ មានភាពជាក់លាក់ទៅតាមបរិបទ/ពេលវេលា និងអាចផ្លាស់ប្តូរបាន។ យេនឌ័រ កំណត់អំពីអ្វីដែលគេរំពឹងថា នឹងមានអ្វីដែលអាចអនុញ្ញាតឱ្យធ្វើបាន និងអ្វីដែលគេផ្តល់តម្លៃឱ្យស្ត្រីម្នាក់ ឬបុរសម្នាក់នៅក្នុងបរិបទណាមួយ។ នៅក្នុងសង្គមភាគច្រើន បុរស និងស្ត្រី មានភាពខុសប្លែកពីគ្នា ហើយមិនមានសមភាពរវាងគ្នានឹងគ្នាឡើយ នៅក្នុងការទទួលខុសត្រូវ ដែលបានកំណត់សកម្មភាព ដែលពួកគេត្រូវធ្វើ លទ្ធភាព ទទួលបានធនធាន និងការកាន់កាប់ធនធានទាំងនោះ ក៏ដូចជាឱកាសនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

យេនឌ័រ គឺជាផ្នែកមួយនៃបរិបទសង្គម-វប្បធម៌ដ៏ទូលំទូលាយ។ លក្ខណៈវិនិច្ឆ័យសំខាន់ៗផ្សេងទៀត សម្រាប់ការវិភាគសង្គម-វប្បធម៌ រួមមាន វណ្ណៈ ពូជសាសន៍ កម្រិតនៃភាពក្រីក្រ ក្រុមជាតិពន្ធ និងអាយុ។[1]

---

1 និយមន័យរបស់អង្គការសហប្រជាជាតិ ដែលបានដកស្រង់ចេញពីគេហទំព័រខាងក្រោម៖ http://www.un.org/womenwatch/osagi/conceptsandefinitions.htm

អំពើហិង្សាទាក់ទងនឹងយេនឌ័រ សំដៅលើអំពើហិង្សា ដែលធ្វើឡើងចំពោះមនុស្សណាម្នាក់ ដោយសារតែយេនឌ័រ ឬភេទរបស់មនុស្សម្នាក់នោះ។ អំពើហិង្សាប្រភេទនេះ រួមមានទង្វើ ដែលនាំឱ្យមានគ្រោះថ្នាក់ ឬការឈឺចាប់ផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទ ការគំរាមកំហែងថានឹងប្រព្រឹត្តទង្វើបែបនេះ ការបង្ខិតបង្ខំ និងការដកហូតសេរីភាពផ្សេងទៀត។ ខណៈពេលដែលស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រី អាចជាជនរងគ្រោះដោយសារតែអំពើហិង្សាទាក់ទងនឹងយេនឌ័រ ស្ត្រី និងក្មេងស្រីគឺជាជនរងគ្រោះច្រើនជាងគេបំផុត។[2]

អំពើហិង្សាលើស្ត្រី គឺជាអំពើណាមួយនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបណ្ដាលឱ្យ ឬទំនងជានាំឱ្យមានគ្រោះថ្នាក់ ឬការឈឺចាប់ផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទ ដល់ស្ត្រីរាប់បញ្ចូលទាំងការគំរាមកំហែងថានឹងប្រព្រឹត្តទង្វើទាំងនេះ ការបង្ខិតបង្ខំ ឬការដកហូតសេរីភាពតាមតែទំនើងចិត្ត មិនថាកើតឡើងនៅទីសាធារណៈ ឬក្នុងជីវិតឯកជននោះឡើយ។[3]

## ក្របខ័ណ្ឌច្បាប់ ដើម្បីផ្តល់កិច្ចការពារដល់ស្ត្រី

### រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា ៣១ បានចែងថា ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នា ចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ មាត្រា ៣៥ បានចែងថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្ម ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។ មាត្រា ៣៦ បានចែងបន្ថែមទៀតថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។ ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃ ដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ។ មាត្រា ៤៥ បានចែងថា ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រី ត្រូវបំបាត់ចោល។ ការធ្វើអាជីវកម្ម លើការងាររបស់ស្ត្រី ត្រូវហាមឃាត់។ បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។

---

2 ផ្អែកតាមមាត្រា ១ និងមាត្រា ២ នៃសេចក្តីប្រកាសរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី (ឆ្នាំ ១៩៩៣) និងអនុសាសន៍ទី ១៩ កថាខណ្ឌទី ៦ នៃសម័យប្រជុំលើកទី ១១ នៃគណៈកម្មាធិការ CEDAW

3 និយមន័យរបស់អង្គការសហប្រជាជាតិ ដែលបានដកស្រង់ចេញពីគេហទំព័រខាងក្រោម៖ http://www.who.int/reproductivehealth/topics/violence/vaw_series/en/index.html

## សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស

មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ បានបញ្ចូលដោយផ្ទាល់នូវលិខិតុបករណ៍អន្តរជាតិមួយចំនួនស្តីពីសិទ្ធិមនុស្ស ទៅក្នុងច្បាប់របស់ប្រទេសកម្ពុជា ដើម្បីធានាឱ្យមានកិច្ចការពារសិទ្ធិមនុស្ស ដែលរួមមានសិទ្ធិជាមូលដ្ឋាន ជាអាទិ៍ សិទ្ធិរស់រានមានជីវិត សិទ្ធិរបស់បុគ្គលម្នាក់ៗ សន្តិសុខផ្ទាល់ខ្លួន និងសេរីភាពនៅក្នុងការធ្វើដំណើរ ការមានជំនឿ និងសាសនា សិទ្ធិបង្កើតសហគមន៍ និងគណបក្សនយោបាយ សិទ្ធិទទួលបានការកាត់ក្តីដ៏ត្រឹមត្រូវនៅក្នុងតុលាការ និងសមភាពចំពោះមុខច្បាប់។

ប្រទេសកម្ពុជា បានចុះហត្ថលេខា និងផ្តល់សច្ចាប័នដល់សន្ធិសញ្ញាអន្តរជាតិជាច្រើន។ សន្ធិសញ្ញាអន្តរជាតិមួយចំនួន ក៏បានធានានូវកិច្ចការពារសិទ្ធិរបស់ស្ត្រីផងដែរ។ ភាគីរដ្ឋត្រូវមានភារកិច្ចអនុវត្ត ធានា ការពារ និងគោរពសិទ្ធិមនុស្សជាសកល ដូចជា៖

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ *(ដែលប្រទេសកម្ពុជា បានផ្តល់សច្ចាប័ន នៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ១៩៩២)*៖ មាត្រា ១ បានចែងថា មនុស្សគ្រប់រូបមានសិទ្ធិធ្វើការសម្រេចចិត្តដោយខ្លួនឯង។ តាមរយៈសិទ្ធិនេះ ពួកគេអាចធ្វើការកំណត់ពីនិន្នាការនយោបាយរបស់ពួកគេ ដោយសេរី និងមានសេរីភាពក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ពួកគេ។ មាត្រា ២ ចំណុចទី ២ បានចែងថា រដ្ឋភាគីត្រូវធ្វើការធានាថា សិទ្ធិទាំងនេះនឹងត្រូវអនុវត្ត ដោយមិនមានការរើសអើង ចំពោះពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា គំនិតនយោបាយអ្វីឡើយ។ មាត្រា ៣ បានចែងថា រដ្ឋភាគីត្រូវធានាឱ្យបុរស និងស្ត្រីទទួលបានសិទ្ធិស្មើគ្នា ក្នុងការប្រតិបត្តិគ្រប់សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ទាំងអស់។ មាត្រា ៦ បានចែងថា រដ្ឋភាគីទទួលស្គាល់សិទ្ធិធ្វើការងារ សិទ្ធិជ្រើសរើសការងារដោយសេរី។ មាត្រា ៧ បានចែងថា រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់មនុស្សគ្រប់គ្នា ក្នុងការទទួលបានលក្ខខណ្ឌការងារប្រកបដោយភាពយុត្តិធម៌ និងអំណោយផល ប្រាក់កម្រៃស្មើគ្នាសម្រាប់ការងារដូចគ្នា។

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងនយោបាយ *(ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន នៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ១៩៩២)*៖ មាត្រា ១, ២, ៣, ៤, ១៤, ២២ និងមាត្រា ២៦ បានធានាផ្តល់កិច្ចការពារដល់សិទ្ធិរបស់បុគ្គលគ្រប់រូប និងធានានូវសិទ្ធិស្មើគ្នា។

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស *(ដែលមានសុពលភាពចំពោះប្រទេសទាំងអស់ដែលជាសមាជិករបស់អង្គការសហប្រជាជាតិ)*៖ មាត្រា ១, ២, ៧, ១៦, ២៣ និងមាត្រា ២៦ បានចែងអំពីការទទួលស្គាល់កិច្ចការពារសិទ្ធិមនុស្ស។

អនុសញ្ញាស្តីពីការបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (CEDAW) *(ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន នៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩២)*៖ ក្នុងចំណោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិជាច្រើន មានតែអនុសញ្ញា CEDAW នេះតែប៉ុណ្ណោះ ដែលបានផ្តោតយ៉ាងជាក់លាក់ទៅលើកិច្ចការពារសិទ្ធិស្ត្រី។ អនុសញ្ញានេះទាមទារឱ្យរដ្ឋភាគី ពង្រឹងការអនុវត្តសិទ្ធិស្ត្រីឱ្យបានទៀងទាត់ និងធ្វើការថ្កោលទោសរាល់ទម្រង់ទាំងអស់នៃការរើសអើងលើស្ត្រី ក៏ដូចជាអនុវត្តរាល់វិធានការសមស្របទាំងអស់។ ប្រទេស ដែលជាភាគីនៃអនុសញ្ញានេះមានកាតព្វកិច្ចតាមផ្លូវច្បាប់ ដើម្បីអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ។ ប្រទេសទាំងនេះ ក៏ត្រូវប្តេជ្ញាផ្ញើរបាយការណ៍ជាតិរបស់ខ្លួន យ៉ាងហោចណាស់ជារៀងរាល់ ៤ ឆ្នាំម្តងអំពីវិធានការទាំងឡាយ ដែលខ្លួនបានអនុវត្ត ដើម្បីអនុលោមទៅតាមកាតព្វកិច្ចរបស់ខ្លួន ដែលមានចែងនៅក្នុងអនុសញ្ញានេះ។ មាត្រា ១ នៃអនុសញ្ញា CEDAW នេះ បានចែងថា ការរើសអើងលើស្ត្រីមានន័យថាជាការបែងចែក ការផាត់ចេញ ឬការរឹតត្បិត ដែលធ្វើឡើងដោយសារតែភេទ ហើយដែលមានផលប៉ះពាល់ ឬមានគោលបំណងធ្វើឱ្យខូច ឬលុបចោលការទទួលស្គាល់ ការទទួលបាន ឬការអនុវត្តសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ស្ត្រី នៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ ស៊ីវិល ឬវិស័យផ្សេងទៀត ដោយមិនគិតពីស្ថានភាពអាពាហ៍ពិពាហ៍របស់ពួកគេ ហើយឈរលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី។ មាត្រា ២ បានចែងថា រដ្ឋភាគី ថ្កោលទោសរាល់ទម្រង់ទាំងអស់នៃការរើសអើងលើស្ត្រី។ រដ្ឋភាគី ត្រូវដាក់បញ្ចូលគោលការណ៍សមភាពរវាងបុរស និងស្ត្រី ទៅក្នុងរដ្ឋធម្មនុញ្ញជាតិរបស់ខ្លួន ឬច្បាប់សមស្របផ្សេងៗទៀត។ មាត្រា ៣ បានចែងអំពីការធានាឱ្យមានការអភិវឌ្ឍន៍ និងការលើកកម្ពស់ស្ត្រីឱ្យបានពេញលេញ ក្នុងគោលបំណង ដើម្បីផ្តល់ការធានាឱ្យពួកគេអាចប្រតិបត្តិ និងទទួលបានសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដោយស្មើភាពគ្នាជាមួយបុរស។ មាត្រា ៤, ៥, ៦, ៧, ៨, ៩, ១០, ១១, ១៥ និងមាត្រា១៦៖ សិទ្ធិសមភាពក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ បានលើកឡើងអំពីកិច្ចការពារ និងការលើកកម្ពស់សិទ្ធិស្ត្រីឱ្យស្មើភាពគ្នាជាមួយបុរស។

ក្រៅពីច្បាប់ក្នុងស្រុក ដែលផ្តល់សិទ្ធិស្មើគ្នាដល់បុគ្គលទាំងអស់ នៅចំពោះមុខច្បាប់ និងកិច្ចការពារសិទ្ធិរបស់ស្ត្រី ដែលត្រូវទទួលរងការរំលោភបំពានដោយខុសច្បាប់នោះ អនុសញ្ញានេះ ក៏អាចយកទៅអនុវត្តដោយផ្ទាល់ផងដែរ ដើម្បីការពារសិទ្ធិស្ត្រីនៅក្នុងប្រទេសកម្ពុជា។

# ច្បាប់របស់ប្រទេសកម្ពុជា

## ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ និងក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាន នៅចុងឆ្នាំ ២០១០

រាល់ទម្រង់ទាំងអស់នៃអំពើហិង្សាលើស្ត្រី និងកុមារ អាចផ្តន្ទាទោសបាន នៅក្រោមក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០ ហើយរបៀបនៃការផ្តន្ទាទោសត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧។

ក្រៅពីនេះ នៅមានច្បាប់ជាក់លាក់ជាងនេះទៀតមួយចំនួន ដែលបានចែងអំពីទម្រង់យ៉ាងជាក់លាក់នៃអំពើហិង្សាលើស្ត្រី និងកុមារនេះ ដែលក្នុងនោះមាន៖

## ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥

ជាការឆ្លើយតបចំពោះការរំលោភបំពានលើស្ត្រី ប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ នៅក្នុងឆ្នាំ ២០០៥។ ច្បាប់នេះមានគោលបំណង ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងពង្រឹងវប្បធម៌អហិង្សា និងភាពសុខដុមរមនា នៅក្នុងក្រុមគ្រួសារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងមួយទៀត គឺដើម្បីផ្តល់ការជួយគាំទ្រជាបន្ទាន់ និងប្រកបដោយប្រសិទ្ធភាពដល់ជនរងគ្រោះ សូម្បីតែជនរងគ្រោះនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលក៏ដោយ។ ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះនេះ មានគោលបំណងដើម្បីបញ្ចៀសមិនឱ្យមានគ្រោះថ្នាក់កើតឡើង និងកាត់បន្ថយឱ្យបានជាអតិបរមានូវហានិភ័យនៃការរំលោភបំពានសិទ្ធិ ដោយអនុញ្ញាតឱ្យមានការចូលធ្វើអន្តរាគមន៍ មុនពេលមានការរំលោភបំពានសិទ្ធិណាមួយកើតឡើង។ មាត្រា ៣ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ បានចែងថា អំពើហិង្សាក្នុងគ្រួសារត្រូវតែទប់ស្កាត់ឱ្យមានប្រសិទ្ធភាព តាមរយៈនៃការចាត់ "*វិធានការសមស្របទាំងឡាយ ដើម្បីការពារជនរងគ្រោះ ឬជនអាចនឹងរងគ្រោះ*"។

## ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

ច្បាប់នេះត្រូវបានអនុម័ត នៅក្នុងឆ្នាំ ២០០៨ ដោយជំនួសឱ្យច្បាប់កាលពី ឆ្នាំ ១៩៩៦ ដែលជាទូទៅ ត្រូវបានគេចាត់ទុកថាមានលក្ខណៈសាមញ្ញខ្លាំងពេក។ ច្បាប់ថ្មីនេះ បានហាមឃាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរូបភាពផ្សេងៗ ដូចជា អំពើពេស្យាចាររូបភាព និងសម្ភារអាសអាភាស និងអំពើអាសជាដើម។

## ឋានានុក្រមនៃច្បាប់

ក្របខ័ណ្ឌច្បាប់ ដើម្បីការពារស្ត្រីពីអំពើហិង្សា រួមមានសន្ធិសញ្ញា ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។ ប្រការដ៏សំខាន់នោះ គឺគេត្រូវតែយល់ដឹងអំពីឋានានុក្រម រវាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ នៅក្នុងករណី ដែលមានភាពមិនច្បាស់លាស់ រវាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានានោះ ច្បាប់ ដែលខ្ពស់ជាងនឹងមានអានុភាព។ ចំណុចនេះ អាចបង្ហាញដូចខាងក្រោម។




*ប្រភព៖ ច្បាប់រដ្ឋបាលទូទៅ ឆ្នាំ ២០០១។*

# ជំពូកទី ២ - មន្ត្រីសំខាន់ៗ

## ព្រះរាជអាជ្ញា

### តួនាទី និងសមត្ថកិច្ច

ព្រះរាជអាជ្ញា មានតួនាទីយ៉ាងសំខាន់ នៅក្នុងបណ្តឹងអាជ្ញា/ករណីព្រហ្មទណ្ឌ។ មានតែអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា *(មាត្រា ១៣១ នៃរដ្ឋធម្មនុញ្ញ)*។ ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ចំពោះជនដែលត្រូវចោទទៅតុលាការ និងបង្ហាញភស្តុតាងក្នុងតុលាការ។

សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា គឺ *(មាត្រា ៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧)*៖

- ព្រះរាជអាជ្ញានៃទីកន្លែង ដែលមានការប្រព្រឹត្តិបទល្មើស
- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនសង្ស័យថាបានប្រព្រឹត្តបទល្មើស។

ព្រះរាជអាជ្ញាអមសាលាដំបូង មានសមត្ថកិច្ចអាចអនុវត្តតួនាទីរបស់ខ្លួន បានត្រឹមតែរាជធានី-ខេត្ត ដែលខ្លួនស្ថិតនៅតែប៉ុណ្ណោះ។

ចំណែកសមត្ថកិច្ចរបស់អគ្គព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ឬតុលាការកំពូលមានវិសាលភាព អាចអនុវត្តបានលើដែនដីទាំងមូលនៃព្រះរាជាណាចក្រកម្ពុជា។

### ទំនាក់ទំនងការងារ និងការទទួលខុសត្រូវ

ជាគោលការណ៍ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរតែជានាការអនុវត្តការងាររបស់ព្រះរាជអាជ្ញា និងចាត់វិធានការខាងវិន័យ នៅក្នុងករណីដែលមានការប្រព្រឹត្តិមិនត្រឹមត្រូវ។ ប្រសិនបើ មានបណ្តឹង ដែលទាក់ទងនឹងការប្រព្រឹត្តិមិនត្រឹមត្រូវ ឬការងាររបស់ព្រះរាជអាជ្ញា បណ្តឹងនេះ គួរតែដាក់ទៅកាន់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មានអំណាចជាកំណត់មួយចំនួនទៅលើព្រះរាជអាជ្ញាដែរ ដូចជា លោករដ្ឋមន្ត្រី អាចធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់លើករណីណាមួយ តាមផ្លូវតុលាការ។

ឧទាហរណ៍៖ *ព្រះរាជអាជ្ញាម្នាក់មិនបានចាត់ការលើបណ្ដឹងអាជ្ញាមួយ ក្រោយពេលដែលជនត្រូវចោទ បានបង់សំណងជំងឺចិត្តទៅឱ្យគ្រួសាររបស់ជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ។ នេះគឺជាការប្រព្រឹត្តមិនត្រឹមត្រូវមួយ ហើយគួរតែរាយការណ៍ទៅកាន់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬក្រសួងយុត្តិធម៌ ដើម្បីចាត់វិធានការ។*

## រូបភាពទី ១ - ទំនាក់ទំនងការងារ និងការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា




គំនូសតាងនេះ មានព្រំដែនកំណត់សំខាន់ៗចំនួន ២ គឺ៖

១. ព្រះរាជអាជ្ញាគ្រប់រូប ត្រូវគោរពតាមអធិបញ្ញាថ្នាក់លើរបស់ខ្លួន តាមឋានានុក្រម។ ប៉ុន្តែ នៅពេលសវនាការ ព្រះរាជអាជ្ញាអាចធ្វើការកត់សម្គាល់ផ្ទាល់មាត់ដោយសេរីស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះព្រះរាជអាជ្ញា ដោយសារតែវាចារបស់ខ្លួន ដែលបានបញ្ចេញនៅពេលសវនាការនោះឡើយ។

២. រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចធ្វើអធិបញ្ញាជាលាយលក្ខណ៍អក្សរ ដល់ព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញា ដើម្បីឱ្យធ្វើការចោទប្រកាន់។ ប៉ុន្តែ លោក រដ្ឋមន្ត្រី មិនអាចធ្វើអធិបញ្ញាដល់ព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញា ឱ្យធ្វើការតម្កល់ទុកឥតចាត់ការនូវរឿងក្ដីព្រហ្មទណ្ឌណាមួយបានឡើយ (មាត្រា *២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

# នគរបាលយុត្តិធម៌

## តួនាទី និងសមត្ថកិច្ច

នគរបាលយុត្តិធម៌ចែកជា ៣ ប្រភេទ ដែលមានតួនាទី និងសមត្ថកិច្ចខុសៗគ្នា ដូចខាងក្រោមនេះ *(មាត្រា ៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧)*៖

១. មន្ត្រីនគរបាលយុត្តិធម៌ *(មាត្រា ៧១-៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧)*

មន្ត្រីនគរបាលយុត្តិធម៌ មានភារកិច្ចទទួលបណ្តឹងទាមទារ ឬបណ្តឹងបរិហារ និងធ្វើកំណត់ហេតុអំពីបណ្តឹងទាំងអស់នេះ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការស៊ើបអង្កេតបឋមទៅលើបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង *(មាត្រា ៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧)*។

មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់ផ្តើមធ្វើការស៊ើបអង្កេតបឋម ទៅលើបទឧក្រិដ្ឋ ឬបទមជ្ឈិម ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌ អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ (*មាត្រា ១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ការស្តាប់ចម្លើយនីមួយៗ ត្រូវមានធ្វើកំណត់ហេតុ (*មាត្រា ១១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ដោយមានការអនុញ្ញាតពីព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គល ដើម្បីសួរចម្លើយ ប្រសិនបើបុគ្គលនោះប្រកែកមិនព្រមផ្តល់ព័ត៌មាន ប៉ុន្តែ ការឃាត់ខ្លួននេះមានថេរវេលាត្រឹមតែ ៤៨ ម៉ោងតែប៉ុណ្ណោះ។ នៅក្នុងករណីលើកលែង ថិរវេលានេះអាចត្រូវបានពន្យារ ២៤ ម៉ោងថែមទៀត។ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចឃាត់ខ្លួនអនីតិជន ដែលមានអាយុក្រោម ១៤ ឆ្នាំបានឡើយ *(មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧)*។

២. ភ្នាក់ងារនគរបាលយុត្តិធម៌ *(មាត្រា ៧៦-៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧)*

ភ្នាក់ងារនគរបាលយុត្តិធម៌ មានបេសកកម្មពិនិត្យបទល្មើសជាបទលហុ និងជួយដល់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងការបំពេញភារកិច្ចរបស់ពួកគេ។ ចំពោះការពិនិត្យបទល្មើស ភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវធ្វើរបាយការណ៍ ដែលរបាយការណ៍នេះមានតម្លៃត្រឹមតែជាព័ត៌មានធម្មតាតែប៉ុណ្ណោះ *(មាត្រា ៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧)*។

៣. មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យពិនិត្យបទល្មើសមួយចំនួន នៅក្នុងយុត្តាធិការដែនដីរបស់ខ្លួន ( *មាត្រា ៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)

បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទា ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ។

ជាធម្មតា មន្ត្រីទាំងអស់នេះ ធ្វើការងារនៅក្នុងវិស័យផ្សេងៗ ដូចជា វិស័យបរិស្ថាន ព្រៃឈើ សុខាភិបាល និងពន្ធដារ នៅតាមក្រសួងពាក់ព័ន្ធនានា។ ក្រសួងកិច្ចការនារី ក៏មានមន្ត្រី ដែលមាននីតិសម្បទា ដើម្បីធ្វើការងារលើសំណុំរឿង ដែលទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារផងដែរ។ សូមពិនិត្យមើលកថាខណ្ឌអំពីមន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី។

## ទំនាក់ទំនងការងារ និងការទទួលខុសត្រូវ

គ្រប់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ព្រះរាជអាជ្ញា។ ប៉ុន្តែ មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ក៏អាចស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរផងដែរ នៅពេលដែលចៅក្រមស៊ើបសួរ ចេញដីកាសម្រេចចាត់ឱ្យស៊ើបសួរជំនួស ( *មាត្រា ៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*) ទៅឱ្យមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ដើម្បីស្នើឱ្យធ្វើការស៊ើបអង្កេតជាក់លាក់ណាមួយ។

វិធានការខាងវិន័យ ត្រូវដាក់ដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

រូបភាពទី ២ - ទំនាក់ទំនងការងារ និងការទទួលខុសត្រូវរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ *(ប្រភេទ ក និង ខ)*

| ចៅក្រមស៊ើបសួរ<br>ដីកាសម្រេចចាត់ឱ្យស៊ើបសួរជំនួស( *មាត្រា ១៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ*) | អគ្គព្រះរាជអាជ្ញា<br>វិធានការខាងវិន័យ | ព្រះរាជអាជ្ញា |
|---|---|---|
| ↓ | ↓ | ↓ |

**មន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌**

# មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី

## តួនាទី និងសមត្ថកិច្ច

មាត្រា ១០ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ និងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ បានអនុញ្ញាតឱ្យមន្ត្រីនៃក្រសួងកិច្ចការនារីមួយចំនួន ក្លាយទៅជាមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីធ្វើសកម្មភាព នៅពេលមានករណីអំពើហិង្សាក្នុងគ្រួសារកើតឡើង។

តាមរយៈច្បាប់នេះ ប្រកាសអន្តរក្រសួងមួយ រវាងក្រសួងកិច្ចការនារី និងក្រសួងយុត្តិធម៌ លេខ ៦៤ *ប្រកកយកកន/០៧* ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០០៧ ស្តីពីការតែងតាំងមន្ត្រីក្រសួងកិច្ចការនារីទាំងឡាយខាងក្រោមនេះ បានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី ដើម្បីអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៧ គឺ៖

- អគ្គនាយកមួយរូប នៃអគ្គនាយកដ្ឋានអភិវឌ្ឍសង្គម
- អគ្គនាយករងពីររូប នៃអគ្គនាយកដ្ឋានអភិវឌ្ឍសង្គម
- ប្រធាននាយកដ្ឋានមួយរូប នៃនាយកដ្ឋានការពារផ្លូវច្បាប់
- អនុប្រធាននាយកដ្ឋានពីររូប នៃនាយកដ្ឋានការពារផ្លូវច្បាប់
- ប្រធានការិយាល័យពីររូប នៃនាយកដ្ឋានការពារផ្លូវច្បាប់
- អនុប្រធានការិយាល័យបួនរូប នៃនាយកដ្ឋានការពារផ្លូវច្បាប់
- មន្ត្រីបីរូប នៃការិយាល័យច្បាប់នៃនាយកដ្ឋានការពារផ្លូវច្បាប់
- ប្រធានទាំងម្ភៃបួនរូប របស់មន្ទីរកិច្ចការនារីរាជធានី-ខេត្ត
- អនុប្រធានទាំងម្ភៃបួនរូប របស់មន្ទីរកិច្ចការនារីរាជធានី-ខេត្ត
- ប្រធានម្ភៃបួនរូប នៃការិយាល័យកិច្ចការនារីរាជធានី-ខេត្ត
- អនុប្រធានម្ភៃបួនរូប នៃការិយាល័យកិច្ចការនារីរាជធានី-ខេត្ត។

ដើម្បីអនុវត្តការងារនេះ ប្រកាសលេខ ០៧២ *កកន/បស* ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៧ របស់ក្រសួងកិច្ចការនារី បានកំណត់តួនាទី និងសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី ដូចខាងក្រោមនេះ៖

១. ធ្វើជាដើមបណ្តឹងជួសមុខឱ្យជនរងគ្រោះ

២. ធ្វើរបាយការណ៍ និងកំណត់ហេតុ

៣. ពិនិត្យតាមដានលើវិធានការស្រាវជ្រាវបទល្មើស និង

៤. តាមដាននីតិវិធីតុលាការ ( *សាលក្រម-ការផ្តន្ទាទោស* ) ។

មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី មានសមត្ថកិច្ចនៅក្នុងក្របខ័ណ្ឌដែនដីនៃអង្គភាព ដែលពួកគេធ្វើការងារ។ នៅក្នុងរាជធានីភ្នំពេញ មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី មានសមត្ថកិច្ចទៅលើរាជធានីទាំងមូល ដោយមិនគិតអំពីទីតាំងរបស់អង្គភាព ដែលពួកគេធ្វើការងារឡើយ។

សូមកត់សម្គាល់ថា នៅពេលដែលសៀវភៅណែនាំនេះលើកឡើងអំពីមន្ត្រីនគរបាលយុត្តិធម៌ គឺជាមន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី ដែលមិនស្ថិតនៅក្រោមប្រភេទមន្ត្រីនគរបាលយុត្តិធម៌ ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ឡើយ។ សមត្ថកិច្ច និងភារកិច្ចភាគច្រើនរបស់នគរបាលយុត្តិធម៌ ដែលបានលើកឡើងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ត្រូវបានប្រគល់ដោយផ្ទាល់ទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌តែប៉ុណ្ណោះ ពោលគឺមិនមែនមន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារីឡើយ ដូចជា សមត្ថកិច្ចនៅក្នុងការស៊ើបអង្កេតរបស់នគរបាល ការឆែកឆេរ ការដកហូតវត្ថុតាង ការសួរចម្លើយ និងការឃាត់ខ្លួនជនសង្ស័យជាដើម។

### ទំនាក់ទំនងការងារ និងការទទួលខុសត្រូវ

ការគ្រប់គ្រងទៅលើការងាររបស់មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី គឺអាស្រ័យទៅលើកិច្ចការដែលត្រូវអនុវត្ត។ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី ត្រូវបានគេសង្ស័យអំពីការប្រព្រឹត្តិមិនត្រឹមត្រូវ នៅពេលដែលខ្លួនធ្វើសកម្មភាព នៅក្រោមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ នោះ ព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលជាអ្នក ដែលត្រូវជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ដើម្បីដាក់វិធានការខាងវិន័យ។ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ត្រូវជូនដំណឹងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍វិញ អំពីវិធានការខាងវិន័យ ដែលត្រូវបានចាត់ (*មាត្រា ៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ឧទាហរណ៍៖ *ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី ទទួលបានពាក្យបណ្តឹងមួយ ប៉ុន្តែ មិនបានបញ្ជូនពាក្យបណ្តឹងនេះទៅកាន់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញាគួរតែជូនដំណឹងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ នៅពេលដែលខ្លួនបានដឹងអំពីការប្រព្រឹត្តិមិនត្រឹមត្រូវនេះ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវផ្តល់ព័ត៌មានដល់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ដែលជាអ្នកត្រូវសម្រេចអំពីវិធានការខាងវិន័យ ទៅលើមន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារីរូបនេះ ក្រោយពេលស៊ើបអង្កេតទៅលើការប្រព្រឹត្តិមិនត្រឹមត្រូវនេះរួចមក។*

រូបភាពទី ៣ - ទំនាក់ទំនងការងារ និងការទទួលខុសត្រូវរបស់មន្ត្រីនគរបាលយុត្តិធម៌



# ចៅក្រមស៊ើបសួរ

## តួនាទី និងសមត្ថកិច្ច

ចៅក្រមស៊ើបសួរ បំពេញកិច្ចស៊ើបសួរ ក្រោយពេលទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរមានករណីយកិច្ចប្រមូលភស្តុតាង នៅក្នុងពេលស៊ើបសួរ។ ចៅក្រមស៊ើបសួរ ត្រូវមានអព្យាក្រឹតភាព ហើយប្រមូលភស្តុតាងទាំងដោះបន្ទុក ទាំងដាក់បន្ទុក (*មាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យជនសង្ស័យចូលខ្លួន នៅចំពោះមុខគាត់ (*មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ចៅក្រមស៊ើបសួរ ក៏អាចចេញដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទ (*មាត្រា ១៩០ និងមាត្រា ១៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*) ដីកាបង្គាប់ឱ្យចាប់ខ្លួន (*មាត្រា ១៩៦ និងមាត្រា ១៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*) និងដីកាឃុំខ្លួនជាបណ្ដោះអាសន្នផងដែរ (*មាត្រា ២០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ចៅក្រមស៊ើបសួរ អាចចេញសេចក្ដីសម្រេច (*ដីកាដំណោះស្រាយ*) ក្រោយពីការស៊ើបសួររួច ដើម្បីចោទប្រកាន់ជនសង្ស័យ ហើយបញ្ជូនសំណុំរឿងទៅកាន់ចៅក្រមជំនុំជម្រះ ឬបិទការស៊ើបសួរ ហើយលើកលែងចោទប្រកាន់ ចំពោះជនសង្ស័យ (*មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

# សភាស៊ើបសួរ

សភាស៊ើបសួរ មានសមត្ថកិច្ចជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ដែលធ្វើឡើងប្រឆាំងនឹងសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ។ ដូចគ្នានឹងចៅក្រមស៊ើបសួរដែរ សមាជិកនៃសភាស៊ើបសួរពុំអាចចូលរួមក្នុងការជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌ ដែលខ្លួនបានចាត់ការ ក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើមិនដូច្នេះទេ សាលដីកានោះចាត់ទុកជាមោឃៈ។

## ឋានានុក្រម




រូបភាពទី ៤ - ឋានានុក្រមរបស់ចៅក្រមស៊ើបសួរ

## ចៅក្រមជំនុំជម្រះ

### តួនាទី និងសមត្ថកិច្ច

ចៅក្រមជំនុំជម្រះ គឺជាអ្នកដឹកនាំសវនាការ។ ចៅក្រមរូបនេះ គួរតែគិតពិចារណា និងធ្វើសកម្មភាពដោយអព្យាក្រឹត។ ចៅក្រមរូបនេះត្រូវអនុញ្ញាតឱ្យគូភាគី និងសាក្សីរបស់ព្រះរាជអាជ្ញា មេធាវីជនត្រូវចោទ និងមេធាវីភាគីរដ្ឋប្បវេណីត្រូវបានសាកសួរ ឱ្យមានការឆ្លងឆ្លើយ តទល់គ្នារវាងជនត្រូវចោទ និងជនរងគ្រោះ និងការបង្ហាញភស្តុតាង។ ប៉ុន្តែ ចៅក្រម ដែលជាប្រធានសវនាការ អាចប្រានចោលពីសវនាការនូវអ្វីៗគ្រប់យ៉ាង ដែលគាត់យល់ឃើញថា នាំឱ្យមានការអូសបន្លាយពេលសវនាការ ដែលមិនចាំបាច់ ដោយមិនមានប្រយោជន៍ចំពោះការបញ្ជាក់អំពីការពិត ដូចជា ការសួរដដែលៗរបស់ព្រះរាជអាជ្ញា និងមេធាវីនូវសំណួរណាមួយ ដែលមិនទាក់ទងនឹងអង្គហេតុជាដើម។

### ឋានានុក្រម

រូបភាពទី ៥ - ឋានានុក្រមរបស់ចៅក្រមជំនុំជម្រះ

| | | |
|---|---|---|
| ប្រធានសាលាដំបូង<br>(ចៅក្រមម្នាក់ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ) | → | ចៅក្រមជំនុំជម្រះ (៣ នាក់...) |

## មេធាវី

### តួនាទី និងសមត្ថកិច្ច

មេធាវី មិនដែលអព្យាក្រឹតនោះឡើយ។ មេធាវីធ្វើសកម្មភាពក្នុងនាមឱ្យកូនក្តីរបស់ខ្លួន។ មេធាវីអាចជួយការពារសិទ្ធិ និងតំណាងឱ្យជនសង្ស័យ/ជនត្រូវចោទ/ជនជាប់ចោទ (*មេធាវីចុងចោទ*) ឬជនរងគ្រោះ (*មេធាវីដើមចោទ*) នៅក្នុងនីតិវិធីព្រហ្មទណ្ឌ។ នៅក្នុងនីតិវិធីរដ្ឋប្បវេណីវិញ ដូចជា នីតិវិធីនៃការលែងលះគ្នា ឬការស្នើសុំដីកាការពារជាដើម មេធាវី មានតួនាទីបញ្ជូនឯកសារ/សំណើនានា ដែលចាំបាច់ទៅកាន់តុលាការ ហើយតំណាងឱ្យកូនក្តីរបស់ខ្លួន នៅក្នុងតុលាការ ពោលគឺ និយាយក្នុងនាមឱ្យកូនក្តីរបស់ខ្លួន ដើម្បីធានាឱ្យមានការការពារ និងការផ្តល់សិទ្ធិដល់កូនក្តីរបស់ខ្លួន។

## ការធ្វើសកម្មភាពជាមេធាវីចុងចោទ

ជនសង្ស័យ ដែលត្រូវបាននគរបាលឃាត់ខ្លួនបានថិរវេលា ២៤ ម៉ោងកន្លងផុតទៅអាចស្នើសុំនិយាយបាន ៣០ នាទី ជាមួយនឹងមេធាវី ឬបុគ្គលផ្សេងទៀត ដែលខ្លួនជ្រើសរើសលើកលែងតែជនដែលជ្រើសរើសនោះ មានការពាក់ព័ន្ធនៅក្នុងរឿងជាមួយគ្នា (*មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ក្នុងករណីដែលតុលាការជំនុំជម្រះលើសំណុំរឿងមួយ ដែលត្រូវបានចាត់ទុកថាជាប្រភេទបទឧក្រិដ្ឋ ដែលប្រព្រឹត្តដោយនីតិជន ឬបទល្មើស ដែលប្រព្រឹត្តដោយអនីតិជន ប្រធានតុលាការត្រូវចាត់តាំងមេធាវីឱ្យ ប្រសិនបើជនជាប់ចោទមិនបានជ្រើសរើស ឬមិនអាចជ្រើសរើសមេធាវីដោយខ្លួនឯងបាននោះទេ (*មាត្រា ៣០០-៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ប្រសិនបើតុលាការជំនុំជម្រះលើសំណុំរឿងនៃបទឧក្រិដ្ឋ ដែលប្រព្រឹត្តដោយនីតិជន និងបទល្មើស ដែលប្រព្រឹត្តដោយអនីតិជន ដោយមិនមានវត្តមានមេធាវីនោះ សេចក្តីសម្រេចនឹងក្លាយជាឥតបានការ ដែលនឹងត្រូវកែប្រែ ឬប្រានចោល ដោយសាលាឧទ្ធរណ៍។ ចៅក្រមស៊ើបសួរ ត្រូវប្រាប់ជនត្រូវចោទឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួន នៅក្នុងការជ្រើសរើសមេធាវី (*មាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ជាគោលការណ៍ ជនត្រូវចោទអាចត្រូវសួរចម្លើយបានតែ នៅចំពោះមុខមេធាវីរបស់ខ្លួនតែប៉ុណ្ណោះ (*មាត្រា ១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ដោយមានការអនុញ្ញាតពី ចៅក្រមស៊ើបសួរ មេធាវីក៏អាចលើកសំណួរ នៅក្នុងពេលស្តាប់ចម្លើយនេះបានផងដែរ (*មាត្រា ១៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ជនត្រូវចោទ ដែលកំពុងជាប់ឃុំ អាចធ្វើការប្រាស្រ័យទាក់ទងដោយសេរីជាមួយនឹងមេធាវីរបស់ខ្លួន ហើយការសន្ទនារបស់ពួកគេត្រូវបាន រក្សាជាការសម្ងាត់ និងមិនអាចត្រូវបានគេស្តាប់ ឬកត់ត្រាឡើយ (*មាត្រា ១៤៩ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

## ការធ្វើសកម្មភាពជាមេធាវីដើមចោទ

ប្រសិនបើជនរងគ្រោះមានមេធាវីជាតំណាងដោយអាណត្តិ ការស្តាប់ចម្លើយរបស់ជនរងគ្រោះ ត្រូវធ្វើឡើងតែចំពោះមុខមេធាវីតែប៉ុណ្ណោះ (*មាត្រា ១៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ មេធាវីក៏អាចលើកសំណួរ នៅក្នុងពេលស្តាប់ចម្លើយនេះបានផងដែរ (*មាត្រា ១៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

√

បើទោះបីជាវាមិនមែនជាការតម្រូវដោយច្បាប់ក៏ដោយ ជាការសំខាន់ណាស់ ដែលជនរងគ្រោះត្រូវមានមេធាវី ដើម្បីធានាយ៉ាងណាឱ្យសិទ្ធិរបស់ពួកគេទទួលបានការការពារ នៅក្នុងនីតិវិធីព្រហ្មទណ្ឌ និងនៅក្នុងការប្ដឹងទាមទារផ្នែករដ្ឋប្បវេណី ប្រសិនបើមាន។ ចំពោះជនក្រីក្រ មានមេធាវីស្ម័គ្រចិត្ត ដែលផ្ដល់ជំនួយផ្លូវច្បាប់ ដោយមិនគិតថ្លៃសេវា។ គេគួរតែបញ្ជូនជនរងគ្រោះ ទៅរកមេធាវី ឬក្រុមមេធាវីស្ម័គ្រចិត្ត ដែលនៅជិតបំផុត។ រាល់ការស្នើសុំមេធាវីជួយជនក្រីក្រ ត្រូវស្នើសុំទៅក្រសួងយុត្តិធម៌។

## ការជំនុំជម្រះ

នៅក្នុងករណីដែលជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវបានអមដោយមេធាវី តុលាការត្រូវកោះហៅមេធាវីឱ្យចូលរួម នៅក្នុងការជំនុំជម្រះ។

មុនពេលសវនាការ មេធាវីអាចពិនិត្យមើលសំណុំរឿង នៅការិយាល័យក្រឡាបញ្ជីនៃតុលាការ នៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីនោះ។ មេធាវី ឬលេខាធិការរបស់មេធាវី អាចត្រូវបានអនុញ្ញាតដោយប្រធានតុលាការឱ្យថតចម្លងសំណុំរឿង ដោយខ្លួនជាអ្នកចេញសោហ៊ុយ និងនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី (*មាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

## ទំនាក់ទំនងការងារ និងការទទួលខុសត្រូវ

មេធាវី ជាវិជ្ជាជីវៈសេរី។ ប៉ុន្តែ ប្រសិនបើមេធាវីប្រព្រឹត្តខុសនឹងក្រមសីលធម៌ គេអាចដាក់ពាក្យបណ្ដឹងរបស់កូនក្ដី ឬអ្នកផ្សេងទៀត ទៅកាន់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលអាចចាត់វិធានការខាងវិន័យចំពោះមេធាវី ដែលបានប្រព្រឹត្តដោយរំលោភបំពានទៅលើក្រមសីលធម៌របស់ខ្លួន។ មេធាវីទាំងអស់ គឺជាសមាជិករបស់គណៈមេធាវីនេះ។

# អាជ្ញាធរមូលដ្ឋាន

## តួនាទី និងសមត្ថកិច្ច

ក្របខ័ណ្ឌច្បាប់របស់ប្រទេសកម្ពុជា បានផ្តល់ឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់នូវតួនាទីមួយ ដើម្បីការពារស្រ្តី និងកុមារពីអំពើហិង្សា។

មាត្រា ១៤ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ បានចែងថា ក្រុមប្រឹក្សាឃុំ-សង្កាត់អាចចេញសេចក្តីសម្រេចមួយ ដើម្បីចាត់វិធានការបណ្តោះអាសន្ន និងបង្គាប់ឱ្យជនមុខសញ្ញាឈប់ប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ បំផ្លាញទ្រព្យសម្បត្តិ ចូលទៅក្នុងទីលំនៅរួម ឬលក់ទីលំនៅរួមរបស់គ្រួសារ ឬចាត់វិធានការផ្សេងៗទៀតដែលយល់ឃើញថាជាការចាំបាច់។

អាពាហ៍ពិពាហ៍ និងសំបុត្រកំណើត ត្រូវតែចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។

នៅក្នុងករណីដែលភាគីណាមួយចង់ដាក់ពាក្យសុំលែងលះគ្នា គេអាចដាក់ពាក្យសុំនេះទៅកាន់ក្រុមប្រឹក្សាឃុំ-សង្កាត់។ សូមពិនិត្យមើលព័ត៌មានជាបន្ថែម នៅក្នុងជំពូកទី ៨។

## ឋានានុក្រម

ពាក្យបណ្តឹង ដែលពាក់ព័ន្ធជាមួយនឹងបុគ្គលិក មន្ត្រីអត្រានុកូលដ្ឋាន ឬសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ គួរត្រូវបានដាក់ទៅកាន់ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់។

ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ → បុគ្គលិក និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់

# វេជ្ជបណ្ឌិត

## តួនាទី និងសមត្ថកិច្ច

នៅក្នុងករណីដែលមានអំពើហិង្សាលើស្ត្រី ឬអំពើហិង្សាលើកុមារកើតឡើង ជនរងគ្រោះ គួរត្រូវបានគេនាំទៅកាន់មន្ទីរពេទ្យឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន ដើម្បីទទួលបានការព្យាបាល ជាពិសេសការធ្វើកោសល្យវិច័យ ដែលជាភស្តុតាងមួយ ពីវេជ្ជបណ្ឌិត។

# ជំពូកទី ៣ - ការណែនាំអំពីច្បាប់ព្រហ្មទណ្ឌ

## និយមន័យនៃបទល្មើស

បទល្មើសព្រហ្មទណ្ឌ គឺជាបទល្មើសមួយ ដែលត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌ។ ជាគោលការណ៍ ប្រសិនបើច្បាប់ពុំបានចែងទង្វើណាមួយ ថាជាបទល្មើសទេនោះ គេមិនអាចចាត់ទុកទង្វើនោះថាជាបទល្មើស ដែលត្រូវផ្តន្ទាទោសបានទេ (*មាត្រា ៣ នៃក្រមព្រហ្មទណ្ឌដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០*)។

> ឧទាហរណ៍៖ *លោក សំណាង បានចាប់រំលោភកញ្ញា ធឿន ដែលជាអ្នកជិតខាងរបស់គាត់។ អំពើនេះ គឺជាបទល្មើសរំលោភសេពសន្ថវៈ ដែលមានចែងនៅក្នុងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០។*

បើយោងតាមក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០ បានឱ្យដឹងថាបទល្មើសត្រូវបានបែងចែកជា ៣ ប្រភេទ ទៅតាមកម្រិតធ្ងន់ធ្ងររបស់បទល្មើស៖

### ១. បទលហុ

និយមន័យ៖ បទល្មើសណាមួយ ជាបទលហុ នៅក្នុងករណីដែល

(១) អតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះ មានរយៈពេលក្រោម ឬស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ។ ទោសដាក់ពន្ធនាគារ អាចបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ និង

(២) បទល្មើស ត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់តែប៉ុណ្ណោះ (*មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០*)។

> ឧទាហរណ៍៖ *ការគំរាមកំហែងថានឹងបផ្លិចបំផ្លាញ ឬធ្វើឱ្យខូចកង់របស់នរណាម្នាក់ ត្រូវផ្តន្ទាទោសដោយការពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ដល់ ១០០.០០០ (មួយសែន) រៀល (ដោយសារការខូចខាតនេះ មានទំហំតូចតាច ដូច្នេះ គេត្រូវអនុវត្តមាត្រា ៤២៣ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០)។*

## ២. បទមជ្ឈិម

និយមន័យ៖ បទល្មើសណាមួយ ជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវវងនោះ មានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ។ ទោសដាក់ពន្ធនាគារ អាចបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ (*មាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០*)។

> ឧទាហរណ៍៖ *លោក វិជ្ជា ដែលជាអ្នកគ្រប់គ្រងរោងចក្រកាត់ដេរមួយ បានប៉ះពាល់ដោះស្ត្រីជាកម្មករកាត់ដេររបស់គាត់ម្នាក់ ដោយមិនបានឱ្យដឹងខ្លួនជាមុន និងមិនមានការយល់ព្រមពីនាងនោះទេ។ នៅក្នុងករណីនេះ បើយោងតាមមាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០ បានឱ្យដឹងថា ជាបទប្រទូស្តកេរខ្មាស ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២ លានរៀល ទៅ ៦ លានរៀល។*

## ៣. បទឧក្រិដ្ឋ

និយមន័យ៖ បទល្មើសណាមួយ ជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោស ដែលត្រូវវងនោះ (១) ជាទោសដាក់ពន្ធនាគារមួយជីវិត ឬ (២) ជាទោសដាក់ពន្ធនាគារ មានរយៈពេលលើសពី ៥ ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ ឆ្នាំ។ ទោសដាក់ពន្ធនាគារ អាចបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ (*មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅ ចុងឆ្នាំ ២០១០*)។

> ឧទាហរណ៍៖
>
> - *ឃាតកម្មគិតទុកជាមុន មានទោសជាអតិបរមាជាប់ពន្ធនាគារ អស់មួយជីវិត។*
> - *ការរំលោភសេពសន្ថវៈ មានទោសជាអតិបរមាជាប់ពន្ធនាគារ ១០ ឆ្នាំ។*
> - *ការសូកប៉ាន់មន្ត្រីរាជការ មានទោសជាអតិបរមាជាប់ពន្ធនាគារ ១០ ឆ្នាំ។*
> - *ការទទួលយកសំណូកដោយមន្ត្រីរាជការណាម្នាក់ មានទោសជាអតិបរមាជាប់ពន្ធនាគារ ១៥ ឆ្នាំ។*

## មូលហេតុនៃការរលត់បណ្តឹងអាជ្ញា

គេមិនអាចនៅតែបន្តចាត់ការលើបទល្មើសមួយឡើយ ប្រសិនបើជនជាប់ចោទ៖

- ទទួលមរណភាព
- ការផុតអាជ្ញាយុកាល
- ត្រូវបានផុតរលត់
- ការលើកលែងទោសជាទូទៅ
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- សំណុំរឿងត្រូវបានជំនុំជម្រះដោយតុលាការ ដែលមានសមត្ថកិច្ចរួចទៅហើយ (*មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

## អាជ្ញាយុកាល

| | | |
|---|---|---|
| បទលហុ - ១ ឆ្នាំ | បទមជ្ឈិម - ៥ ឆ្នាំ | បទឧក្រិដ្ឋ - ១៥ ឆ្នាំ។ |

ថិរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស ប៉ុន្តែ ត្រូវផ្តាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ (*មាត្រា ១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ក្រោយពេលបញ្ចប់ការផ្តាច់នេះហើយ ថិរវេលាថ្មីនៃអាជ្ញាយុកាលត្រូវចាប់ផ្តើមគិត។

ឧទាហរណ៍៖ *កញ្ញា **គ** ត្រូវបានគេចាប់រំលោភ (បទឧក្រិដ្ឋ) នៅក្នុងឆ្នាំ ១៩៩៥ ហើយពុំមានតម្រុយជនសង្ស័យសោះ។ នៅក្នុងឆ្នាំ ២០១៣ មានសាក្សីម្នាក់ បានចូលខ្លួនមកបង្ហាញ។ ការស៊ើបអង្កេតត្រូវបានចាប់ផ្តើម ហើយជនសង្ស័យត្រូវបានចាប់ខ្លួន។ ប៉ុន្តែ អាជ្ញាយុកាលនៃបទល្មើសប្រភេទនេះ គឺ ១៥ ឆ្នាំ ដូច្នេះ គេមិនអាចកាត់ទោសជនល្មើសនេះបានឡើយ។*

ឧទាហរណ៍៖ *កញ្ញា **គ** ត្រូវបានគេចាប់រំលោភ (បទឧក្រិដ្ឋ) នៅក្នុងឆ្នាំ ១៩៩៥ ហើយពុំមានតម្រុយជនសង្ស័យសោះ។ នៅក្នុងឆ្នាំ ២០០៣ ការផ្តល់តម្រុយ នាំឱ្យមានការបើកការស៊ើបអង្កេតឡើងវិញ ប៉ុន្តែការស៊ើបអង្កេតនេះពុំបានរកឃើញអ្វីឡើយ។ នៅក្នុងឆ្នាំ ២០១៣ សាក្សីថ្មីម្នាក់បានចូលខ្លួនមកបង្ហាញ។ ការស៊ើបអង្កេតបានចាប់ផ្តើម ហើយជនសង្ស័យត្រូវបានចាប់ខ្លួន។ នៅពេលនេះ គេអាចកាត់ទោសជនល្មើសបានដោយសារតែការស៊ើបអង្កេតនៅក្នុងឆ្នាំ ២០០៣ បានកាត់ផ្តាច់ថិរវេលានៃអាជ្ញាយុកាល ហើយថិរវេលា ១៥ ឆ្នាំថ្មី បានចាប់ផ្តើមក្រោយពេលបិទការស៊ើបអង្កេតនៅក្នុងឆ្នាំ ២០០៣។*

បណ្ដឹងអាជ្ញា ក៏អាចផុតរលត់ (*មាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*) បានផងដែរ៖

- ❖ ដោយការដកពាក្យប្ដឹង នៅក្នុងករណីដែលពាក្យប្ដឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ
- ❖ ដោយការសម្របសម្រួលជាមួយរដ្ឋ
- ❖ ដោយការបង់ប្រាក់ពិន័យ ដែលបានព្រមព្រៀងគ្នា។

ឧទាហរណ៍៖ *ការដកពាក្យបណ្ដឹងរបស់ជនរងគ្រោះ បន្ទាប់ពីបានព្រមព្រៀងគ្នាបង់ប្រាក់ពិន័យ។*

គ្មានការសម្រុះសម្រួលណាមួយ អាចត្រូវបានធ្វើឡើង (*ដោយខុសច្បាប់*) ដែលនាំឱ្យមានការបញ្ចប់បណ្ដឹងព្រហ្មទណ្ឌបានឡើយ។

មានការអនុវត្តជាទូទៅ នៅក្នុងប្រទេសកម្ពុជាថា នៅពេលដែលក្រុមគ្រួសាររបស់ជនរងគ្រោះ ដោយសារការរំលោភសេពសន្ថវៈយល់ព្រមលើចំនួនទឹកប្រាក់សំណងពីជនល្មើស នោះករណីនេះនឹងត្រូវបានទម្លាក់ចោល ដោយមន្ត្រីនគរបាលយុត្តិធម៌ និង/ឬព្រះរាជអាជ្ញា។ ក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា ប្រសិនបើជនរងគ្រោះដកពាក្យបណ្ដឹងរបស់ខ្លួន ការលះបង់នេះ មិនព្យួរបណ្ដឹងអាជ្ញានោះទេ (*មាត្រា ២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ក្រមនេះ ក៏បានចែងយ៉ាងច្បាស់លាស់ផងដែរថា នគរបាលមិនអាចតម្កល់រឿងព្រហ្មទណ្ឌណាមួយទុកឥតចាត់ការបានទេ ទោះបីជាក្រោយពីមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះ ឬក៏មានការដកពាក្យប្ដឹងក៏ដោយ (*មាត្រា ៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ការអនុវត្តដែលអាក្រក់ដូចគ្នានេះដែរ គឺការបង្ខិតបង្ខំឱ្យជនរងគ្រោះ ដោយសារការរំលោភសេពសន្ថវៈ រៀបការជាមួយនឹងជនល្មើស ដើម្បីស្ដារកិត្តិយសគ្រួសាររបស់ជនរងគ្រោះ។ មន្ត្រីអនុវត្តច្បាប់ មិនគួរលើកទឹកចិត្តឱ្យគ្រួសារទទួលយកដំណោះស្រាយបែបនេះឡើយ ដោយសារតែវាគឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើសិទ្ធិរបស់ស្ត្រី។

## ការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម

ការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកចំពោះបទមជ្ឈិម អាចត្រូវបានផ្តន្ទាទោស កាលណាលក្ខខណ្ឌទាំងឡាយ ដូចខាងក្រោមនេះ ត្រូវបានបំពេញ( *មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០*)៖

- ចារី បានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើ ដែលមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស និង
- ចារី មិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញ ដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខាន ដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន។

ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសនោះទេ។

## ការទទួលខុសត្រូវព្រហ្មទណ្ឌ

គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ មានន័យថា បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌ តែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ ( *មាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០* )។

### ចារី

ចារី សំដៅលើបុគ្គលណា ដែលប្រព្រឹត្តបទល្មើស។ បុគ្គលណា ដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម ក៏ត្រូវចាត់ទុកថាជាចារីផងដែរ។

### សហចារី

សហចារី សំដៅលើកាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់ ( *មាត្រា ២៦ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០*)។

អ្នកផ្តើមគំនិត ( *មាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០*)

អ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម គឺជាបុគ្គល ដែលជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។

អ្នកសមគំនិត *(មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០)*

អ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម គឺជាបុគ្គលណា ដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។ អ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវផ្តន្ទាទោសដូចគ្នានឹងចារីផងដែរ។

អនីតិជន *(មាត្រា ៣៨ ដល់ ៤១ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០)*

អនីតិជន (អាយុក្រោម ១៨ ឆ្នាំ) ដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ (*មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០*)។ ប៉ុន្តែ ការផ្តន្ទាទោសលើអនីតិជន ដែលមានអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ ត្រូវអនុវត្ត ដូចខាងក្រោមនេះ៖

- ការផ្តន្ទាទោសអតិបរមាជាប់ពន្ធនាគារ ត្រូវកាត់បន្ថយពាក់កណ្តាល។ ប្រសិនបើការផ្តន្ទាទោសអតិបរមា គឺការជាប់ពន្ធនាគារអស់មួយជីវិត ត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ ឆ្នាំ។
- អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បរមានេះមានរយៈពេលលើសពី ១ ថ្ងៃ។
- អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបានបន្ថយពាក់កណ្តាល។

នីតិបុគ្គល *(មាត្រា ១៨ ដល់ ៤២ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០)*

ជាគោលការណ៍ នីតិបុគ្គលអាចទទួលខុសត្រូវលើបទល្មើសមួយ ប្រសិនបើមានការចែងយ៉ាងច្បាស់នៅក្នុងច្បាប់។ ការផ្តន្ទាទោស ដែលអាចដាក់ទៅលើនីតិបុគ្គល (*មាត្រា ១៦៧ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០*) មានដូចខាងក្រោមនេះ៖

- ទោសពិន័យជាប្រាក់ នៅក្នុងស្ថានភាពមូលទោស
- ទោសបន្ថែម ដែលមានចែងដោយច្បាប់សម្រាប់នីតិបុគ្គល។

## គោលការណ៍នៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

មានមូលហេតុមួយចំនួន ដែលអាចឱ្យរូបវន្តបុគ្គល ដែលប្រព្រឹត្តបទល្មើស អាចរួចពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដូចខាងក្រោមនេះ៖

### ការការពារដោយស្របច្បាប់

បុគ្គលណា ដែលប្រព្រឹត្តបទល្មើសមួយ ក្នុងស្ថានភាពការពារខ្លួនដោយស្របច្បាប់ មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ ការការពារខ្លួនដោយស្របច្បាប់ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមនេះ ( *មាត្រា ៣៣ និង ៣៤ នៃក្រមព្រហ្មទណ្ឌ*)៖

- បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវ ដោយការចាំបាច់ ដើម្បីការពារខ្លួនឯង ឬការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឈមមុខនឹងការឈ្លានពានមួយ ដែលមិនត្រឹមត្រូវ។
- បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា ហើយ
- គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារ ដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។

ឧទាហរណ៍៖ *លោក សុភាព ដែលជាប្តី បានផឹកស្រាស្រវឹង ពេលមកដល់ផ្ទះ ហើយបានឃើញប្រពន្ធរបស់ខ្លួន នៅជាមួយនឹងបុរសម្នាក់ទៀត។ គាត់គិតថា នាងកំពុងតែប្រព្រឹត្តអំពើសាហាយស្មន់ ហើយក៏បានយកពូថៅមកកាប់ប្រពន្ធរបស់គាត់ និងបុរសម្នាក់នោះ។ ក្នុងពេលនោះ ប្រពន្ធ ដែលស្រវាយកបានកាំបិតនៅក្បែរខ្លួន ក៏បានចាក់គាត់ចំដើមទ្រូង ក្នុងពេលដែលប្តីដេញតាមកាប់នាង និងបុរសម្នាក់នោះ។ ប្តីនោះក៏ស្លាប់ទៅ។ ទង្វើរបស់ប្រពន្ធបែបនេះ បានបំពេញតាមលក្ខខណ្ឌនៃការការពារខ្លួន។*

នៅពេលដែលជនជាប់ចោទ បានអះអាងថា អំពើហិង្សានេះត្រូវបានប្រព្រឹត្ត ដើម្បីការពារខ្លួន ការការពារបែបនេះ គួរត្រូវបានលើកយកមកបង្ហាញនៅក្នុងតុលាការ។ នៅក្នុងករណីដែលស្ត្រី និងកុមារជាជនរងគ្រោះដោយសារអំពើហិង្សា ពេលខ្លះពួកគេក្លាយជាជនជាប់ចោទ នៅក្នុងតុលាការទៅវិញ នៅពេលដែលពួកគេបានការពារខ្លួននោះ។

## វិបល្លាសស្មារតី

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ប៉ុន្តែ កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។ ដូច្នេះ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិ ដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ (*មាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០*) ។

## ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

បុគ្គលណា ដែលប្រព្រឹត្តអំពើដែលបានបញ្ញត្តិ ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ។ បុគ្គលណា ដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ (មា*ត្រា ៣២ នៃក្រមព្រហ្មទណ្ឌដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០*)។

ឧទាហរណ៍៖ *លោក សុខុម ដែលជាមន្ត្រីនគរបាលយុត្តិធម៌ម្នាក់ បានបញ្ជាឱ្យភ្នាក់ងារនគរបាលយុត្តិធម៌ បោះចោលថង់សម្រាម នៅកន្លែងកើតហេតុ។ ប៉ុន្តែ ក្រោយមក គេបានដឹងថា លោក សុខុម ពិតជាបានដឹងថា ថង់នោះមានភស្តុតាងដ៏សំខាន់ ដើម្បីប្រឆាំងនឹងមិត្តភក្តិដ៏ល្អម្នាក់របស់លោកសុខុម ដែលជាជនសង្ស័យម្នាក់នៅក្នុងបទល្មើសនេះ។ ភ្នាក់ងារនគរបាលយុត្តិធម៌ ពុំអាចមានកំហុសប្រព្រឹត្តបទល្មើសនៃការលាក់បាំងភស្តុតាងឡើយ ដោយសារតែគាត់មិនបានដឹងអំពីអ្វីដែលមាននៅក្នុងថង់នោះឡើយ ហើយគាត់បានធ្វើតាមតែបញ្ជារបស់គេតែប៉ុណ្ណោះ (*មាត្រា *៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០)*។

# ជំពូកទី ៤ - នីតិវិធីព្រហ្មទណ្ឌ

នៅពេលពិភាក្សាគ្នាអំពីកិច្ចការពារសិទ្ធិស្ត្រី និងកុមារ នៅក្នុងបរិបទអំពើហិង្សាលើស្ត្រី/កុមារ នៅក្នុងនីតិវិធីព្រហ្មទណ្ឌ ជាធម្មតា ស្ត្រី/កុមារគឺជាជនរងគ្រោះ។ ប៉ុន្តែ ស្ត្រី/កុមារក៏អាចជាជនជាប់ចោទប្រព្រឹត្តអំពើហិង្សា នៅក្នុងករណីការពារខ្លួនផងដែរ។ ដូច្នេះ សិទ្ធិរបស់ជនរងគ្រោះ និងសិទ្ធិរបស់ជនសង្ស័យ/ជនត្រូវចោទ/ជនជាប់ចោទ ត្រូវបានលើកយកមកពិភាក្សាគ្នា នៅក្នុងជំពូកនេះ។

សិទ្ធិ/ករណីយកិច្ចដ៏សំខាន់ជាងគេបំផុត សម្រាប់ជនរងគ្រោះ ត្រូវបានលើកយកមកគូសបញ្ជាក់នៅក្នុងជំពូកនេះ ដែលរួមមាន៖

- ការដាក់ពាក្យប្តឹងព្រហ្មទណ្ឌ
- សិទ្ធិទទួលបានជំនួយពីមេធាវី (*ទោះបីជាមិនបានកំណត់ដោយច្បាប់ក៏ដោយ*)
- សិទ្ធិទទួលបានព័ត៌មានពីព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរអំពីការសម្រេចចិត្ត ដែលពាក់ព័ន្ធនឹងការបន្តចាត់ការលើសំណុំរឿង និងការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ
- ការដាក់សេចក្តីសំអាងរបស់ជនរងគ្រោះជាកស្តុតាង ប្រសិនបើមានការស្នើសុំពីចៅក្រមជំនុំជម្រះឱ្យមកធ្វើសក្ខីកម្មនៅក្នុងសវនាការ
- សិទ្ធិដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី នៅក្នុងនីតិវិធីព្រហ្មទណ្ឌ ដើម្បីស្នើសុំសំណងជំងឺចិត្ត
- សិទ្ធិចូលរួមនៅក្នុងការជំនុំជម្រះ។

ច្បាប់ និងអ្នកអនុវត្តច្បាប់ ដែលពាក់ព័ន្ធនឹងសំណុំរឿងអំពើហិង្សាលើស្ត្រី មិនបានផ្តល់កិច្ចការពារអត្តសញ្ញាណរបស់ជនរងគ្រោះ ពីជនជាប់ចោទឱ្យបានគ្រប់គ្រាន់ឡើយ។ ជាធម្មតា ពួកគេត្រូវបានស្នើសុំឱ្យមកធ្វើសក្ខីកម្មនៅក្នុងការជំនុំជម្រះ (*បើទោះបីជាពួកគេបានផ្តល់សេចក្តីសំអាងជាច្រើន ទៅនគរបាល និងព្រះរាជអាជ្ញារួចមកហើយក្តី*)។ នៅក្នុងពេលជំនុំជម្រះ ជាធម្មតា ពួកគេអាចមើលឃើញជនជាប់ចោទ។ អ្នកសាកសួរ និងចៅក្រមជំនុំជម្រះ ជាញឹកញាប់ មិនមានការប្រយ័ត្នប្រយែង ឬមានបុរេវិនិច្ឆ័យលើបញ្ហានេះ។

## ១. បណ្តឹងព្រហ្មទណ្ឌ

ជនរងគ្រោះ មានសិទ្ធិដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ។ បណ្តឹងព្រហ្មទណ្ឌអាចដាក់ទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញា (*មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី អាចទទួលពាក្យបណ្តឹងបាន*)។ ជនរងគ្រោះក៏អាចដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ទៅកាន់ចៅក្រមស៊ើបសួរផងដែរ ដើម្បីទាមទារសំណងជំងឺចិត្តពីជនល្មើស។

ព្រះរាជអាជ្ញា គឺជាអ្នកសម្រេចចិត្ត ថាតើត្រូវចាប់ផ្តើមនីតិវិធីព្រហ្មទណ្ឌដែរ ឬអត់តាមបណ្តឹងទាមទារ ដែលបានដាក់ដោយជនរងគ្រោះ/សាច់ញាតិរបស់ជនរងគ្រោះ ឬបណ្តឹងបរិហារ (*"តម្រុយ"*) ដែលបានដាក់មកព្រះរាជអាជ្ញាដោយផ្ទាល់ ឬបានដាក់ទៅកាន់មន្ត្រីនគរបាលយុត្តិធម៌។

រូបភាពទី ៦ - បណ្តឹងព្រហ្មទណ្ឌ




ឧទាហរណ៍៖ *នៅព្រឹកព្រលឹមមួយ លោកស្រី សៅ បានឃើញជន ជួញដូរមនុស្សមួយក្រុម ដែលបាននឹងកំពុងតែប៉ុនប៉ងនាំក្មេងស្រីចំនួន ១០ នាក់ឆ្លងកាត់ព្រំដែននៅមុខផ្ទះរបស់គាត់។ គាត់បានរាយការណ៍ អំពីហេតុការណ៍នេះទៅកាន់មន្ត្រីនគរបាលយុត្តិធម៌។ មន្ត្រីនគរបាលយុត្តិធម៌នោះ បានរាយការណ៍បន្តទៅកាន់ព្រះរាជអាជ្ញា។*

ជនរងគ្រោះមានសិទ្ធិដាក់ពាក្យបណ្ដឹង។ ប៉ុន្តែ មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការ នារី ក៏អាចដាក់ពាក្យបណ្ដឹងបានផងដែរ ក្នុងនាមឱ្យជនរងគ្រោះ ដោយសារអំពើហិង្សាក្នុងគ្រួសារ (*មាត្រា ១០ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥*)។



សូមកត់សម្គាល់ថា គេមិនអាចដាក់ពាក្យបណ្ដឹងជួសមុខឱ្យជនរងគ្រោះ នៅក្នុងករណីរំលោភសេពសន្ថវៈ ការជួញដូរមនុស្ស ឬអំពើហិង្សាលើស្ត្រីផ្សេងៗទៀត ដែលមិនមែនជាអំពើហិង្សាក្នុងគ្រួសារនោះឡើយ។

កំណត់សម្គាល់៖ ទោះបីជាយ៉ាងណា ក៏ដោយ តួនាទី និងគោលនយោបាយរបស់ក្រសួងកិច្ចការនារី អាចជួយជនរងគ្រោះនៃអំពើហិង្សាលើស្ត្រី។

នៅពេលទទួលពាក្យបណ្ដឹង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុ ដូចដែលមានចែងនៅក្នុងមាត្រា ៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលក្នុងនោះត្រូវមានចុះសេចក្ដី ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងកាលបរិច្ឆេទ។

គ្រប់អង្គភាពនគរបាលយុត្តិធម៌ ត្រូវរៀបចំជាបញ្ជីបណ្ដឹង ដូចមានចែងនៅក្នុងមាត្រា ៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧។ បញ្ជីត្រូវមានចុះសេចក្ដីអត្តសញ្ញាណរបស់អ្នកប្ដឹង កាលបរិច្ឆេទនៃការដាក់ពាក្យបណ្ដឹង ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើកំណត់ហេតុស្ដីពីការដាក់ពាក្យបណ្ដឹង ប្រភេទនៃអំពើដែលប្ដឹង ចំណាត់ការលើបណ្ដឹង ដូចជាការបញ្ជូនទៅព្រះរាជអាជ្ញា ឬក៏ការចាប់ផ្ដើមធ្វើការស៊ើបអង្កេត។

ក្រោយពីបានទទួលពាក្យបណ្ដឹងរួចមក មន្ត្រីនគរបាលយុត្តិធម៌ ត្រូវចាប់ផ្ដើមធ្វើការស៊ើបអង្កេតភ្លាមៗ ឬក៏បញ្ជូនកំណត់ហេតុស្ដីពីការដាក់ពាក្យបណ្ដឹងនោះទៅព្រះរាជអាជ្ញាដើម្បីចាត់ការតទៅ។ ក្នុងករណី ទទួលពាក្យបណ្ដឹងបរិហារ ដែលមានបង្ហាញមូលហេតុសមហេតុផល មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា និងសុំការណែនាំ (*មាត្រា ៧៤ នៃនីតិវិធីក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ សម្រេចចិត្តធ្វើការស៊ើបអង្កេត មុនពេលបញ្ជូនរបាយការណ៍នៃពាក្យបណ្តឹង គឺពួកគេមានសមត្ថកិច្ចនៅក្នុងការ៖

- ស៊ើបអង្កេត និងពិនិត្យបទល្មើស
- ឆែកឆេរ
- ស្តាប់ចម្លើយរបស់ជនទាំងឡាយណា ដែលមានព័ត៌មាន ពាក់ព័ន្ធជាមួយនឹងសំណុំរឿងនេះ
- កោះហៅអ្នកជំនាញឱ្យធ្វើកោសលវិច័យបច្ចេកទេស និងវិទ្យាសាស្ត្រ និងឃាត់ខ្លួនជនសង្ស័យជាដើម។

(លើកលែងតែមន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី មិនអាចស៊ើបអង្កេតបានឡើយ)។

## ២. ការស៊ើបអង្កេតបឋម



ព្រះរាជអាជ្ញា អាចចាប់ផ្តើមធ្វើការស៊ើបអង្កេតបឋម លើពាក្យប្តឹង (*មាត្រា៨០នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ព្រះរាជអាជ្ញា អាចចាត់ឱ្យមន្ត្រីនគរបាល យុត្តិធម៌ បំពេញកិច្ចការនេះ ឬធ្វើការស៊ើបអង្កេតលើ សំណុំរឿងនេះ ដោយខ្លួនឯង។ ព្រះរាជអាជ្ញា មានអំណាចបញ្ជាឱ្យមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការចាប់ខ្លួន ឬបញ្ជាឱ្យបុគ្គល ដែលអាចផ្តល់ព័ត៌មានអំពីបទល្មើសនេះ ចូលបង្ហាញខ្លួន ឬបញ្ជាឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឆែកឆេរ និងដកហូតវត្ថុតាង និងអាចអនុញ្ញាតឱ្យបន្តឃាត់ខ្លួនជនសង្ស័យបាន។

## ៣. ការប្រមូលភស្តុតាង

ភស្តុតាងតាមន័យគតិយុត្ត សំដៅលើមធ្យោបាយ ដែលគេអាចបញ្ជាក់អំពីអង្គហេតុ ដូចបានចោទប្រកាន់ ឬបញ្ជាក់ថា អង្គហេតុនេះ គឺជាការពិត ឬមិនពិត។

ដើម្បីផ្តល់លទ្ធភាពឱ្យមានការចោទប្រកាន់ នៅក្នុងសំណុំរឿងអំពើហិង្សាលើស្ត្រី និងកុមារ អ្វីដែលសំខាន់បំផុតនោះ គឺត្រូវមានភស្តុតាង ដោយសារតែករណីទាំងអស់នេះ ភាគច្រើនពឹងផ្អែកតែទៅលើសេចក្តីសំអាងរបស់ជនរងគ្រោះ និងជនសង្ស័យតែប៉ុណ្ណោះ។

### ភស្តុតាងនៅទីកន្លែងកើតហេតុ

មន្ត្រីនគរបាលយុត្តិធម៌ដំបូងគេ ដែលស្ថិតនៅទីកន្លែងកើតហេតុ គួរតែជានាយ៉ាងណា មិនឱ្យមានការប៉ះពាល់ភស្តុតាងនៅទីកន្លែងកើតហេតុ ការពារភស្តុតាង ដែលអាចត្រូវបានគេបំផ្លាញចោល ធ្វើកំណត់ហេតុអំពីទីកន្លែងកើតហេតុនោះ និងកត់ត្រាឈ្មោះសាក្សី។

នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ផ្សេងទៀត មកដល់ទីកន្លែងកើតហេតុ ពួកគេអាចចាប់ផ្តើមកត់ត្រាជាឯកសារអំពីទីកន្លែងកើតហេតុ ដូចជា ការថតវីដេអូ ការថតរូប និង/ឬការគូសគំនូសព្រាង និងប្រមូល ហើយបិទថង់ ដែលដាក់ភស្តុតាង។

### ការស្តាប់ចម្លើយជនសង្ស័យ

មន្ត្រីនគរបាលយុត្តិធម៌ អាចបញ្ជាឱ្យជនសង្ស័យបង្ហាញខ្លួន នៅការិយាល័យនគរបាល ដើម្បីស្តាប់ចម្លើយ។ ប្រសិនបើចាំបាច់ នគរបាលអាចឃាត់ខ្លួនជនសង្ស័យនោះ ដែលជាគោលការណ៍មិនត្រូវលើសពី ៤៨ ម៉ោងឡើយ។ នៅក្នុងករណីបទឧក្រិដ្ឋ ហើយភស្តុតាងបង្ហាញថា ជនសង្ស័យពិតជាបានប្រព្រឹត្តមែន ព្រះរាជអាជ្ញាអាចពន្យារបើរវេលាឃាត់ខ្លួននេះបាន ២៤ ម៉ោងថែមទៀត។

### សេចក្តីសំអាងរបស់ជនរងគ្រោះ និង/ឬសាក្សី

មន្ត្រីនគរបាលយុត្តិធម៌ ដែលស្តាប់ចម្លើយ គួរតែធ្លាប់ទទួលបានការបណ្តុះបណ្តាលអំពីរបៀបធ្វើសម្ភាសន៍ជនរងគ្រោះ ឬសាក្សី ដែលកំពុងមានការប៉ះទង្គិចផ្លូវចិត្ត ដើម្បីមានលទ្ធភាពសាកសួរជនរងគ្រោះ ឬសាក្សីនោះ តាមលក្ខណៈដែលមានការប្រយ័ត្នប្រយែង និងមិនមានបុរេវិនិច្ឆ័យ។ ជាការសំខាន់ណាស់ ដែលត្រូវបង្កើតឱ្យមានបរិយាកាសមួយ ដែលធ្វើឱ្យជនរងគ្រោះ/សាក្សីនោះមានអារម្មណ៍ទុកចិត្ត នៅក្នុងការចែករំលែកព័ត៌មានលំអិត ដែលគួរឱ្យ

អាម៉ាសគ្រប់បែបយ៉ាងទាំងអស់ អំពីការវាយប្រហារនេះ។ ការមានមន្ត្រីនគរបាលយុត្តិធម៌ជាស្ត្រីធ្វើសម្ភាសន៍ អាចជួយបានច្រើនណាស់។ ប៉ុន្តែ អ្វីដែលសំខាន់ជាងគេនោះ គឺអាកប្បកិរិយារបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើសម្ភាសន៍នោះ។

### ភស្តុតាងផ្នែកវេជ្ជសាស្ត្រ

នៅពេលដែលជនរងគ្រោះ មិនទទួលរងរបួសធ្ងន់ធ្ងរទេ គេគួរតែធ្វើសម្ភាសន៍ជនរងគ្រោះនេះជាមុនសិន ដើម្បីទទួលបានចម្លើយពីគាត់។ ភ្លាមៗ ក្រោយពេលស្តាប់ចម្លើយលើកដំបូងនេះចប់ ជនរងគ្រោះរូបនេះគួរត្រូវបានបញ្ជូន ទៅកាន់បន្ទប់សង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យ ដែលនៅជិតបំផុត ដើម្បីពិនិត្យសុខភាព។ ជាការល្អបំផុតនោះ សម្លៀកបំពាក់ថ្មីសម្រាប់ផ្លាស់ប្តូរគួរតែយកទៅតាមជនរងគ្រោះ ដើម្បីឱ្យគេអាចប្រមូលសម្លៀកបំពាក់ចាស់របស់ជនរងគ្រោះធ្វើជាភស្តុតាងបាន ប្រសិនបើមានឈាម ទឹកកាម ឬស្នាមប្រឡាក់ ឬ មានការដាច់រហែកនៅលើសម្លៀកបំពាក់នោះ។

មន្ត្រីនគរបាលយុត្តិធម៌ គួរតែជួយជនរងគ្រោះឱ្យទទួលបានលិខិតកោសលវិច័យពីមន្ទីរពេទ្យបង្អែករាជធានី-ខេត្ត ដែលគេអាចប្រើប្រាស់ធ្វើជាភស្តុតាងនៅក្នុងតុលាការ ឬយ៉ាងហោចណាស់ស្នើសុំឱ្យវេជ្ជបណ្ឌិត ចេញលិខិតសំអាងមួយ ដែលបញ្ជាក់អំពីស្នាមរបួស ដែលបានមើលឃើញ។

លិខិតកោសលវិច័យ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ៥។ ការចំណាយទៅលើលិខិតកោសលវិច័យនេះ គឺមានតម្លៃ ១២,៥០ ដុល្លារ (ស្មើនឹង ៥០.០០០ រៀល)។

√ ជាការសំខាន់ជាទីបំផុតនោះ គឺជនរងគ្រោះត្រូវទទួលបានការពិនិត្យ ដោយវេជ្ជបណ្ឌិតឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្រោយពេលមានការវាយប្រហារបានកើតឡើង។ នៅពេលដែលពេលវេលាកាន់តែកន្លងផុតទៅ ក្រោយពេលមានការវាយប្រហារបានកើតឡើងនោះ វេជ្ជបណ្ឌិតអាចរកឃើញភស្តុតាងកាន់តែតិច។ នេះគឺជាចំណុចដ៏សំខាន់ពិសេស សម្រាប់ករណីអំពើហិង្សាលើស្ត្រី និងកុមារ ដែលជាធម្មតា គេមានភស្តុតាងផ្សេងទៀតតិចតួចជាទីបំផុត។ ប្រសិនបើជនរងគ្រោះមានជីវភាពក្រីក្រ មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារីគួរតែព្យាយាមធ្វើការចរចាអំពីតម្លៃនៃការធ្វើលិខិតកោសលវិច័យនេះ ជាមួយនឹងមន្ទីរពេទ្យបង្អែករាជធានី-ខេត្ត ឬស្វែងរកអង្គការមិនមែនរដ្ឋាភិបាលណាមួយ ដែលអាចជួយចេញថ្លៃនេះបាន។ ជួនកាល គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមាររាជធានី-ខេត្ត ក៏អាចធ្វើការចរចាជាមួយនឹងមន្ទីរពេទ្យបង្អែករាជធានី-ខេត្ត ដើម្បីមិនយកថ្លៃនេះ ចំពោះស្ត្រី និងកុមារក្រីក្រ។

កំណត់សម្គាល់៖ នីតិវិធី ដែលមិនចាំបាច់បង់ថវិកា នៅពេលធ្វើកោសលវិច័យគឺ៖

១. នគរបាលជាអ្នកស្នើសុំធ្វើកោសលវិច័យ។

២. មេធាវីជាអ្នកស្នើសុំទៅតុលាការ។

៣. តុលាការជាអ្នកបញ្ជាឱ្យចេញលិខិតកោសលវិច័យ ដោយមិនបង់ប្រាក់។

សូមជូនភ្ជាប់នូវទម្រង់ឯកសារពិនិត្យការរំលោភផ្លូវភេទឧបសម្ព័ន្ធទី ៦។

### កំណត់ហេតុ

មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើការស៊ើបអង្កេត ត្រូវតែបញ្ជូនកំណត់ហេតុ និងភស្តុតាងទាំងអស់ ទៅកាន់ព្រះរាជអាជ្ញា។

## ៤. ការសម្រេចរបស់ព្រះរាជអាជ្ញា

ក្រោយពេលទទួលបានពាក្យប្តឹង ព្រះរាជអាជ្ញាមានពេលពីរខែ ដើម្បីធ្វើការសម្រេចថាតើត្រូវចាត់ការលើពាក្យប្តឹងនេះ ឬក៏តម្កល់រឿងទុកឥតចាត់ការ (*មាត្រា ៤០ និងមាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ប្រសិនបើមានការស៊ើបអង្កេតបឋមនោះ ការសម្រេចនេះ គួរតែធ្វើឡើងដោយផ្អែកតាមលទ្ធផលនៃការស៊ើបអង្កេតបឋមនេះ។

រូបភាពទី ៧ - ការសម្រេចរបស់ព្រះរាជអាជ្ញា



> នៅក្នុងករណីដែលព្រះរាជអាជ្ញា សម្រេចតម្កល់ពាក្យប្ដឹងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់ជនរងគ្រោះ។ ប្រសិនបើជនរងគ្រោះមិនសុខចិត្ត ជនរងគ្រោះអាចប្ដឹងតវ៉ាទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ នៅរាជធានីភ្នំពេញបាននៅក្នុងរយៈពេលពីរខែ (*មាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

រូបភាពទី ៨ - ការប្ដឹងតវ៉ាទៅលើសេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញា




បើយោងតាមមាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ បានឱ្យដឹងថា ការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា ត្រូវមានសំអាងច្បាប់ និងសំអាងហេតុ ហើយការតម្កល់រឿងទុកឥតចាត់ការនេះ គ្មានអាជ្ញាអស់ជំនុំទេ។

ព្រះរាជអាជ្ញាអាចមានមូលហេតុ ដូចខាងក្រោមនេះ៖

- អង្គហេតុរបស់សំណុំរឿង ពុំមានអ្វីពាក់ព័ន្ធជាមួយនឹងសំណុំរឿងព្រហ្មទណ្ឌ ឬពុំមានភស្តុតាងគ្រប់គ្រាន់ ដើម្បីបង្ហាញអំពីបទល្មើស ឬ
- បណ្ដឹងអាជ្ញាត្រូវបានផុតរលត់ ឬ
- អង្គហេតុ ដែលបញ្ជាក់អំពីសំណុំរឿងព្រហ្មទណ្ឌ ជាបទលហុ ហើយដើម្បីជាប្រយោជន៍សាធារណៈ គេគួរតែសន្សំសំចៃធនធានសាធារណៈ ដើម្បីទុកធ្វើការចោទប្រកាន់លើបទល្មើស ដែលមានលក្ខណៈធ្ងន់ធ្ងរជាងនេះវិញ។

ឧទាហរណ៍៖ *នៅក្នុងការឈ្លោះប្រកែកគ្នាមួយ លោក សុកក្តិបានទះកំផ្លៀង នាង មករា ដែលជាអ្នកជិតខាងរបស់ខ្លួន ដែលមិនបណ្តាលឱ្យមានរបួសទេ។ ករណីនេះ ព្រះរាជអាជ្ញា មិនធ្វើការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌឡើយ ដោយសារតែ៖*

- *នេះ គឺជាបទលហុ (មាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ ដែលបានចូលជាធរមាន នៅចុងឆ្នាំ ២០១០)*
- *លោក សុកក្តិ មិនដែលប្រព្រឹត្តបទល្មើសពីមុនមក ហើយ*
- *នាង មករា សុខចិត្តបំភ្លេចចោលនូវអ្វីៗដែលកើតឡើង ប្រសិនបើ លោក សុកក្តិ សុំទោសនាង។*

នៅក្នុងករណីដែលព្រះរាជអាជ្ញា សម្រេចចាត់ការលើពាក្យប្តឹងនេះ ការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ អាចធ្វើឡើងតាមរយៈ៖

- ការបើកស៊ើបសួរ ក្រោយពីបានចេញដីកាបញ្ជូនសំណុំរឿង ទៅកាន់ចៅក្រមស៊ើបសួរ (*មាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*) ឬ
- ការចេញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់៖ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាដីកា ដែលចេញឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួនក្នុងការជំនុំជម្រះ នៅមុខតុលាការ មិនឱ្យហួសពីចំនួនថ្ងៃណាមួយ (*មាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*) ឬ
- ដីកាកោះហៅឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួនភ្លាម នៅក្នុងការជំនុំជម្រះ ជាធម្មតា នៅថ្ងៃដដែលក្នុងករណី (*មាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)
  - បទល្មើសនេះ គឺជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ហើយ
  - បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិចបំផុត ១ ឆ្នាំ និងយ៉ាងយូរបំផុត ៥ ឆ្នាំ ហើយ
  - ជនជាប់ចោទ គឺជានីតិជន
  - រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមនឹងជំនុំជម្រះបាន។

ដំណើរការនៃការចាប់ផ្តើមនីតិវិធីព្រហ្មទណ្ឌ គឺអាស្រ័យទៅតាមប្រភេទនៃបទល្មើស។

រូបភាពទី ៩ - ការផ្តួចផ្តើមនីតិវិធីព្រហ្មទណ្ឌ




ការអនុញ្ញាតឱ្យចាប់ខ្លួន ត្រូវបានចៅក្រមស៊ើបសួរផ្តល់ទៅព្រះរាជអាជ្ញា។

ក្រោយពេលបញ្ចប់ការចាប់ខ្លួន បុគ្គលដែលត្រូវបានចាប់ខ្លួន អមដោយមន្ត្រីសន្តិសុខ ត្រូវនាំទៅបង្ហាញខ្លួននៅមុខព្រះរាជអាជ្ញា។ ក្រោយពេលពិនិត្យលើអត្តសញ្ញាណរបស់ជននោះរួចហើយ ព្រះរាជអាជ្ញាត្រូវឱ្យជននោះបានដឹងអំពីបទចោទប្រកាន់ ខ្លឹមសារច្បាប់ និងបទល្មើស ដែលត្រូវទទួលរងការចោទប្រកាន់។ ក្រោមវិធានការនេះ បុគ្គលនេះ ត្រូវនាំខ្លួនទៅជំនុំជម្រះនៅថ្ងៃតែមួយក្នុងសាលាដំបូង ហើយបុគ្គលនេះ ត្រូវគេប្រាប់ឱ្យដឹងថា គាត់មានសិទ្ធិជ្រើសរើសមេធាវី។

## ៥. ការស៊ើបសួរ

រូបភាពទី ១០ - ការស៊ើបសួរ



ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវបានធ្វើឡើងសេចក្តីព្រាងដោយព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ។ ការស៊ើបសួរ ត្រូវតែធ្វើឡើងសម្រាប់បទឧក្រិដ្ឋ និងជាជម្រើសសម្រាប់បទមជ្ឈិម។

ក្រោយពេលដែលចៅក្រមស៊ើបសួរ បានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញារួចមក ចៅក្រមស៊ើបសួរអាចសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យនូវបុគ្គល ដែលមានចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះ (*មាត្រា ១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ បន្ទាប់មក ជនសង្ស័យក្លាយជា "*ជនត្រូវចោទ*"។ ការស៊ើបសួរ ត្រូវដឹកនាំដោយចៅក្រមស៊ើបសួរ។

**ការស៊ើបអង្កេត លើភស្តុតាង**

ចៅក្រមស៊ើបសួរ ត្រូវប្រមូលភស្តុតាងទាំងអស់ ដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿងនេះ (*មាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ នេះមានន័យថា មិនត្រឹមតែភស្តុតាងដែលបង្ហាញថា ជនត្រូវចោទបានប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះទេ ក៏ប៉ុន្តែភស្តុតាងដែលបង្ហាញថា ជននោះមិនបានប្រព្រឹត្តបទល្មើសនេះផងដែរ។ នេះគឺដោយសារតែចៅក្រមស៊ើបសួរ គឺជាចៅក្រម ហើយត្រូវមានភាពសត្យានុម័ត ដូចគ្នានឹងចៅក្រមជំនុំជម្រះ ដែលត្រូវមានភាពសត្យានុម័តផងដែរ។

**ការស្តាប់ចម្លើយ របស់ជនត្រូវចោទ សាក្សី ជនរងគ្រោះ និងការពិគ្រោះ ជាមួយអ្នកជំនាញ**

ចៅក្រមស៊ើបសួរ ត្រូវប្រាប់ជនត្រូវចោទឱ្យបានដឹងអំពីរឿងរ៉ាវនៃការចោទប្រកាន់ និងឱ្យដឹងអំពីសិទ្ធិមិនឆ្លើយ រហូតដល់មានមេធាវី។ ចៅក្រមស៊ើបសួរ ក៏ត្រូវប្រាប់ជនត្រូវចោទឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនផងដែរ ក្នុងការជ្រើសរើសមេធាវី ឬការសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី (*មាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ (*មាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ក៏អាចស្នើសុំឱ្យចៅក្រមស៊ើបសួរ ធ្វើការសួរចម្លើយខ្លួន និងអ្នកដទៃទៀតផងដែរ (*មាត្រា ១៣៣ និងមាត្រា ១៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាន ដែលជាគោលការណ៍ ការឆែកឆេរត្រូវធ្វើឡើង នៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬប្រើប្រាស់ទីកន្លែង ដូចជា សម្រាប់ការប្រកបអាជីវកម្មជាដើម។ ជាគោលការណ៍ ការឆែកឆេរត្រូវធ្វើឡើងចន្លោះពីម៉ោង ៦ ព្រឹក ដល់ម៉ោង ៦ ល្ងាច (*មាត្រា ១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*) ហើយវត្ថុតាងនានា ដែលអាចយកមកប្រើជាភស្តុតាងបាន ត្រូវមានបិទស្លាកបោះត្រា (*មាត្រា ១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យមានការធ្វើកោសលវិច័យ (*មាត្រា ១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ឧទាហរណ៍៖ *ចៅក្រមស៊ើបសួរ មានភាពមន្ទិលលើស្លាកស្នាមនៃការវាយដំរបស់ប្តី នៅក្នុងរឿងក្តីអំពើហិង្សាក្នុងគ្រួសារ។ ចៅក្រមស៊ើបសួរ បានស្នើសុំឱ្យវេជ្ជបណ្ឌិតធ្វើកោសលវិច័យទៅលើជនរងគ្រោះបន្ថែមទៀត។*

ឧទាហរណ៍៖ *ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យមានការធ្វើតេស្តលើ DNA ដើម្បីពិនិត្យមើលថាតើទឹកកាមនេះ ពិតជាទឹកកាមរបស់ជនសង្ស័យ ក្នុងករណីរំលោភសេពសន្ថវៈមែនដែរឬទេ។*

ឧទាហរណ៍៖ *ព្រះរាជអាជ្ញាឱ្យអ្នកជំនាញផ្នែកអក្សរ ធ្វើការពិនិត្យថាតើលិខិតសរសេរដោយដៃ មុនពេលធ្វើអត្តឃាតនេះ ពិតជាលិខិត ដែលសរសេរដោយលោកស្រី រុំឡី មែនដែរឬទេ ដើម្បីធានាថា នេះគឺជាករណីអត្តឃាត មិនមែនករណីឃាតកម្មនោះទេ។*

ប្រសិនបើចៅក្រមស៊ើបសួរ ចាត់ទុកថាការស៊ើបសួរបានបញ្ចប់រួចរាល់ហើយ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ពួកគេ។ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ។

ក្នុងរយៈពេល ១៥ ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវបានឃុំខ្លួន និង ១ ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាបង្វិលសំណុំរឿងទៅឱ្យចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរ ភ្ជាប់មកជាមួយផង។ នៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះ ព្រះរាជអាជ្ញាអាច

សុំឱ្យចៅក្រមស៊ើបសួរ សម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងចោទប្រកាន់ (*មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ចៅក្រមស៊ើបសួរធ្វើការសម្រេចចុងក្រោយ តាមរយៈដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយ អាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់។ ចៅក្រមស៊ើបសួរ មិនត្រូវជាប់កាតព្វកិច្ចគោរព តាមដីកាសន្និដ្ឋានស្ថាពរ/ការយល់ឃើញរបស់ព្រះរាជអាជ្ញាទេ (*មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ចៅក្រមស៊ើបសួរ ត្រូវចេញដីកាលើកលែងការចោទប្រកាន់ នៅក្នុងករណីដូចតទៅ៖

១. អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ

២. ជនដែលប្រព្រឹត្តអំពើនោះ នៅតែគេមិនស្គាល់

៣. គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។

ដីកាដំណោះស្រាយ ត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុត ដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី (*មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

បន្ទាប់ពីទទួលរងការចោទប្រកាន់ ជនត្រូវចោទក្លាយជា "*ជនជាប់ចោទ*" ។

រូបភាពទី ១១៖ ដីកាដំណោះស្រាយ គឺជាការសម្រេចចុងក្រោយរបស់ចៅក្រមស៊ើបសួរ



# ករណីបទល្មើសជាក់ស្តែង

បទល្មើសមួយ គឺជាបទល្មើសជាក់ស្តែង ប្រសិនបើជនជាប់ចោទត្រូវបានចាប់ខ្លួន នៅក្នុងពេលកំពុងប្រព្រឹត្តបទល្មើស និងត្រូវបានឃាត់ខ្លួននៅក្នុងពេលប្រព្រឹត្តបទល្មើស ឬភ្លាមៗក្រោយពេលប្រព្រឹត្តបទល្មើស។ បទល្មើសមួយ ក៏ជាបទល្មើសជាក់ស្តែងផងដែរ កាលណានៅក្រោយពេលមានបទមជ្ឈិម ឬបទឧក្រិដ្ឋរួចបន្តិចមក ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រផាប់ចាប់ប្រកីង ឬបុគ្គលដែលត្រូវគេរកឃើញថាមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើសនោះ។

គ្រប់បុគ្គលទាំងអស់ អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ ដែលនៅជិតបំផុត។



ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា (*មាត្រា ៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះទៅកាន់ទៅទីកន្លែងកើតហេតុ ដើម្បីធ្វើការត្រួតពិនិត្យបទល្មើស ដកហូតវត្ថុតាងសម្រាប់ធ្វើជាភស្តុតាង ហើយអាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅណាឆ្ងាយពីទីកន្លែងបទល្មើសរហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន។

មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរ នៅពេលណាក៏បាន (*និងអាចមុនម៉ោង ៦.០០ ព្រឹក និងក្រោយម៉ោង ៦.០០ ល្ងាចក៏បាន*) ក្នុងករណីដែល៖

- ការឆែកឆេរត្រូវធ្វើឡើង ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង
- ការឆែកឆេរត្រូវធ្វើឡើង ក្នុងករណីចាត់ទុកដូចបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង៖
    - មានសម្រែកស្រែកឱ្យគេជួយពីក្នុងទីកន្លែង
    - ការឆែកឆេរត្រូវធ្វើឡើង នៅទីកន្លែង ដែលបើកចំហដល់សាធារណជន
    - ការឆែកឆេរត្រូវធ្វើឡើង នៅទីកន្លែង ដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន (*មាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

## ការឃុំខ្លួនបណ្តោះអាសន្ន

ជាគោលការណ៍ ជនត្រូវចោទនៅតែមានសេរីភាព មុនពេលមានការចាប់ផ្តើមជំនុំជម្រះ (*មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់ដោយចៅក្រមស៊ើបសួរ សម្រាប់រយៈពេលណាមួយ ចាប់គិតពីពេលស៊ើបសួររហូតដល់កាលបរិច្ឆេទជំនុំជម្រះ ដើម្បីផ្តល់លទ្ធភាពឱ្យមានការស៊ើបសួរឱ្យបានត្រឹមត្រូវ រាំងមិនឱ្យជនសង្ស័យលាក់ខ្លួនពីសំណាញ់ច្បាប់ និងបង្ការបទល្មើសកុំឱ្យកើតជាថ្មី ការពារសន្តិសុខឱ្យជនត្រូវចោទ និងធានារក្សាសណ្តាប់ធ្នាប់សាធារណៈ (*មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ លក្ខខណ្ឌ សម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន (*មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*) រួមមាន៖

- ជនជាប់ចោទ នៅក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិម
- ច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពីមួយឆ្នាំ។

### តារាងទី ១៖ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

| អាយុ | បទឧក្រិដ្ឋ | បទមជ្ឈិម |
|---|---|---|
| នីតិជន | ៦ ខែ + (៦ x ២) | ៤ ខែ ឬពាក់កណ្ដាលអប្បបរមានៃទោស + (២ x ១) |
| ១៦-១៧ ឆ្នាំ | ៦ ខែ | ៤ ខែ ឬពាក់កណ្ដាលអប្បបរមានៃទោស |
| ១៤-១៥ ឆ្នាំ | ៤ ខែ | ២ ខែ ឬពាក់កណ្ដាលអប្បបរមានៃទោស |
| ក្រោម ១៤ ឆ្នាំ | ០ | ០ |

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន សម្រាប់បទមជ្ឈិម ដែលប្រព្រឹត្តដោយជនអាយុក្រោម ១៨ ឆ្នាំ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោស ដែលច្បាប់បានកំណត់ឡើយ (*មាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

អនីតិជនអាយុក្រោម ១៤ ឆ្នាំ មិនអាចត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន។ ចៅក្រមស៊ើបសួរអាចសម្រេចបញ្ជូនអនីតិជន ទៅឱ្យអាណាព្យាបាលរបស់សាមីខ្លួនបណ្ដោះអាសន្ន ឬទៅកាន់មណ្ឌលអប់រំ និងគាំពារបណ្ដោះអាសន្ន ប្រសិនបើពុំមានអាណាព្យាបាល រហូតដល់ពេលដែលចៅក្រមមានសមត្ថកិច្ច ធ្វើការសម្រេចអំពីបញ្ហានេះ។

ព្រះរាជអាជ្ញា និងជនត្រូវចោទ អាចសុំឱ្យចៅក្រមស៊ើបសួរដោះលែងពីការឃុំខ្លួនបណ្ដោះអាសន្ន។ ចៅក្រមស៊ើបសួរ ត្រូវសម្រេចអំពីការដោះលែងនេះ។

ប្រសិនបើចៅក្រមស៊ើបសួរ បដិសេធចំពោះការសុំនេះ ព្រះរាជអាជ្ញា និង/ឬជនត្រូវចោទ អាចតវ៉ាទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ (*មាត្រា ២១៦ និងមាត្រា ២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ក្រោយពេលដែលដីកាដំណោះស្រាយ ត្រូវបានចេញដោយចៅក្រមស៊ើបសួរ ការឃុំខ្លួនបណ្ដោះអាសន្នត្រូវបញ្ចប់ លុះត្រាតែចៅក្រមស៊ើបសួរចេញការសម្រេចដោយឡែក ដើម្បីបន្តឃុំខ្លួនជនត្រូវចោទ។ សេចក្ដីសម្រេចរក្សាទុកជនត្រូវចោទក្នុងការឃុំខ្លួនបណ្ដោះអាសន្នលែងមានអានុភាពក្នុងរយៈពេលបួនខែ។ ប្រសិនបើជនត្រូវចោទមិនត្រូវបានកោះឱ្យចូលទៅបង្ហាញខ្លួន នៅមុខតុលាការ ក្នុងរយៈពេលបួនខែនោះទេ ជនត្រូវចោទនោះត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នដោយឯកឯង (*មាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

# ៦. ការជំនុំជម្រះ

ការជំនុំជម្រះ ត្រូវបានផ្តើមតាមរយៈ៖

ក) សេចក្តីសម្រេចចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ឬ

ខ) ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះ ដែលចេញដោយព្រះរាជអាជ្ញា (*មាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*) ឬ

គ) ដីកាបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាម នៅក្នុងការជំនុំជម្រះដែលជាធម្មតា នៅក្នុងថ្ងៃតែមួយ (*មាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*) ។

រូបភាពទី ១២ - ការផ្តើមការជំនុំជម្រះ ត្រូវធ្វើឡើងដោយចៅក្រមស៊ើបសួរ តាម ៣ ផ្លូវផ្សេងគ្នា អាស្រ័យទៅតាមបទល្មើស៖



ប្រធានតុលាការ កំណត់កាលបរិច្ឆេទសម្រាប់សវនាការ។ ចៅក្រមជំនុំជម្រះ មិនអាចជាចៅក្រមដដែល ដែលបានធ្វើការស៊ើបសួរ នៅក្នុងសំណុំរឿងដដែលនោះទេ (*មាត្រា ២៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

> កាលបរិច្ឆេទនៃការជំនុំជម្រះ ត្រូវជូនដំណឹងដោយផ្ទាល់មាត់ដល់ព្រះរាជអាជ្ញា (*មាត្រា ២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះផ្សេងទៀត សាក្សី អ្នកជំនាញ អ្នកបកប្រែ ត្រូវបានព្រះរាជអាជ្ញាកោះឱ្យបង្ហាញខ្លួនក្នុងសវនាការ (*មាត្រា ២៩៤-២៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ជាគោលការណ៍ ជនជាប់ចោទមានសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ។ ប៉ុន្តែតុលាការអាចលើកលែងមិនឱ្យមានការជំនុំជម្រះជាសាធារណៈបាន (*មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ សម្រាប់គ្រប់ការជំនុំជម្រះទាំងអស់ សាលក្រមត្រូវតែប្រកាសជាសាធារណៈ (*មាត្រា ៣១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

## ការចំណាយទៅលើការជំនុំជម្រះ

> នៅក្នុងការជំនុំជម្រះបទព្រហ្មទណ្ឌ ជនជាប់ចោទ និងជនរងគ្រោះ មិនមានករណីកិច្ចបង់ប្រាក់ប្រដាប់ក្តីនោះទេ។ ប៉ុន្តែ ប្រសិនបើជនរងគ្រោះដាក់ពាក្យបណ្តឹងទាមទារសំណងរដ្ឋប្បវេណី តែមួយមិនមានភ្ជាប់មកជាមួយបណ្តឹងអាជ្ញា នោះជនរងគ្រោះត្រូវបង់ប្រាក់ប្រដាប់ក្តី ហើយចៅក្រមស៊ើបសួរ ក៏អាចបញ្ជាឱ្យដើមបណ្តឹងរដ្ឋប្បវេណីបង់ប្រាក់តម្កល់ទុក (*មាត្រា ១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ប៉ុន្តែ ចៅក្រមស៊ើបសួរ អាចមិនឱ្យជនរងគ្រោះបង់ប្រាក់តម្កល់ទុកនេះ នៅក្នុងករណីដែលជនរងគ្រោះជាជនក្រីក្រ។

តារាងទី ២ - ប្រាក់ប្រដាប់ក្តី នៅក្នុងនីតិវិធីរដ្ឋប្បវេណី ឬបណ្តឹងទាមទារសំណងរដ្ឋប្បវេណី នៅក្នុងនីតិវិធីព្រហ្មទណ្ឌ

| តម្លៃរបស់វិវាទ | ប្រាក់ប្រដាប់ក្តី |
|---|---|
| រហូតដល់ ១០.០០០.០០០ រៀល (២.៥០០ ដុល្លារ) | ១% |
| ១០.០០០.០០០ រៀល (២.៥០០ ដុល្លារ) - ១០០.០០០.០០០ រៀល (២៥.០០០ ដុល្លារ) | ០,៧% |
| ១០០.០០០.០០០ រៀល (២៥.០០០ ដុល្លារ) - ១.០០០.០០០.០០០ រៀល (២៥០.០០០ ដុល្លារ) | ០,៣% |
| លើសពី ១.០០០.០០០.០០០ រៀល (២៥០.០០០ ដុល្លារ) | ០,១% |

នៅក្នុងករណី ដែលគេមានការពិបាក នៅក្នុងការកំណត់អំពីតម្លៃរបស់វិវាទ តុលាការត្រូវកំណត់អំពីតម្លៃនៃបណ្តឹង ដោយឆន្ទានុសិទ្ធិរបស់ខ្លួន។ នៅក្នុងករណី ដែលគេមិនអាចកំណត់អំពីតម្លៃរបស់បណ្តឹងមួយបាន នោះតម្លៃរបស់បណ្តឹងនេះត្រូវស្មើនឹង ៥.៥០០.០០០ រៀល។

សម្រាប់បណ្តឹងទាមទារសំណងរដ្ឋប្បវេណី នៅក្នុងនីតិវិធីព្រហ្មទណ្ឌ ជាធម្មតា តុលាការគិតថ្លៃ ១៣,៧៥ ដុល្លារ (*៥៥.០០០ រៀល = ១% នៃ ៥.៥០០.០០០ រៀល*) សម្រាប់មេធាវីស្ម័គ្រចិត្ត ដែលតំណាងឱ្យប្រជាពលរដ្ឋក្រីក្រ។

## អ្នកដែលមានវត្តមាននៅក្នុងសវនាការ

- ចៅក្រមជំនុំជម្រះ (ចៅក្រម ៣ រូប សម្រាប់បទឧក្រិដ្ឋ) (*មាត្រា ២៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)
- ព្រះរាជអាជ្ញា (រង)
- ក្រឡាបញ្ជី ដែលជួយដល់ចៅក្រម និងធ្វើកំណត់ហេតុ
- ជនជាប់ចោទ
- មេធាវីរបស់ជនជាប់ចោទ ត្រូវតែមានវត្តមាន នៅក្នុងកំឡុងពេលជំនុំជម្រះលើសំណុំរឿងបទឧក្រិដ្ឋ និងនៅក្នុងករណីដែលជនជាប់ចោទជាអនីតិជន។ សម្រាប់ការជំនុំជម្រះលើបទមជ្ឈិម និងបទលហុ វត្តមានរបស់មេធាវីមិនជាការចាំបាច់នោះទេ។ នៅក្នុងករណីដែលជនជាប់ចោទមិនបង្ហាញខ្លួន ការជំនុំជម្រះ អាចធ្វើឡើងដោយកំបាំង

មុខ មានន័យថា តុលាការនឹងបន្តធ្វើការជំនុំជម្រះ បើទោះបីជាជនជាប់ចោទអវត្តមានក៏ដោយ ( *មាត្រា ៣៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

- ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ខ្លួន ( *មាត្រា ៣១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។
- សាក្សី និងអ្នកជំនាញ។ *មាត្រា ៣១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧* តម្រូវឱ្យសាក្សីបង្ហាញខ្លួន ចំពោះមុខតុលាការ នៅពេលដែលពួកគេត្រូវបានកោះហៅ។ មានច្បាប់តិចតួច ដែលការពារសាក្សី នៅក្នុងប្រទេសកម្ពុជា។ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន អាចជាការការពារសាក្សី ( *មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧*)។

## ជំហាននៃការជំនុំជម្រះ

### ១. ការផ្ទៀងផ្ទាត់អត្តសញ្ញាណ និងការសាកសួរជនជាប់ចោទ និងភាគីបណ្តឹង

នៅពេលដែលសវនាការចាប់ផ្តើម ក្រឡាបញ្ជីហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹង រដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់មើលអត្តសញ្ញាណជនទាំងនោះ។ កាលណាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតំណាង ឬ មានមេធាវី ក្រឡាបញ្ជីត្រូវពិនិត្យមើលអត្តសញ្ញាណនៃអ្នកតំណាងទាំងនោះ និងសុពលភាពនៃការប្រគល់សិទ្ធិ។

នៅពេលបើកការពិភាក្សាដេញដោល ភាគីអាចសុំឱ្យតុលាការស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គល ដែលមានវត្តមាននៅក្នុងបន្ទប់សវនាការ ប៉ុន្តែ មិនបានកោះហៅឱ្យបានត្រឹមត្រូវទេ។ ការស្តាប់ចម្លើយសាក្សីនេះ ត្រូវមានការយល់ព្រមពីប្រធានសវនាការ។ គ្រប់ភាគីទាំងអស់ អាចជំទាស់នឹងការស្តាប់ចម្លើយសាក្សី ដែលខ្លួនយល់ឃើញថា ចម្លើយនេះគ្មានប្រយោជន៍អ្វីដល់ការសម្តែងឱ្យឃើញការពិត។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចដោយឥស្សរចិត្តថាតើត្រូវស្តាប់ ឬមិនស្តាប់ចម្លើយសាក្សីនេះ ( *មាត្រា ៣២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

### ២. សាក្សី និងអ្នកជំនាញថយខ្លួនទៅក្រៅបន្ទប់សវនាការ

អ្នកជំនាញ និងសាក្សីថយខ្លួនទៅនៅក្នុងបន្ទប់រង់ចាំ ដែលទុកបម្រុងឱ្យខ្លួន ហើយដែលពីក្នុងបន្ទប់រង់ចាំនោះ ខ្លួនមិនអាចមើលឃើញ ឬស្តាប់ឮអ្វីដែលប្រព្រឹត្តទៅនៅក្នុងបន្ទប់សវនាការទេ ( *មាត្រា ៣២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

៣. ការអានបទចោទ

មុនពេលចាប់ផ្ដើមសួរចម្លើយ ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទ ឱ្យបានដឹងអំពីអំពើដែលគេចោទប្រកាន់មកលើខ្លួន។

៤. ការប្រមូលភស្តុតាង

ប្រធានសវនាការស្តាប់ចម្លើយរបស់ជនជាប់ចោទ ហើយសួរគ្រប់សំណួរ ដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការសម្ដែងឱ្យឃើញការពិត (*មាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ក្រោយពីចៅក្រមសួរចម្លើយរួច ហើយព្រះរាជអាជ្ញា មេធាវី និង ភាគីត្រូវបានអនុញ្ញាតឱ្យលើកសំណួរសួរដល់ជនជាប់ចោទ។ គ្រប់ការលើកសំណួរទាំងអស់ ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ។ ក្រៅពីសំណួររបស់ព្រះរាជអាជ្ញា និងមេធាវី សំណួរផ្សេងៗទៀតត្រូវសួរតាមរយៈប្រធានសវនាការ ដូចជាសំណួររបស់ជនរងគ្រោះ ចំពោះជនជាប់ចោទជាដើម។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេច ដោយឥស្សរចិត្តថា តើសំណួរនេះត្រូវតែសួរដែរឬទេ។

បន្ទាប់មក ប្រធានសវនាការអាចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ដែលបានចូលរួមក្នុងការស៊ើបអង្កេតក្នុងឋានៈជាសាក្សី (*មាត្រា ៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ព្រះរាជអាជ្ញា មេធាវី និងភាគីផ្សេងទៀត អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរសួរទៅកាន់ភាគីនីមួយៗដែលផ្ដល់ចម្លើយ (*មាត្រា ៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ វត្ថុតាងអាចត្រូវបានបង្ហាញ និងប្រើជាភស្តុតាងនៅក្នុងសវនាការ (*មាត្រា ៣៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

កំណត់សម្គាល់៖ គ្រប់សាក្សីទាំងអស់ត្រូវស្បថថា ខ្លួននិយាយតែការពិតស្របតាមជំនឿ ឬសាសនារបស់ខ្លួន លើកលែងតែសាក្សី ដែលជាប់សាច់ញាតិគ្រួសារ និងកុមារអាយុក្រោម ១៤ ឆ្នាំ (*មាត្រា ៣២៨ និងមាត្រា ១៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

## សេចក្ដីសន្និដ្ឋាន

ក្រោយពេលបញ្ចប់ការពិភាក្សាដេញដោល ប្រធានសវនាការបើកឱ្យជនទាំងឡាយ ដូចខាងក្រោមនេះ និយាយជាបន្តបន្ទាប់គ្នា៖

- ❖ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់ខ្លីៗ
- ❖ មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីធ្វើសេចក្ដីសន្និដ្ឋានការពារ
- ❖ ព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ
- ❖ មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងបន្ទាប់មក មេធាវីរបស់ជនជាប់ចោទ ដើម្បីធ្វើសេចក្ដីសន្និដ្ឋានការពារ។

ដើមបណ្ដឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញា អាចឆ្លើយតបទៅវិញបាន។ ប៉ុន្តែ ជនជាប់ចោទ និងមេធាវីរបស់ខ្លួន ត្រូវនិយាយក្រោយគេបង្អស់ជានិច្ច (*មាត្រា ៣៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

> កំណត់សម្គាល់៖ រហូតទល់នឹងការបិទការពិភាក្សាដេញដោល ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ដល់ការសម្ដែងឱ្យឃើញការពិត (*មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

## ការពិនិត្យលើភស្តុតាង

ចៅក្រមជំនុំជម្រះ ត្រូវសំអាងនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ទៅលើភស្តុតាង ដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវបានគេយកមកបង្ហាញ នៅពេលសវនាការតែប៉ុណ្ណោះ។ ការសារភាព ក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយ ដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្ត គ្មានតម្លៃជាភស្តុតាងទេ។ ការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួន មិនអាចយកមកធ្វើជាភស្តុតាងបានឡើយ (*មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ប្រសិនបើការពិភាក្សាដេញដោល មិនបានបញ្ចប់នៅក្នុងពេលសវនាការនោះទេ តុលាការអាចបន្តនៅពេលសវនាការក្រោយ តាមកាលបរិច្ឆេទដែលខ្លួនកំណត់ (*មាត្រា ៣៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

## ការពិភាក្សារបស់តុលាការ

នៅពេលបញ្ចប់ការពិភាក្សាដេញដោល ចៅក្រមជំនុំជម្រះនឹងធ្វើការប្រកាសសាលក្រម ឬជូនដំណឹងដល់ភាគីអំពីកាលបរិច្ឆេទនៃការប្រកាសសាលក្រម។ ប៉ុន្តែ ប្រសិនបើចៅក្រមជំនុំជម្រះជឿថា សំណុំរឿងនេះមិនទាន់អាច ប្រកាសសាលក្រម នៅពេលបញ្ចប់ការពិភាក្សាដេញដោលបាន ចៅក្រមអាចធ្វើការស៊ើបសួរបន្តទៀត ទៅតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ ដូចជា ការស្តាប់ចម្លើយសាក្សី ដែលមិនបានទទួលកន្លងមកជាដើម។

ចៅក្រមជំនុំជម្រះអាចចេញសាលក្រមរបៀប ដើម្បីឱ្យមានការស៊ើបសួរបន្ថែម ដល់ចៅក្រមជាក់លាក់ណាមួយ។

## សាលក្រម

សេចក្តីសម្រេចចុងក្រោយតុលាការជាន់ដំបូង ហៅថា "*សាលក្រម*"។ សាលក្រមមាន ៣ ប្រភេទ នៅតុលាការជាន់ដំបូង ដូចជា៖

សាលក្រមចំពោះមុខ៖ នៅពេលដែលជនជាប់ចោទចូលបង្ហាញខ្លួន ក្នុងសវនាការ (*មាត្រា ៣០៩ និងមាត្រា ៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)

សាលក្រមត្រូវចាត់ទុកថាជាសាលក្រមចំពោះមុខ ប្រសិនបើជនជាប់ចោទ បានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីការកោះហៅហើយ (*មាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)

សាលក្រមកំបាំងមុខ (*មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

គ្រប់សាលក្រម ដែលចេញដោយតុលាការ ត្រូវចូលជាធរមាន តាមរយៈការប្រកាសសាលក្រមនោះជាសាធារណៈ (*មាត្រា ៣១៧ និងមាត្រា ៣៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

## ទោស

តុលាការប្រកាសទោស ដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើស្ថានភាពផ្លូវចិត្ត ទៅលើធនធាន និងបន្ទុកទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើសជាអាទិ៍ ចំពោះជនរងគ្រោះ។ នេះ ហៅថាគោលការណ៍នៃទោស (*មាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌដែលបានចូលជាធរមាននៅចុងឆ្នាំ ២០១០*)។ ក្រមព្រហ្មទណ្ឌបែងចែកទោសជា ៣ ប្រភេទគឺ៖



១. មូលទោស

មូលទោសចែកចេញជាពីរប្រភេទ គឺ៖ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់រៀល (*មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌ ដែលចូលជាធរមាននៅចុងឆ្នាំ ២០១០*)។ តុលាការអាចផ្តន្ទាទោស ដូចខាងក្រោម (*មាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ដែលចូលជាធរមាននៅចុងឆ្នាំ ២០១០*)៖

- ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ
- ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ
- ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ។

ប្រាក់ពិន័យ ដែលទទួលបានត្រូវបង់ចូលរដ្ឋ (*ចូលថវិការដ្ឋ សូមមើលមាត្រា ៥២ នៃក្រមព្រហ្មទណ្ឌ ដែលចូលជាធរមាននៅចុងឆ្នាំ ២០១០*)។

២. ទោសជំនួស *(មាត្រា ៧២-៧៥ នៃក្រមព្រហ្មទណ្ឌ ដែលចូលជាធរមាននៅចុងឆ្នាំ ២០១០)*

ទោសជំនួស រួមមានការងារសហគមន៍ និងការស្តីបន្ទោស។ តុលាការអាចប្រកាសទោសការងារសហគមន៍ដើម្បីជំនួសមូលទោសបាន។កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារតិចជាង ឬស្មើ ៣ ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍ ជាទោសជំនួសវិញ។ ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញ ក្នុងចិរវេលាចន្លោះពី ៣០ ដល់ ២០០ ម៉ោង ជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។ ការងារសហគមន៍ ត្រូវគ្រប់គ្រងដោយបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ដូចជា ការងារវេនពេលយប់ អនាម័យ សន្តិសុខ និងការងារស្ត្រី ជាដើម។ ការងារសហគមន៍ អាចធ្វើឡើងត្រួតគ្នាជាមួយនឹងសកម្មភាពវិជ្ជាជីវៈមួយបាន។

កាលបើជនជាប់ចោទទទួលរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំងបី ដូចតទៅ៖

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាតត្រូវបានជួសជុលរួចហើយ និង
- ជនជាប់ចោទបានបង្ហាញការជានាក្នុងការចូលទៅរួមរស់ នៅក្នុងសង្គមវិញ។

ឧទាហរណ៍៖ *លោក វីរៈបង្ហាញកេរភេទរបស់ខ្លួន ទៅឱ្យក្មេងស្រី ២ នាក់ នៅក្នុងថ្នាក់រៀនរបស់ខ្លួន។ តុលាការអាចសម្រេចដាក់ទោសការងារសហគមន៍ ឱ្យបោសសំអាតសាលាឃុំ ១០០ ម៉ោង។ ដូច្នេះ តុលាការ មិនបានផ្តន្ទាទោសមូលទោស ដូចជា ការពិន័យជាប្រាក់ ឬទោសដាក់ពន្ធនាគារ ដល់លោក វីរៈនោះទេ។ លោក វីរៈ សុំអភ័យទោស នៅចំពោះមុខសិស្សក្នុងថ្នាក់ទាំងអស់ ចំពោះបទល្មើសរបស់ខ្លួន យល់អំពីកំហុសរបស់ខ្លួន ហើយសន្យាថានឹងកែប្រែខ្លួន នាពេលអនាគត។*

៣. ទោសបន្ថែម *(មាត្រា ៥៣-៧១ នៃក្រមព្រហ្មទណ្ឌ ដែលចូលជាធរមាននៅចុងឆ្នាំ ២០១០)*

ទោសបន្ថែមនឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែង ដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវចោទប្រកាន់។ ចៅក្រមអាចដាក់បញ្ចូលទោសទាំងនេះ នៅក្នុងសាលក្រម។ ប៉ុន្តែ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើមានច្បាប់ចែងយ៉ាងជាក់លាក់។

ឧទាហរណ៍នៃទោសបន្ថែម៖ *រួមមានការហាមឃាត់ចំពោះការស្នាក់នៅកន្លែងមួយចំនួន ការព្យួរប័ណ្ណបើកបរ ការរឹបអូសទ្រព្យសម្បត្តិ និងការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស។*

# បណ្តឹងឧទ្ធរណ៍

## ភាគីដែលមានសិទ្ធិប្តឹងឧទ្ធរណ៍

នៅក្នុងករណីបទល្មើសព្រហ្មទណ្ឌ គ្រប់ភាគីមានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការមានសមត្ថកិច្ចបាន។ ប៉ុន្តែ សម្រាប់ករណីបណ្តឹងឧទ្ធរណ៍ ច្បាប់ធ្វើការកំណត់ពីជន ដែលអាចប្តឹងឧទ្ធរណ៍បាន។

!

អ្នកដែលអាចប្តឹងឧទ្ធរណ៍បាន ( *មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*) រួមមាន៖

- ជនជាប់ចោទ
- ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

កំណត់សម្គាល់៖ ចំណុចនេះ ក្រសួងកិច្ចការនារី អាចជួយអន្តរាគមន៍ទៅសាលាឧទ្ធរណ៍ នៅក្នុងលក្ខខណ្ឌដូចខាងក្រោមនេះ៖

- ជនរងគ្រោះត្រូវស្នើសុំមកក្រសួងកិច្ចការនារីជាមុនសិន (ពាក្យស្នើសុំ) បន្ទាប់មកក្រសួងកិច្ចការនារីរៀបចំលិខិតឱ្យជនរងគ្រោះ (ជនរងគ្រោះជាអ្នកចុះហត្ថលេខា) ទៅសាលាឧទ្ធរណ៍ តាមរយៈលោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារី។
- ករណីនៅខេត្ត ត្រូវធ្វើតាមរយៈអភិបាលខេត្ត ឬអភិបាលរងខេត្តទៅតុលាការ។ សូមជូនភ្ជាប់នូវគំរូទម្រង់លិខិតស្នើសុំកិច្ចអន្តរាគមន៍ នៅក្នុងឧបសម្ព័ន្ធទី ៨ និងទី ៩។

ឧទាហរណ៍៖ *លោក វិបុល ត្រូវបានចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ។ នៅក្នុងដំណាក់កាលជំនុំជម្រះ ចៅក្រមជំនុំជម្រះបានទម្លាក់ចោលនូវការចោទប្រកាន់នេះ។ ដោយមិនពេញចិត្តចំពោះសេចក្តីសម្រេចនេះ ព្រះរាជអាជ្ញាធ្វើការប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនេះ។ នៅក្នុងករណីដែលលោក វិបុលកំពុងជាប់ឃុំឃាំង គាត់នៅតែត្រូវបន្តជាប់ឃុំឃាំងដោយរង់ចាំសេចក្តីសម្រេចពីសាលាឧទ្ធរណ៍។*

ឧទាហរណ៍៖ *លោក សុធារី ត្រូវបានចៅក្រមជំនុំជម្រះកាត់ទោសដាក់ពន្ធនាគារអស់មួយជីវិត ពីបទរំលោភសេពសន្ថវៈ និងសម្លាប់។ ដោយមិនពេញចិត្តជាមួយនឹងសេចក្តីសម្រេចនេះ លោក សុធារី អាចប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចនេះ ទៅសាលាឧទ្ធរណ៍បាន។*

ឧទាហរណ៍៖ *កញ្ញា បុប្ផា ដាក់ពាក្យប្តឹងលោក រតនៈ ទៅសាលាដំបូងខេត្តកំពង់ស្ពឺ ពីបទប្រទូស្តកេរ្តិ៍ខ្មាស និងទាមទារសំណង ១០ លានរៀល។ នៅក្នុងកំឡុងពេលជំនុំជម្រះ ចៅក្រមជំនុំជម្រះសម្រេចកាត់ទោសលោក រតនៈ ឱ្យជាប់ពន្ធនាគារ ២ ឆ្នាំ និងសងសំណង ១ លានរៀលដល់កញ្ញា បុប្ផា។ ដោយសារតែមិនពេញចិត្តជាមួយនឹងសំណង ដែលសម្រេចដោយតុលាការខេត្តកំពង់ស្ពឺនេះ កញ្ញា បុប្ផា អាចប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរដ្ឋប្បវេណីបាន (សំណងជំងឺចិត្ត)។*

ឧទាហរណ៍៖ *ជនល្មើសឈ្មោះ សគុន្ធា អាយុ ១៣ ឆ្នាំ ចាប់រំលោភ ណារៈ អាយុ ៨ ឆ្នាំ។ ម្តាយណារៈ ដាក់ពាក្យប្តឹងទាមទារសំណង ២០ លានរៀលពីឪពុកជនល្មើស។ នៅក្នុងពេលជំនុំជម្រះ ចៅក្រមសម្រេចថា ឪពុករបស់ជនល្មើសត្រូវបង់សំណង ២០ លានរៀល ទៅឱ្យម្តាយរបស់ណារៈ។ ដោយមិនពេញចិត្តជាមួយនឹងសេចក្តីសម្រេចរបស់ចៅក្រម ឪពុករបស់ជនល្មើស ធ្វើការប្តឹងឧទ្ធរណ៍ចំពោះសំណងរដ្ឋប្បវេណីនេះ។*

## សមត្ថកិច្ចរបស់សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ មានសមត្ថកិច្ចដើម្បីសម្រេចអំពីបណ្ដឹងឧទ្ធរណ៍ ដែលធ្វើឡើងប្រឆាំងនឹងសេចក្ដីសម្រេចរបស់តុលាការជាន់ដំបូង ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួនក្នុងរឿងព្រហ្មទណ្ឌ ( *មាត្រា ៣៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ ដូច្នេះ កាលបើភាគីណាមួយនៃវិវាទ មិនពេញចិត្ត ចំពោះសេចក្ដីសម្រេចរបស់តុលាការជាន់ដំបូង ពួកគេអាចដាក់ពាក្យប្ដឹងទៅកាន់សភាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍បាន។

ឧទាហរណ៍៖ *តារា ដាក់ពាក្យប្ដឹងពីបទជួញដូរផ្លូវភេទលើណារៈ ទៅតុលាការខេត្តបាត់ដំបង ហើយទាមទារសំណង ១០ លានរៀល។ សាលាដំបូងខេត្តបាត់ដំបង បើកសវនាការលើសំណុំរឿងនេះ និងបានចេញសាលក្រមដាក់ទោសណារៈ ក្នុងពន្ធនាគារ ១ ឆ្នាំ និងសងសំណង ១ លានរៀលទៅតារា។ ដោយមិនពេញចិត្តចំពោះសេចក្ដីសម្រេចរបស់សាលាដំបូងខេត្តបាត់ដំបង តារា ប្ដឹងឧទ្ធរណ៍ទៅសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ឱ្យធ្វើសេចក្ដីសម្រេចលើសំណងនេះម្ដងទៀត។*

## រយៈពេលប្ដឹងឧទ្ធរណ៍

ការប្ដឹងឧទ្ធរណ៍ ដែលធ្វើឡើងដោយពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវតែធ្វើឡើងក្នុងរយៈពេលមួយខែ។

កាលណាសាលក្រមនោះ ជាសាលក្រមចំពោះមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលប្រកាសសាលក្រម។ កាលណាសាលក្រមនោះ ជាសាលក្រមចាត់ទុកថាចំពោះមុខ រយៈពេលប្ដឹងឧទ្ធរណ៍ ផ្ដើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីជាការឱ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ ( *មាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

តារាងទី ៣៖ រយៈពេលប្ដឹងឧទ្ធរណ៍ ចំពោះសាលក្រមចំពោះមុខ *(មាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧)*

| សាលក្រមចំពោះមុខ<br>*(មាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)* | |
|---|---|
| | ជនជាប់ចោទ |
| រយៈពេលសម្រាប់ដាក់ពាក្យបណ្ដឹង | ១ ខែ ចាប់ពីថ្ងៃទទួលប្រកាសសាលក្រម |
| ទម្រង់នៃការជំទាស់ | បណ្ដឹងឧទ្ធរណ៍ទៅតុលាការជាន់ដំបូង |

តារាងទី ៤៖ រយៈពេលប្ដឹងឧទ្ធរណ៍ ចំពោះសាលក្រមចាត់ទុកថាចំពោះមុខ

| សាលក្រមចាត់ទុកថាចំពោះមុខ<br>*(មាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)* | |
|---|---|
| | ជនជាប់ចោទ |
| រយៈពេលសម្រាប់ដាក់ពាក្យបណ្ដឹង | ១ ខែចាប់ពីថ្ងៃទទួលដំណឹងសាលក្រម |
| ទម្រង់នៃការជំទាស់ | បណ្ដឹងឧទ្ធរណ៍ទៅតុលាការជាន់ដំបូង |

តារាងទី ៥៖ រយៈពេលប្ដឹងឧទ្ធរណ៍ ចំពោះសាលក្រមកំបាំងមុខ

| សាលក្រមកំបាំងមុខ<br>*(មាត្រា ៣៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)* | |
|---|---|
| | ជនជាប់ចោទ |
| រយៈពេលសម្រាប់ដាក់ពាក្យបណ្ដឹង | ១៥ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីសាលក្រម |
| ទម្រង់នៃការជំទាស់ | ប្ដឹងទាស់ទៅតុលាការជាន់ដំបូង |

ការប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ត្រូវធ្វើឡើងក្នុងរយៈពេលមួយខែ ចាប់គិតពីថ្ងៃប្រកាសសាលក្រម។ ការប្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ត្រូវធ្វើឡើងក្នុងរយៈពេលបីខែ ចាប់គិតពីថ្ងៃប្រកាសសាលក្រម ( *មាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧* )។

## ដំណើរការ

បណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ដែលបានប្រកាសសាលក្រម។ បណ្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ត្រូវធ្វើឡើងនៅការិយាល័យក្រឡាបញ្ជីរបស់សាលាឧទ្ធរណ៍ ( *មាត្រា ៣៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧* )។

## ការតំណាង

ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី ដើម្បីប្ដឹងឧទ្ធរណ៍។ ប៉ុន្តែ មេធាវី ត្រូវតែមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្ដឹងឧទ្ធរណ៍ ក្នុងនាមពិរុទ្ធជន។ ប៉ុន្តែ ក្នុងករណីដែលពិរុទ្ធជនជាអនីតិជន គាត់អាចតំណាងដោយឪពុក ម្ដាយ ឬអ្នកអាណាព្យាបាល។ ក្នុងករណីនេះ អ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិនោះទេ។

ក្នុងករណីដែលដើមបណ្ដឹងរដ្ឋប្បវេណី តំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ អ្នកតំណាង ត្រូវតែមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្ដឹងឧទ្ធរណ៍នេះ ទើបអាចធ្វើបណ្ដឹងឧទ្ធរណ៍ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីនេះបាន។ នៅក្នុងករណីដែលអ្នកទទួលខុសត្រូវរដ្ឋប្បវេណី តំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ អ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្ដឹងឧទ្ធរណ៍នេះ ( *មាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧* )។

!

ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ អាចតំណាងដោយមន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី ដោយអនុលោមទៅតាមប្រកាសរបស់ក្រសួងកិច្ចការនារីលេខ ០៧២ កកន/បស ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៧។ ប៉ុន្តែ ជាគោលការណ៍ មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី គួរតែធ្វើបណ្ដឹងឧទ្ធរណ៍ តែនៅក្នុងករណីមានការយល់ព្រមពីជនរងគ្រោះតែប៉ុណ្ណោះ។

## អនុបវាទ

នៅពេលដែលចៅក្រម ឬព្រះរាជអាជ្ញាណាម្នាក់ បានចូលរួមក្នុងកិច្ចស៊ើបសួរ ឬចូលរួមជំនុំជម្រះសាលាដំបូងរួចហើយនោះចៅក្រមឬព្រះរាជអាជ្ញារូបនេះមិនអាចចូលរួមជំនុំជម្រះនៅសាលាឧទ្ធរណ៍ ក្នុងឋានៈជាប្រធាន ឬចៅក្រម ចំពោះរឿងដដែលនោះបានឡើយ (*មាត្រា ៣៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ នៅក្នុងករណីដែលចៅក្រម ឬព្រះរាជអាជ្ញាណាម្នាក់ បំពានទៅលើបទប្បញ្ញត្តិនៃវិធាននេះ នោះសាលក្រមរបស់ពួកគេនឹងក្លាយជាមោឃៈ។

ឧទាហរណ៍៖ *ចៅក្រម ខ បានចូលរួមក្នុងនាមជាចៅក្រមស៊ើបសួរ នៅក្នុងការជំនុំជម្រះលើករណីរំលោភសេពសន្ថវៈ នៅក្នុងសាលាដំបូងមួយ។ ចៅក្រម ខ មិនអាចធ្វើជាចៅក្រមជំនុំជម្រះ នៅក្នុងសំណុំរឿងដដែលនេះទេ។*

ឧទាហរណ៍៖ *ចៅក្រម ក បានចូលរួមនៅក្នុងដំណើរការក្តី ក្នុងនាមជាចៅក្រមស៊ើបសួរ ក្នុងសំណុំរឿងឃាតកម្មលើប្តីរបស់លោក ស្រី វី។ នៅដំណាក់កាលស៊ើបសួរ ចៅក្រម ក បានលើកលែងការចោទប្រកាន់ទៅលើជនជាប់ចោទ។ លោកស្រី វី ប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចនេះ ទៅសាលាឧទ្ធរណ៍។ ស្របពេលជាមួយគ្នានេះ ចៅក្រម ក បានផ្លាស់ទៅធ្វើការងារជាចៅក្រម នៅសាលាឧទ្ធរណ៍។ ចៅក្រម ក មិនអាចដោះស្រាយសំណុំរឿងឧទ្ធរណ៍នេះឡើយ ដោយសារតែគាត់បានធ្វើជាចៅក្រមស៊ើបសួរ នៅសាលាដំបូង ដែលធ្វើការជំនុំជម្រះលើសំណុំរឿងនេះរួចហើយ។*

## ការអនុវត្តសាលក្រម

នៅក្នុងករណី ដែលមានការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមរបស់សាលាដំបូង ការអនុវត្តសាលក្រមត្រូវបង្អង់សិន រហូតដល់ពេលដែលរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍ផុតកំណត់។

ប៉ុន្តែ ជនជាប់ចោទ ដែលជាប់ឃុំ ដែលបានចូលបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ត្រូវនៅក្នុងពន្ធនាគារ នៅក្នុងរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា។ ក្នុងករណី ដែលព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ នោះជនជាប់ចោទត្រូវនៅក្នុងពន្ធនាគារ រហូតដល់សាលាឧទ្ធរណ៍សម្រេច។ ក្នុងករណី ដែលតុលាការជាន់ដំបូងបានសម្រេចឱ្យជនជាប់ចោទរួចខ្លួន ឬបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលតិចជាង ឬស្មើនឹងរយៈពេល

នៃការឃុំខ្លួនបណ្ដោះអាសន្ន ព្រះរាជអាជ្ញាអាចយល់ព្រមដោះលែងជនជាប់ចោទឱ្យមានសេរីភាព មុនពេលផុតកំណត់នៃរយៈពេលសម្រាប់ប្ដឹងឧទ្ធរណ៍ (*មាត្រា ៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ឧទាហរណ៍៖ *លោក សំរេច ត្រូវបានព្រះរាជអាជ្ញាចោទប្រកាន់ពីបទរំលោភកូនប្រុស ចុង អាយុ ១០ ឆ្នាំរបស់គាត់ ហើយបញ្ជូនសំណុំរឿងនេះទៅជំនុំជម្រះ។ នៅក្នុងពេលជំនុំជម្រះ ចៅក្រមជំនុំជម្រះសម្រេចលើកលែងការចោទប្រកាន់ទៅលើលោកសំរេច។ ព្រះរាជអាជ្ញាមិនពេញចិត្តនឹងសេចក្ដីសម្រេចនេះ ហើយដាក់ពាក្យប្ដឹងឧទ្ធរណ៍។ នៅក្នុងនីតិវិធីឧទ្ធរណ៍ ការអនុវត្តសាលក្រម ដើម្បីលើកលែងការចោទប្រកាន់ត្រូវព្យួរសិន។ មានន័យថា លោក សំរេច នឹងមិនត្រូវបានដោះលែងឱ្យរួចខ្លួនឡើយ នៅក្នុងពេលរង់ចាំ សេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍នេះ។*

ឧទាហរណ៍៖ *លោក ផាន់ណា ត្រូវបានព្រះរាជអាជ្ញាចោទប្រកាន់ពីបទបង្ហាញកេរភេទ។ នៅក្នុងដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរ សម្រេចឃុំខ្លួនជនជាប់ចោទបណ្ដោះអាសន្ន រយៈពេល ១ ខែ។ ក្រោយពេលបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមជំនុំជម្រះ សម្រេចកាត់ទោស លោក ផាន់ ណា ដាក់ពន្ធនាគាររយៈពេល ១ ខែ។ ដោយមិនពេញចិត្តនឹងសេចក្ដីសម្រេចរបស់ចៅក្រមជំនុំជម្រះ ជនរងគ្រោះប្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្ដីសម្រេចនេះ។ ដោយសារតែទោសដាក់ពន្ធនាគាររបស់ លោក ផាន់ណា មានរយៈពេលស្មើនឹងរយៈពេលឃុំខ្លួនបណ្ដោះអាសន្ន ព្រះរាជអាជ្ញាអាចដោះលែង លោក ផាន់ណា មុនពេលផុតកំណត់រយៈពេលប្ដឹងឧទ្ធរណ៍បាន។*

## នីតិវិធី

នីតិវិធីរបស់សាលាឧទ្ធរណ៍ គឺមិនខុសគ្នាច្រើនពីនីតិវិធីរបស់តុលាការជាន់ដំបូងឡើយ។

ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃតុលាការជាន់ដំបូងរៀបចំសំណុំរឿង ដើម្បីបញ្ជូនទៅសាលាឧទ្ធរណ៍។ ក្រឡាបញ្ជីត្រូវផ្ញើនៅក្នុងរយៈពេលដ៏ខ្លីបំផុត ជូនទៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍នូវ៖

❖ សំណុំរឿង

❖ សេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍នីមួយៗ ( *ដោយមានត្រារបស់តុលាការ ដើម្បីបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម*)

❖ សេចក្តីចម្លងនៃសាលក្រម ( *ដោយមានត្រារបស់តុលាការ ដើម្បីបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម*)។

នៅក្នុងករណីមានបណ្តឹងឧទ្ធរណ៍ អំពីសេចក្តីសម្រេចរបស់តុលាការស្តីពីការឃុំខ្លួនជនជាប់ចោទ សំណុំរឿងត្រូវបញ្ជូនក្នុងរយៈពេល ១០ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃប្តឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈមិនអាចជំនះបាន ដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន។

នៅពេលសំណុំរឿងទៅដល់សាលាឧទ្ធរណ៍ ប្រធានសភាព្រហ្មទណ្ឌពិនិត្យ ផ្ទៀងផ្ទាត់មើលថាតើទម្រង់បែបបទនៃបណ្តឹងឧទ្ធរណ៍បានត្រឹមត្រូវឬទេ និងកំណត់កាលបរិច្ឆេទនៃសវនាការ។ សាលាឧទ្ធរណ៍ត្រូវសម្រេច ក្នុងរយៈពេលសមស្រប។

ក្នុងករណីប្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចរបស់តុលាការជាន់ដំបូង ស្តីពីការឃុំខ្លួនជនជាប់ចោទ សាលាឧទ្ធរណ៍ត្រូវសម្រេចក្នុងរយៈពេលដ៏ខ្លីបំផុត និងយ៉ាងយូរបំផុតក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃទទួលសំណុំរឿង ( *មាត្រា ៣៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

## សាលដីកាសាលាឧទ្ធរណ៍

អានុភាពនៃបណ្តឹងឧទ្ធរណ៍ តែពីជនជាប់ចោទប៉ុណ្ណោះ

សាលាឧទ្ធរណ៍ កាលណាបានទទួលបណ្តឹងឧទ្ធរណ៍ តែពីជនជាប់ចោទប៉ុណ្ណោះ មិនអាចដាក់ទម្ងន់ទោសជននោះទេ។ តុលាការអាចកែប្រែសាលក្រមបាន នៅក្នុងន័យដែលអនុគ្រោះដល់ជននេះតែប៉ុណ្ណោះ។ មានន័យថា សាលាឧទ្ធរណ៍មិនអាចបន្ថែមទោសបន្ថែមពីលើមូលទោសបានទេ។ សាលាឧទ្ធរណ៍អាចជំនួសឈ្មោះបទល្មើស ដែលកំណត់ដោយតុលាការជាន់ដំបូង ដោយឈ្មោះបទល្មើសមួយទៀតបាន ប៉ុន្តែមិនអាចដាក់ទម្ងន់ទោសលើជនជាប់ចោទចំពោះការខូចខាត ដែលបង្កចំពោះបណ្តឹងរដ្ឋប្បវេណីនោះទេ។ ប្រសិនបើតុលាការជាន់ដំបូងភ្លេចប្រកាសទោសបន្ថែមណាមួយ ដែលជាច់ខាតត្រូវតែប្រកាសនោះ សាលាឧទ្ធរណ៍ បដិសេធសាលក្រម ហើយសម្រេចអំពីទោសជាថ្មីម្តងទៀតដោយខ្លួនឯង ( *មាត្រា ៣៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ឧទាហរណ៍៖ *លោក ឌីលុច ត្រូវបានតុលាការជាន់ដំបូងកាត់ទោសដាក់ពន្ធនាគារ ៨ ឆ្នាំ និងសងសំណង ៣ លានរៀល ដល់ជនរងគ្រោះ ដែលគាត់បានរំលោភសេពសន្ថវៈ។ ដោយមិនពេញចិត្តចំពោះសេចក្តីសម្រេចរបស់តុលាការជាន់ដំបូង លោក ឌីលុច ប្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចដាក់ពន្ធនាគារ។ ក្រោយពីទទួលបណ្តឹងឧទ្ធរណ៍ពីជនជាប់ចោទ សាលាឧទ្ធរណ៍បើកសវនាការ ដើម្បីសម្រេចលើទោសដាក់ពន្ធនាគារ។ សាលាឧទ្ធរណ៍មិនអាចបន្ថែមទោសលើសពី ៨ ឆ្នាំបានឡើយ។ សាលាឧទ្ធរណ៍ អាចសម្រេចតែលើបទល្មើសមួយទៀត ដែលមានទោសដាក់ពន្ធនាគារស្មើ ឬតិចជាង ៨ ឆ្នាំ តែប៉ុណ្ណោះ។ សាលាឧទ្ធរណ៍ មិនអាចបង្កើនសំណងរដ្ឋប្បវេណី លើសពី ៣ លានរៀល ទៅតាមអ្វីដែលខ្លួនដឹងនោះទេ ដោយសារតែជនរងគ្រោះមិនបានប្តឹងឧទ្ធរណ៍។*

### អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាលើសាលក្រមរបស់តុលាការជាន់ដំបូង នាំឱ្យសើរើឡើងវិញនូវសេចក្តីសម្រេចខាងព្រហ្មទណ្ឌនៃតុលាការជាន់ដំបូង។ សាលាឧទ្ធរណ៍ ជាយថាហេតុ អាចបដិសេធសាលក្រម ដែលសម្រេចឱ្យរួចខ្លួន ឬអាចសម្រេចដាក់ទម្ងន់ទោស ដែលបានប្រកាសឡើង ដោយតុលាការជាន់ដំបូង។ សាលាឧទ្ធរណ៍ អាចសម្រេចឱ្យជនជាប់ចោទរួចខ្លួន ជានិច្ច ប្រសិនបើយល់ឃើញថា ពិរុទ្ធភាពលើជននេះ មិនអាចបង្ហាញឱ្យឃើញទេនោះ។ ប៉ុន្តែ សាលាឧទ្ធរណ៍អាចប្រកាសទោសបន្ថែម ដែលដាច់ខាតត្រូវតែប្រកាសដោយខានមិនបាន ដែលតុលាការជាន់ដំបូងភ្លេចមិនបានប្រកាស (*មាត្រា ៤០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ឧទាហរណ៍៖ *លោក សុខុម ត្រូវបានតុលាការជាន់ដំបូងកាត់ទោសដាក់ពន្ធនាគារ ៧ ឆ្នាំ ពីបទរំលោភសេពសន្ថវៈ។ ដោយមិនពេញចិត្តចំពោះសេចក្តីសម្រេចនេះ ព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍។ ដូច្នេះ សាលាឧទ្ធរណ៍អាចកាត់ទោសលោក សុខុម ដាក់ពន្ធនាគារ ស្មើនឹង ៧ ឆ្នាំ ឬច្រើនជាង ៧ ឆ្នាំ (ពោលគឺ ៨, ៩ ឬ ១០ ឆ្នាំ ទៅតាមការយល់ឃើញរបស់ខ្លួន)។*

### អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីរបស់តុលាការជាន់ដំបូង ពាក្យប្តឹងនេះ នាំឱ្យសើរើតែផ្នែករដ្ឋប្បវេណីរបស់សាលក្រមជំនុំជម្រះរបស់តុលាការជាន់ដំបូងតែប៉ុណ្ណោះ។ លើសពីនេះ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើពាក្យប្តឹងសុំថ្មី ដែលមិនបានដាក់ជូនតុលាការជាន់ដំបូងនោះទេ (*មាត្រា ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ឧទាហរណ៍៖ *លោក ធីតា ត្រូវបានសាលាដំបូងកាត់ទោសដាក់ពន្ធនាគារ ២ ខែ ពីបទរុកគួនខាងផ្លូវភេទ និងត្រូវសងជំងឺចិត្ត ៥ លាន រៀល ដល់ជនរងគ្រោះ។ ដោយមិនពេញចិត្តចំពោះសេចក្តីសម្រេចឱ្យសង ៥ លានរៀល ជនរងគ្រោះដាក់ពាក្យប្តឹងឧទ្ធរណ៍។ ដូច្នេះសាលាឧទ្ធរណ៍អាចកែប្រែសេចក្តីសម្រេចរបស់សាលាដំបូង ដែលពាក់ព័ន្ធជាមួយនឹងសំណងចំនួន ៥ លានរៀលតែប៉ុណ្ណោះ។ ជនរងគ្រោះ មិនអាចប្តឹងឧទ្ធរណ៍ពាក់ព័ន្ធជាមួយ នឹងទោសដាក់ពន្ធនាគារ ដែលបានសម្រេចដោយសាលាដំបូងនោះទេ។*

### ការបដិសេធសាលក្រម

នៅពេលដែលសាលាឧទ្ធរណ៍ទទួលបានពាក្យប្តឹងឧទ្ធរណ៍ ពីបុគ្គលណាក៏ដោយ ហើយបើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នេះ រកឃើញថាជនជាប់ចោទគ្មានពិរុទ្ធភាព សាលាឧទ្ធរណ៍ត្រូវបដិសេធសាលក្រមរបស់តុលាការជាន់ដំបូង ហើយឱ្យជនជាប់ចោទរួចខ្លួន (*មាត្រា ៤០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ឧទាហរណ៍៖ *លោក រិទ្ធី ត្រូវបានសាលាដំបូងរាជធានីភ្នំពេញផ្តន្ទាទោសដាក់ពន្ធនាគារ ២ ឆ្នាំ ពីបទប្រទូស្តកេរខ្មាស។ ដោយមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ លោក រិទ្ធី ដាក់ពាក្យប្តឹងឧទ្ធរណ៍។ នៅពេលដែលសាលាឧទ្ធរណ៍បើកការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នេះ សាលាឧទ្ធរណ៍រកឃើញថា លោក រិទ្ធី មិនមានកំហុសឡើយ។ ដូច្នេះសាលាឧទ្ធរណ៍ចេញសាលដីកាមួយ ដើម្បីលើកលែងការចោទប្រកាន់ចំពោះលោក រិទ្ធី ហើយដោះលែងជនជាប់ចោទ នៅពេលដែលរយៈពេលសម្រាប់ដាក់បណ្តឹងសាទុក្ខដល់ពេលផុតកំណត់។*

# បណ្ដឹងសាទុក្ខ

បណ្ដឹងសាទុក្ខ គឺជាការបដិសេធចំពោះសាលដីកាស្ថាពរ ដែលចេញដោយសាលាឧទ្ធរណ៍។ មានន័យថា នៅក្នុងរយៈពេល ដើម្បីធ្វើបណ្ដឹងសាទុក្ខ ការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍ត្រូវព្យួរទុកសិន។

## បុគ្គល ដែលអាចធ្វើបណ្ដឹងសាទុក្ខ

បណ្ដឹងសាទុក្ខ អាចត្រូវធ្វើដោយ៖

- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ជនជាប់ចោទ ឬពិរុទ្ធជន
- បុគ្គល ដែលត្រូវគេទាមទារ ក្នុងករណីនៃនីតិវិធីបត្យាប័ន
- ដើមបណ្ដឹងរដ្ឋប្បវេណី និង
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

បណ្ដឹងសាទុក្ខ ត្រូវពិនិត្យដោយសភាព្រហ្មទណ្ឌនៃតុលាការកំពូល (*មាត្រា ៤១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

ក្នុងករណីដែលមានបណ្ដឹងសាទុក្ខ ប្រឆាំងនឹងសាលដីការបស់សាលាឧទ្ធរណ៍ ការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍ត្រូវផ្អាកសិន រហូតដល់ពេលមានសេចក្ដីសម្រេចពីតុលាការកំពូល។ បណ្ដឹងសាទុក្ខលើកទី ១ មានសមាសភាពចៅក្រមចំនួន ៥ រូប ដែលធ្វើការជំនុំជម្រះតែលើអង្គច្បាប់តែប៉ុណ្ណោះ។ ភាគី មានសិទ្ធិប្ដឹងសាទុក្ខលើកទី ២ ចំពោះការសម្រេចរបស់តុលាការកំពូល។ អង្គជំនុំជម្រះនៃបណ្ដឹងសាទុក្ខទីពីរ មានសមាសភាពចៅក្រមចំនួន ៩ រូប ដែលធ្វើការជំនុំជម្រះលើអង្គច្បាប់ផង និងអង្គហេតុផង (*មាត្រា ៤៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

## មូលហេតុនៃបណ្តឹងសាទុក្ខ

តុលាការកំពូល អាចបដិសេធសេចក្តីសម្រេច ក្នុងករណីដូចតទៅ៖

- សមាសភាពមិនស្របច្បាប់នៃតុលាការ
- អសមត្ថកិច្ចនៃតុលាការ
- ការរំលោភអំណាច
- ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់
- ការបំពាន ឬភ្លេចទម្រង់ការ ដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ
- ការមិនបានសម្រេចលើពាក្យប្តឹងសុំរបស់អយ្យការ ឬភាគី កាលណាពាក្យប្តឹងសុំនេះធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់
- ការបំភ្លៃអង្គហេតុ
- គ្មានសំអាងហេតុ
- ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្តីសម្រេច (មាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ *ឆ្នាំ ២០០៧*)។

## រយៈពេល ដើម្បីធ្វើបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខ ត្រូវធ្វើក្នុងរយៈពេល ដូចតទៅ៖

- មួយខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍
- ដប់ប្រាំថ្ងៃ ចំពោះសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍
- ប្រាំថ្ងៃ ចំពោះមតិរបស់សភាស៊ើបសួរ ដែលបញ្ចេញក្នុងរឿងបត្យាប័ន។

កាលណាសាលដីកាដែលប្តឹងសាទុក្ខនេះ ជាសាលដីកាចំពោះមុខ រយៈពេលត្រូវផ្តើមគិតពីការប្រកាសសាលដីកា។

កាលណាសាលដីកាដែលប្តឹងសាទុក្ខនេះ ជាសាលដីកាដែលចាត់ទុកថាចំពោះមុខ រយៈពេលត្រូវផ្តើមគិតពីការឱ្យដំណឹង។

កាលណាសាលដីកាសម្រេចដោយកំបាំងមុខ រយៈពេលត្រូវផ្ដើមគិតពីការផុតរយៈពេលប្ដឹងទាស់ (*មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។

បណ្ដឹងសាទុក្ខ ត្រូវធ្វើតាមពាក្យប្ដឹង នៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ដែលបានចេញសេចក្ដីសម្រេច (*មាត្រា ៤២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ នៅក្នុងរយៈពេលដ៏ខ្លីបំផុត ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍រៀបចំសំណុំរឿង ហើយបញ្ជូនទៅក្រឡាបញ្ជីតុលាការកំពូល ដើម្បីចុះបញ្ជីលើសំណុំរឿងនេះ។ ក្រឡាបញ្ជីតុលាការកំពូល ត្រូវឱ្យដំណឹងដល់គូភាគី អំពីការចុះបញ្ជីនៃសំណុំរឿង។

ក្នុងរយៈពេល ១០ ថ្ងៃ ក្រោយការឱ្យដំណឹងនេះ ក្រឡាបញ្ជីឱ្យដំណឹងដល់អ្នកប្ដឹងសាទុក្ខ ឬមេធាវីរបស់គាត់ ថាខ្លួនមានចិរវេលា ២០ ថ្ងៃ ដើម្បីផ្ញើជូនសភាព្រហ្មទណ្ឌតុលាការកំពូល នូវសារណាមួយ ដែលខ្លួនត្រូវរៀបរាប់អំពីមធ្យោបាយខាងច្បាប់។

ប្រសិនបើអ្នកប្ដឹងសាទុក្ខបានតាំងមេធាវី និងបានបញ្ជូនឈ្មោះមេធាវីនេះ ទៅក្រឡាបញ្ជីតុលាការកំពូល ការជូនដំណឹងនេះក៏ត្រូវផ្ញើទៅមេធាវីផងដែរ។ ប្រសិនបើអ្នកប្ដឹងសាទុក្ខបានជូនសារណា ក្រឡាបញ្ជីត្រូវឱ្យដំណឹងដល់ភាគីដទៃទៀត និងជាយថាហេតុ ដល់មេធាវី ដែលមានចិរវេលា ២០ ថ្ងៃដែរ ដើម្បីឆ្លើយតបទៅនឹងសារណារបស់អ្នកប្ដឹងសាទុក្ខ (*មាត្រា ៤២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ កាលណារយៈពេលម្ភៃថ្ងៃនេះមិនគ្រប់គ្រាន់ទេ ភាគីអាចសុំទៅប្រធានសភាព្រហ្មទណ្ឌឱ្យពន្យារពេល។ ការពន្យារពេលនេះ មិនអាចលើសពីដប់ថ្ងៃឡើយ។

## រយៈពេលសម្រាប់សេចក្ដីសម្រេច

តុលាការកំពូល ត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ ៦ ខែ គិតពីពេលទទួលសំណុំរឿង លើកលែងតែមានកាលៈទេសៈ ដែលមិនអាចជំនះបាន (*មាត្រា ៤៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ សភាព្រហ្មទណ្ឌនៃតុលាការកំពូល អាចបដិសេធបណ្ដឹងសាទុក្ខទាំងស្រុង ឬមួយផ្នែក និងបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ដែលគេតវ៉ានេះចោលទាំងស្រុង ឬមួយផ្នែក។

ប្រសិនបើបណ្ដឹងសាទុក្ខ ត្រូវបានបដិសេធ នោះសេចក្ដីសម្រេចដែលតវ៉ា មានអាជ្ញាអស់ជំនុំ។ អ្នកប្ដឹងសាទុក្ខ មិនត្រូវបានអនុញ្ញាតឱ្យប្ដឹងសាទុក្ខជាថ្មីម្ដងទៀតអំពីសាលដីកាដដែលនោះឡើយ។ កាលណាតុលាការកំពូលបដិសេធសេចក្ដីសម្រេច ដែលគេតវ៉ា តុលាការកំពូលបញ្ជូនរឿង និងគូភាគីទៅសាលាឧទ្ធរណ៍វិញ ប៉ុន្តែ មានសមាសភាពថ្មីផ្សេងពីសមាសភាពមុន។

# ជំពូកទី ៥ - បណ្ដឹងរដ្ឋប្បវេណី នៅក្នុងរឿងក្ដីព្រហ្មទណ្ឌ

## នៅក្នុងរឿងក្ដីព្រហ្មទណ្ឌ តើអ្នកណា ដែលអាចដាក់ពាក្យបណ្ដឹងរដ្ឋប្បវេណីបាន ?

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្ដឹង ដោយតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ (*មាត្រា ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧*)។ បណ្ដឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឱ្យបានជួសជុលការខូចខាត ដែលបណ្ដាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជំងឺចិត្ត ជួនល្មមនឹងព្យសនកម្ម ដែលខ្លួនបានទទួល។

មិនមែនត្រឹមតែជនរងគ្រោះប៉ុណ្ណោះនោះទេ ដែលអាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបាន បុគ្គលខាងក្រោមនេះ ក៏អាចធ្វើបានដែរ៖

- តំណាងស្របច្បាប់របស់ជនរងគ្រោះជាអនីតិជន
- តំណាងស្របច្បាប់របស់ជនរងគ្រោះ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកអាណាព្យាបាលស្របច្បាប់
- សិទ្ធិវន្តរបស់ជនរងគ្រោះ
- បុគ្គល ឬសមាគម ដែលច្បាប់ទទួលស្គាល់ថាជាដើមបណ្ដឹងរដ្ឋប្បវេណី។

## តើអ្វីទៅ ដែលហៅថាបណ្ដឹងរដ្ឋប្បវេណី ក្នុងរឿងក្ដីព្រហ្មទណ្ឌ ?

គេអាចធ្វើពាក្យប្ដឹងរដ្ឋប្បវេណី ក្នុងរឿងក្ដីព្រហ្មទណ្ឌ ដើម្បីទទួលបានសំណងខាងផ្លូវចិត្ត ខាងផ្លូវកាយ និងព្យសនកម្មខាងទ្រព្យសម្បត្តិ ដល់ជនរងគ្រោះ ដែលទទួលរងព្យសនកម្មដោយសារតែទង្វើមិនត្រឹមត្រូវ។

មានលក្ខខណ្ឌចំនួន ៣ ដែលបង្ហាញអំពីការទទួលខុសត្រូវរដ្ឋប្បវេណី៖

១. ផលវិបាកផ្ទាល់នៃបទល្មើស

២. ព្យសនកម្មផ្ទាល់ខ្លួន

៣. បានកើតឡើង និងមាននៅក្នុងពេលបច្ចុប្បន្ន។

## បណ្ដឹងរដ្ឋប្បវេណី ក្នុងពេលជាមួយគ្នានឹងការជំនុំជម្រះព្រហ្មទណ្ឌ

!

បណ្ដឹងរដ្ឋប្បវេណី អាចធ្វើឡើងក្នុងពេលជាមួយគ្នានឹងបណ្ដឹងអាជ្ញា នៅចំពោះមុខសាលាជម្រះក្ដីព្រហ្មទណ្ឌ មានន័យថា នៅពេលដែលជនរងគ្រោះដាក់ពាក្យប្ដឹងអាជ្ញា ជនរងគ្រោះអាចទាមទារឱ្យមានការចោទប្រកាន់ជនល្មើស និងទាមទារសំណង ចំពោះការខូចខាតនានា ដោយសរសេរដាក់ក្នុងពាក្យបណ្ដឹង។

ឧទាហរណ៍៖ *លោក សុខ និងកញ្ញា សុភី គឺជាអ្នកជិតខាងគ្នារាប់ឆ្នាំមកហើយ។ នៅថ្ងៃទី ០២ ខែធ្នូ ឆ្នាំ ២០១២ លោក សុខបានប្រព្រឹត្តបទប្រទូស្តកេរខ្មាសចំពោះកញ្ញា សុភី រហូតដល់មានរបួស។ កញ្ញា សុភីដាក់ពាក្យប្ដឹងទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងស្រុកកំពង់ត្រាច ដើម្បីសុំឱ្យអធិការនគរបាលស្រុកកំពង់ត្រាច ចាប់ខ្លួនលោក សុខ ហើយនាំគាត់ទៅតុលាការ ដើម្បីប្រឈមនឹងយុត្តិធម៌។ នៅក្នុងបណ្ដឹងនោះ កញ្ញា សុភី មិនត្រឹមតែប្ដឹងពីបទប្រទូស្តកេរខ្មាសនោះទេ តែក៏បានប្ដឹងទាមទារសំណងពីលោក សុខ សង ថ្លៃព្យាបាលរបួសរបស់នាង ក្នុងទឹកប្រាក់សរុប ១០ លានរៀលផងដែរ។*

ឧទាហរណ៍៖ *នាង សាននាំក្មេងស្រីអាយុ ១៤ ឆ្នាំ ឈ្មោះ ចាន់ សុភាព ទៅខេត្តកំពត ដើម្បីធ្វើការងារនៅក្នុងភោជនីយដ្ឋានមួយ ដែលជាផ្ទះបនរកស៊ីផ្លូវភេទមួយផងដែរ។ ឪពុករបស់កុមារី ចាន់ សុភាព ឈ្មោះលោក ចាន់ដាក់ពាក្យប្ដឹងនាង សាន ទៅចៅក្រមស៊ើបសួរ នៅសាលាដំបូងខេត្តកំពត និងទាមទារសំណងចំពោះការបាត់បង់កិត្តិយស ក្នុងទឹកប្រាក់ ៤ លានរៀល។ ព្រះរាជអាជ្ញាទទួលពាក្យប្ដឹងនេះពីចៅក្រមស៊ើបសួរ និងមានពេលពីរខែ ដើម្បីធ្វើការសម្រេច ថាតើត្រូវចាប់ផ្ដើមនីតិវិធីព្រហ្មទណ្ឌ និងចោទប្រកាន់ជនសង្ស័យដែរឬអត់។ ជំហានបន្ទាប់គឺ ចៅក្រមស៊ើបសួរ ត្រូវធ្វើការសម្រេចថាតើត្រូវ ចោទប្រកាន់នាង សានពីបទជួញដូរមនុស្សដែរ ឬអត់។ ទាល់តែសំណុំរឿងនេះត្រូវបានបញ្ជូនទៅចៅក្រមជំនុំជម្រះ ហើយនាង សានត្រូវបានកាត់ឱ្យជាប់ទោសពីបទជួញដូរមនុស្ស ទើបចៅក្រមអាចសម្រេចលើបណ្ដឹងរដ្ឋប្បវេណីបាន។ សេចក្ដីសម្រេចថាតើ លោក ចាន់អាចទទួលបានសំណងប៉ុន្មាននោះ គឺអាស្រ័យទៅលើសាលក្រមរបស់តុលាការ ថាតើទឹកប្រាក់ ៤ លានរៀលនេះ សមស្របទៅនឹងការខូចខាត ដែលទាមទារដោយលោក ចាន់ដែរ ឬទេ។*

## បណ្ដឹងរដ្ឋប្បវេណី ដោយឡែកពីការជំនុំជម្រះព្រហ្មទណ្ឌ

បណ្ដឹងរដ្ឋប្បវេណី អាចត្រូវបានប្ដឹង ដោយឡែកពីការជំនុំជម្រះព្រហ្មទណ្ឌ។ នៅក្នុងករណីនេះ បណ្ដឹងអាជ្ញា ត្រូវបានប្ដឹងទៅចៅក្រមនៃសភាព្រហ្មទណ្ឌរបស់តុលាការ ហើយបណ្ដឹងរដ្ឋប្បវេណី ត្រូវបានប្ដឹងទៅចៅក្រមម្នាក់ទៀត នៅសភារដ្ឋប្បវេណីរបស់តុលាការ។ ប៉ុន្តែ សេចក្ដីសម្រេចរបស់សភារដ្ឋប្បវេណីរបស់តុលាការ នឹងត្រូវព្យួរសិន រហូតដល់ពេលដែលមានការចេញសាលក្រមស្ថាពរសម្រាប់បណ្ដឹងអាជ្ញាសិន។

ឧទាហរណ៍៖ *លោកស្រី ចរិយា គឺជាម្ដាយមីងរបស់ក្មេងស្រីម្នាក់ ឈ្មោះ សុភាព ដែលត្រូវបានមិត្តរួមថ្នាក់របស់នាង ឈ្មោះ តុលា អាយុ ១៦ ឆ្នាំ ចាប់រំលោភនៅវិទ្យាល័យទូកមាស នៅពេលដែលពួកគេទៅដើរលេងជាមួយគ្នា។ លោកស្រី ចរិយា ដាក់ពាក្យប្ដឹងព្រហ្មទណ្ឌ ទៅសាលាដំបូងខេត្តកំពត ដើម្បីស្នើសុំឱ្យតុលាការ ផ្ដន្ទាទោស ឈ្មោះ តុលា តាមច្បាប់ និងបានដាក់ពាក្យប្ដឹងមួយទៀត ដែលជាបណ្ដឹងរដ្ឋប្បវេណី ទៅសាលាដំបូងខេត្តកំពត ដើម្បីទាមទារសំណងចំពោះការខូចខាត ដែលកើតឡើងរួចទៅហើយ ដូចជាការខូចខាតកិត្តិយស ការព្យាបាល និងការចាយវាយទៅលើការធ្វើដំណើរ រួមទាំងការខាតបង់ពេលវេលា ដោយទាមទារទឹកប្រាក់ សរុប ៥ លានរៀល។ ដូច្នេះ នៅក្នុងចំណោមបណ្ដឹងទាំងពីរនេះ ត្រូវមានការសម្រេច លើបណ្ដឹងអាជ្ញាជាមុនសិន មុនពេលដែលមានការសម្រេចលើបណ្ដឹងរដ្ឋប្បវេណី។ ប្រសិនបើបណ្ដឹងអាជ្ញារកឃើញថា ឈ្មោះ តុលា នេះ មានកំហុសពិតប្រាកដមែន នោះ ចៅក្រមកាន់រឿងក្ដីរដ្ឋប្បវេណី អាចធ្វើការសម្រេចអំពីចំនួនសំណងបាន។ ប្រសិនបើឈ្មោះ តុលា នេះត្រូវបានរកឃើញថាគ្មានកំហុសទេ នោះបណ្ដឹង រដ្ឋប្បវេណីនឹងត្រូវបានទាត់ចោល។*

# ជំពូកទី ៦ - អំពើហិង្សាក្នុងគ្រួសារ

## វិសាលភាពនៃអំពើហិង្សាក្នុងគ្រួសារ

បើយោងតាមច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ បានឱ្យដឹងថា អំពើហិង្សាក្នុងគ្រួសារ គឺសំដៅលើអំពើហិង្សា ដែលកើតមាន និងអាចកើតមានទៅលើប្ដី ឬប្រពន្ធ កូនក្នុងបន្ទុក និងជនទាំងឡាយ ដែលរស់នៅក្រោមដំបូលផ្ទះតែមួយ និងក្នុងបន្ទុកគ្រួសារនោះ (*មាត្រា ២ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥*)។

អំពើហិង្សាក្នុងគ្រួសារ ចែកចេញជា ៤ ប្រភេទ គឺ៖

- អំពើហិង្សាផ្លូវកាយ
- អំពើហិង្សាផ្លូវចិត្ត
- អំពើហិង្សាផ្លូវជីវភាពសេដ្ឋកិច្ច
- អំពើឈ្លានពានខាងផ្លូវភេទ។

### អំពើហិង្សាផ្លូវកាយ

អំពើហិង្សាផ្លូវកាយ សំដៅលើការប្រើប្រាស់កម្លាំងកាយទៅលើមនុស្សម្នាក់ទៀត ដែលនាំឱ្យមនុស្សម្នាក់នោះទទួលរងរបួស ឬធ្វើឱ្យមនុស្សម្នាក់នោះ ប្រឈមនឹងការរងរបួស។[4]

ឧទាហរណ៍៖ *ការចាប់ចង ការវាយដំនឹងដៃ ឬវត្ថុអ្វីមួយ ការខោកក្បាល ការទះកំផ្លៀង ការទះគូទ ការទាត់ធាក់ ការខាំ ការចាប់បោក គ្រវីគ្រវាត់ ការបោចសក់ក្បាល ការក្តិច ការចោលវត្ថុអ្វីមួយទៅលើ ការរុញច្រាន ការចាប់ទាញកន្ត្រាក់ ការដុត/អុជ ឬការធ្វើឱ្យរលាក ការគប់ ឬជះទឹកអាស៊ីដ ការបាញ់ ការធ្វើឃាត ការរំលោភសេពសន្ថវៈ និងការបង្ខិតបង្ខំឱ្យធ្វើទង្វើផ្លូវភេទ។*

4 សេចក្តីពន្យល់អំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ក្រសួងកិច្ចការនារី ឆ្នាំ ២០០៧ ទំព័រទី ៥៧។

## ការរំលោភបំពានផ្លូវចិត្ត

ការរំលោភបំពានផ្លូវចិត្ត អាចធ្វើឡើងដោយប្រើពាក្យសម្តី ឬមិនប្រើពាក្យសម្តី។ ការរំលោភបំពានផ្លូវចិត្ត រួមមានសកម្មភាព ឬឥរិយាបថ ដែលគេមិនសូវជាកត់សម្គាល់ឃើញ ប៉ុន្តែអាចបង្កគ្រោះថ្នាក់ ដូចការរំលោភបំពានផ្លូវកាយផងដែរ។ ជាទូទៅ ការរំលោភបំពានផ្លូវចិត្ត រួមមានអំពើទាំងឡាយ ដែលបង្កឱ្យមានការតានតឹងចិត្តដល់ជនរងគ្រោះ។[5]

ឧទាហរណ៍៖ *ការបំភិតបំភ័យ ការស្រែកគំហកដាក់ ការជេរប្រទេច ការប្រមាថមាក់ងាយ ការធ្វើទុក្ខបុកម្នេញ ការបន្ទាបបន្ថោក ឬការបង្ខូចកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គលម្នាក់តាមរយៈការគំរាមកំហែង ការប្រមាថមាក់ងាយ ឬការគំរាមកេប្រយោជន៍អ្វីមួយជាដើម។ ការគំរាមកំហែង ដោយប្រើវត្ថុ (ដូចជា កាំបិត ពូថៅ កាំភ្លើង ជាដើម) ការទុកឱ្យឯកោពីសាច់ញាតិ និងមិត្តភក្តិជិតស្និទ ការបង្ខិតបង្ខំឱ្យធ្វើសកម្មភាពអ្វីមួយ ដែលហួសពី ឬប្រឆាំងនឹងគោលបំណង ឆន្ទៈ ឬសមត្ថភាពរបស់ជននោះ។*

ឧទាហរណ៍៖ *ការហាមឃាត់បុគ្គលម្នាក់ចាកចេញពីផ្ទះជាដើម។*

## ការរំលោភបំពានផ្លូវភេទ

ការរំលោភបំពានផ្លូវភេទ រួមមានទង្វើបំពានទៅលើផ្លូវភេទ ឬសេរីភាពផ្លូវភេទរបស់មនុស្សណាម្នាក់។[6]

ឧទាហរណ៍៖ *បទប្រទូស្តកេរខ្មាស-ការបង្ខិតបង្ខំនរណាម្នាក់ឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទ ដែលគេមិនចង់បាន មិនមានសុវត្ថិភាព ឬជាទង្វើបន្ទាបបន្ថោកដល់ជននោះ។*

ឧទាហរណ៍៖ *អំពើធ្វើអាជីវកម្មផ្លូវភេទ-ការបង្ខិតបង្ខំនរណាម្នាក់ឱ្យមើលរូបភាព/សម្ភារអាសអាភាស ឬចូលរួមនៅក្នុងការផលិតភាពយន្តអាសអាភាសជាដើម។*

ឧទាហរណ៍៖ *លោក វេតនា បានគំរាមកំហែងវាយដំប្រពន្ធរបស់គាត់ ប្រសិនបើនាងមិនយល់ព្រមរួមភេទ នៅពេលដែលគាត់ចង់រួមភេទ បើទោះបីជាប្រពន្ធសំពះអង្វរគាត់យ៉ាងណាក៏ដោយ។*

---

5 សេចក្តីពន្យល់អំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ក្រសួងកិច្ចការនារី ឆ្នាំ ២០០៧ ទំព័រទី ៥៨។

6 សេចក្តីពន្យល់អំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ក្រសួងកិច្ចការនារី ឆ្នាំ ២០០៧ ទំព័រទី ៦០។

### អំពើហិង្សាផ្លូវជីវភាពសេដ្ឋកិច្ច

អំពើហិង្សាក៏អាចកើតឡើង នៅក្នុងរូបភាព ឬទម្រង់ជាអំពើហិង្សាខាងផ្នែកទ្រព្យសម្បត្តិ/ជីវភាពសេដ្ឋកិច្ច/ហិរញ្ញវត្ថុផងដែរ។ អំពើហិង្សាប្រភេទនេះ រួមមាន ទង្វើ ដែលរឹតត្បិតទៅលើសិទ្ធិរបស់ជនរងគ្រោះ នៅក្នុងការធ្វើជាម្ចាស់កម្មសិទ្ធិ ឬការកាន់កាប់ ដូចជា ការប្រើប្រាស់លំនៅឋាន អាហារ សម្លៀកបំពាក់ និងទ្រព្យសម្បត្តិ ប្រាក់ចំណូល លុយកាក់ ឬធនធាននានា។[7]

> ឧទាហរណ៍៖ *ប្ដីបានបោកទូរស័ព្ទរបស់ប្រពន្ធចោល ដោយសារតែគាត់ប្រច័ណ្ឌប្រពន្ធរបស់គាត់។*
>
> ឧទាហរណ៍៖ *ប្ដីបង្ខិតបង្ខំប្រពន្ធរបស់ខ្លួនឱ្យផ្ដល់លុយកាក់មកគាត់ ដើម្បីយកទៅផឹកស្រា ឬលេងល្បែងស៊ីសង។*
>
> ឧទាហរណ៍៖ *ការហាមឃាត់ប្រពន្ធ ឬដៃគូទៅធ្វើការងារ ឬជ្រើសរើសមុខរបរ/អាជីពអ្វីមួយ។*

## ការចូលធ្វើអន្តរាគមន៍

បើយោងតាមមាត្រា ៩ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ បានឱ្យដឹងថា អាជ្ញាធរដែលនៅជិតបំផុត ត្រូវតែចូលធ្វើអន្តរាគមន៍៖

*"អាជ្ញាធរមានសមត្ថកិច្ច ដែលនៅជិតបំផុត មានកាតព្វកិច្ចធ្វើអន្តរាគមន៍ជាបន្ទាន់ ក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារកើតឡើង ឬបម្រុងនឹងកើតឡើង ដើម្បីទប់ស្កាត់ និងការពារជនរងគ្រោះ។"*

### ភារកិច្ចរបស់ភាគី ដែលចូលរួមនៅក្នុងការធ្វើអន្តរាគមន៍ និងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ

ដើម្បីទប់ស្កាត់ និងចូលធ្វើអន្តរាគមន៍ នៅក្នុងករណីអំពើហិង្សាក្នុងគ្រួសារ គេអាចប្រើប្រាស់វិធីសាស្ត្រ ដូចខាងក្រោមនេះ (*មាត្រា ១៣ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥*)៖

---

7 សេចក្ដីពន្យល់អំពីច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ក្រសួងកិច្ចការនារី ឆ្នាំ ២០០៧ ទំព័រទី ៦១។

- ឃាត់ទុកអាវុធ ឬវត្ថុជាក់ស្តែង ដែលជនមុខសញ្ញាបាន ឬអាចប្រើប្រាស់។
- បង្វែរយកចេញជនមុខសញ្ញាពីកន្លែងកើតហេតុ ឬបង្វែរជនរងគ្រោះ បើមានការស្នើសុំពីជនរងគ្រោះ។ នៅក្នុងករណីពិសេស ជនរងគ្រោះអាចបង្វែរចេញបាន ដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ។
- ផ្តល់ឱ្យជនរងគ្រោះនូវជំនួយសមស្រប តាមកាលៈទេសៈ ជាពិសេសផ្តល់កន្លែងជម្រកបណ្តោះអាសន្ន ដែលអាចធានាសុវត្ថិភាព និងផ្តល់នូវជំនួយសុខាភិបាលជាបន្ទាន់។
- ពន្យល់ អប់រំ និងសម្រុះសម្រួលគូភាគីទាំងសងខាង ឱ្យបញ្ឈប់អំពើហិង្សា និងណែនាំជនរងគ្រោះអំពីសិទ្ធិរបស់ខ្លួន សម្រាប់ទប់ស្កាត់អំពើហិង្សា ដូចជា ការដាក់ពាក្យសុំដីកាការពារពីតុលាការ ដើម្បីបញ្ជាឱ្យជនមុខសញ្ញាឈប់ប្រព្រឹត្តអំពើហិង្សា ឬស្នើសុំឱ្យមានការផ្សះផ្សា និងការសម្រុះសម្រួលគ្នាជាដើម។

មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី អាចជួបជាមួយជនរងគ្រោះ ដើម្បីសួរនាំពីដំណើររឿងហេតុដែលកើតឡើង និងស្នើសុំឱ្យដាក់ឯកសារពាក់ព័ន្ធ ដើម្បីជួយរៀបចំពាក្យបណ្តឹងចូលមកក្រសួងកិច្ចការនារី/មន្ទីរកិច្ចការនារី តាមនីតិវិធីច្បាប់។

ចំពោះករណីមួយចំនួន ក្រសួង/មន្ទីរកិច្ចការនារី ក៏អាចអញ្ជើញភាគីម្ខាងទៀតមកសួរនាំពីរឿងរ៉ាវដែលកើតឡើង និងធ្វើការសម្រុះសម្រួលលើករណីអំពើហិង្សាក្នុងគ្រួសារ ឬស្នើសុំកុំឱ្យប្រព្រឹត្តអំពើហិង្សាតទៅទៀត (*ចំពោះករណីអំពើហិង្សាស្រាលតែប៉ុណ្ណោះ*)។

នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី បានដឹងថា ជនមុខសញ្ញាបានរំលោភលើដីកាការពាររបស់តុលាការ (*តាមរយៈព័ត៌មានពីជនរងគ្រោះ*) ត្រូវណែនាំទៅជនរងគ្រោះឱ្យផ្តល់ព័ត៌មានជាបន្ទាន់ ទៅមន្ត្រីនគរបាលយុត្តិធម៌ ដែលនៅជិតបំផុត ដើម្បីជួយធ្វើអន្តរាគមន៍ តាមនីតិវិធីច្បាប់។ ការឃាត់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងករណីនេះ មិនចាំបាច់សុំការអនុញ្ញាតពីព្រះរាជអាជ្ញាឡើយ (*មាត្រា ១៨ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ*)។

ដើម្បីការពារសន្តិសុខជនរងគ្រោះ អាជ្ញាធរមានសមត្ថកិច្ច[8] អាចចេញសេចក្តីសម្រេចរដ្ឋបាល និងចាត់វិធានការបណ្តោះអាសន្នស្របច្បាប់ ស្របតាមមាត្រា ៤៣ មាត្រា ៤៨ និងមាត្រា ៤៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ (*មាត្រា ១៤ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥*)។

8 អាជ្ញាធរមានសមត្ថកិច្ច ដែលមានសិទ្ធិចេញសេចក្តីសម្រេចរដ្ឋបាល គឺមេឃុំ/ចៅសង្កាត់។

# យន្តការដោះស្រាយករណីអំពើហិង្សាក្នុងគ្រួសារ

នៅក្នុងការជ្រើសរើសជម្រើសនានា ដើម្បីដោះស្រាយករណីអំពើហិង្សាក្នុងគ្រួសារ គូភាគីអាចជ្រើសរើសជម្រើស ដែលសមស្របទៅតាមកម្រិតធ្ងន់ធ្ងរនៃបទល្មើស។ ជម្រើសទាំងនោះរួមមាន៖

- ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ការដោះស្រាយតាមផ្លូវតុលាការ។

## ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

បើយោងតាមមាត្រា ២៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ បានឱ្យដឹងថា៖

*"ចំពោះបទល្មើស ដែលជាអំពើហិង្សាប៉ះពាល់ខាងផ្លូវចិត្ត ឬផ្លូវជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិមស្រាល ឬបទលហុ ការផ្សះផ្សា ឬសម្រុះសម្រួលអាចធ្វើទៅបានតាមការយល់ព្រមពីភាគីទាំងសងខាង។*

*សមាជិកគ្រួសារអាចជ្រើសរើសវិធីណាមួយ ដោយស្នើសុំឪពុកម្តាយ សាច់ញាតិ ព្រះសង្ឃចាស់ព្រឹទ្ធាចារ្យ មេភូមិ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើជាអ្នកអាជ្ញាកណ្តាល ដោះស្រាយបញ្ហា ដើម្បីថែរក្សាបាននូវភាពសុខដុមរមនាក្នុងគ្រួសារ តាមទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិ។"*

មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី មិនគួរលើកទឹកចិត្តឱ្យជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ស្វែងរកការសម្រុះសម្រួលគ្នា នៅក្នុងករណីដែលមានអំពើហិង្សាធ្ងន់ធ្ងរកើតឡើងនោះឡើយ ឧទាហរណ៍ ការទទួលរងរបួសផ្លូវកាយ ឬករណី ដែលបានកើតឡើងម្តងហើយម្តងទៀត។ ជាការពិត ពួកគេ ក៏មិនគួរមិនលើកទឹកចិត្តឱ្យជនរងគ្រោះស្វែងរកការលែងលះគ្នានោះទេ បើទោះបីជានៅក្នុងវប្បធម៌ខ្មែរ ពួកគេត្រូវតែបន្តរស់នៅក្រោមការមាក់ងាយ ចំពោះអ្នកដែលលែងលះគ្រួសារនៅក្នុងសង្គមខ្មែរយ៉ាងណាក៏ដោយ។

## ការដោះស្រាយតាមផ្លូវតុលាការ

បើយោងតាមមាត្រា ១៧ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ បានឱ្យដឹងថា គូភាគីមិនអាចជ្រើសរើសការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបានទេ នៅក្នុងករណីដែលអំពើហិង្សាក្នុងគ្រួសារ ត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋ ឬបទមជ្ឈិមធ្ងន់ធ្ងរ។ អំពើហិង្សា ដែលជាបទឧក្រិដ្ឋ ឬបទមជ្ឈិមធ្ងន់ធ្ងរ ត្រូវទទួលរងការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ។

√

ក្រសួងកិច្ចការនារី គួរមានគោលនយោបាយមួយ ដែលកំណត់ថា នៅក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី បានដឹងថា ករណីអំពើហិង្សាក្នុងគ្រួសារមួយគឺជាបទឧក្រិដ្ឋ ឬជាបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារីនោះ គួរតែរាយការណ៍អំពីករណីនេះទៅព្រះរាជអាជ្ញា បើទោះបីជាជនរងគ្រោះមិនចង់ដាក់ពាក្យបណ្តឹងយ៉ាងណាក៏ដោយ។

ប៉ុន្តែ ចំពោះបទមជ្ឈិមស្រាល ឬបទលហុវិញ ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជននោះ។ ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ កើតឡើងជាថ្មីម្តងទៀត ដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ តុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញារូបនោះ ស្របតាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានការស្នើសុំពីជនរងគ្រោះ ឱ្យលើកលែងការចោទប្រកាន់ក៏ដោយ (*មាត្រា ៣៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥*)។

កំណត់សម្គាល់៖ បើសំណុំរឿងនោះ ព្រះរាជអាជ្ញាមិនទាន់បានចោទប្រកាន់ជាស្ថាពរទេ ពេលនោះ គាត់អាចធ្វើការដោះលែងបានករណីបទល្មើសមជ្ឈិមស្រាល ឬបទលហុ។

# ជំពូកទី ៧ - ដីកាការពារ

ដីកាការពារ គឺជាសេចក្ដីសម្រេចមួយ ដែលចេញដោយសាលាដំបូងរាជធានី-ខេត្ត ទៅតាមការស្នើសុំរបស់ភាគីណាមួយ ដែលមានវិវាទអំពើហិង្សាក្នុងគ្រួសារ។

ដីកាការពារ គឺជាវិធានការច្បាប់ ដែលមានគោលបំណងផ្ដល់កិច្ចការពារជាបណ្ដោះអាសន្នដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ តាមរយៈការបង្គាប់បញ្ជាឱ្យជនមុខសញ្ញាមិនធ្វើអ្វីមួយ ឬធ្វើអ្វីមួយ។ គេអាចប្រើប្រាស់ដីកាការពារ ជាឧទាហរណ៍ ដើម្បីហាមឃាត់ជនមុខសញ្ញា ចូលទៅក្នុងផ្ទះ/ដើរតាមផ្លូវ ដែលនៅជិត/ធ្វើដំណើរនៅជិតទីកន្លែង ដែលជនរងគ្រោះរស់នៅ ប៉ុន្តែ គេក៏អាចស្នើសុំដីកាការពារនេះ សម្រាប់ទិដ្ឋភាពផ្សេងៗទៀតនៅក្នុងគ្រួសារផងដែរ។ ដីកាការពារ អាចត្រូវបានចេញដោយតុលាការ ទៅតាមការស្នើសុំរបស់ជនរងគ្រោះតែប៉ុណ្ណោះ។ ការស្នើសុំនេះ គឺអនុវត្តតាមច្បាប់រដ្ឋប្បវេណី។ មាត្រា ២០ កថាខណ្ឌទី ១ វាក្យ ខណ្ឌទី ២ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ បានចែងយ៉ាងច្បាស់លាស់ថា ដីកាការពារ គឺជាវិធានការផ្នែករដ្ឋប្បវេណី។ ដីកាការពារនេះ គឺ៖

- មិនមែនជាការចូលធ្វើអន្តរាគមន៍ ដោយអាជ្ញាធរសាធារណៈនោះទេ (ច្បាប់រដ្ឋបាល)
- មិនមែនជាការផ្ដន្ទាទោសអ្វីមួយ ទៅលើជនមុខសញ្ញានោះទេ (ច្បាប់ព្រហ្មទណ្ឌ)។

ប៉ុន្តែ នៅពេលដែលមានការរំលោភបំពានទៅលើដីកាការពារនេះ មានន័យថា ជនមុខសញ្ញាកំពុងប្រព្រឹត្តបទល្មើស (*មាត្រា ២៩ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥*)។

## ប្រភេទនៃដំណាក់កាលខុសៗគ្នានៃដីកាការពារ

ដីកាការពារ អាចចេញនៅដំណាក់កាលពីរផ្សេងគ្នា នៅក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារកើតឡើង។

### ដំណាក់កាលទី ១ - ដីកាការពារបណ្តោះអាសន្ន

តុលាការ អាចចេញដីកាការពារបណ្តោះអាសន្ន ដែលមានសុពលភាព រយៈពេលអតិបរមាចំនួន ២ ខែ។ ដីកាការពារនេះ ត្រូវចេញជាវិធានការជាបណ្តោះអាសន្ន នៅក្នុងពេលដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងភ្លាមៗ (*មាត្រា ២៣ នៃច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥*)។

ឧទាហរណ៍៖ *លោកស្រី នារី គឺជាជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ នៅពេលដែលស្វាមីរបស់គាត់ វាយដំគាត់ចំមុខ បង្កឱ្យមានស្នាមជាំ ក្រោយពេលដែលគាត់វិលត្រឡប់មកដល់ផ្ទះវិញ ក្នុងស្ថានភាពស្រវឹងស្រា។ លោកស្រី នារី ជឿជាក់ថា ប្តីរបស់គាត់នឹងវាយដំគាត់ជាថ្មីម្តងទៀត ប្រសិនបើគាត់ស្រវឹងស្រាលើកក្រោយ។ លោកស្រី នារីដាក់ពាក្យទៅតុលាការ ដើម្បីស្នើសុំដីកាការពារ ដើម្បីហាមឃាត់ប្តីរបស់គាត់ចូលទៅក្នុងផ្ទះ និងធ្វើដំណើរតាមផ្លូវនៅជិតផ្ទះរបស់គាត់។*

### ដំណាក់កាលទី ២ - ដីកាការពារធម្មតា

បើយោងតាមមាត្រា ២៣ កថាខណ្ឌទី ២ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ បានឱ្យដឹងថា ដីកាការពារធម្មតា មានសុពលភាពរហូតដល់ ៦ ខែ ហើយត្រូវបានចេញនៅក្នុងពេល ដែលតុលាការកំពុងតែស៊ើបសួរលើករណីអំពើហិង្សាក្នុងគ្រួសារ នៅពេលដែលមិនទាន់មានការជំនុំជម្រះនៅឡើយ ឬមុនពេលដែលមានការប្រកាសសាលក្រមជាស្ថាពរ។

ឧទាហរណ៍៖ *នៅក្នុងកំឡុងពេលស៊ើបសួរលើបទព្រហ្មទណ្ឌ ចំពោះករណី ដែលលោក វាសនាវាយដំប្រពន្ធរបស់គាត់ ដែលនាំឱ្យបែកក្បាលធ្ងន់ធ្ងរ តុលាការចេញដីកាការពារ ដោយតម្រូវឱ្យជនមុខសញ្ញា មិនត្រូវដាក់លក់អចលនទ្រព្យរបស់ខ្លួន និងហាមឃាត់ជនមុខសញ្ញាចូលទៅក្នុងទីកន្លែង ដែលជនរងគ្រោះស្នាក់នៅក្នុងរយៈពេល ៦ ខែ។*

## អ្នកដាក់ពាក្យបណ្តឹងសុំដីកាការពារ

បើយោងតាមមាត្រា ២២ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ បានឱ្យដឹងថា បុគ្គលដែលមានសិទ្ធិដាក់ពាក្យបណ្តឹងសុំដីកាការពាររួមមាន៖

- ជនរងគ្រោះ ឬតំណាងជនរងគ្រោះ ឬអាជ្ញាធរមានសមត្ថកិច្ចនៃលំនៅឋានជនរងគ្រោះ ឬមន្ត្រីភ្នាក់ងារ ដែលបំពេញការងារនៅកន្លែងកើតហេតុ។
- ជនណាម្នាក់ ដែលបានដឹងពីឧបទ្ទវហេតុនៃអំពើហិង្សាក្នុងគ្រួសារ ប្រសិនបើជនរងគ្រោះជាកុមារ ជាជនវិកលចរិត ឬជាជនដែលតុលាការយល់ថា គ្មានលទ្ធភាពធ្វើពាក្យបណ្តឹងដោយខ្លួនឯងបាន។

√ មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី ក៏អាចស្នើសុំដីកាការពារបានផងដែរ។ នៅក្នុងគោលនយោបាយរបស់ក្រសួងកិច្ចការនារី ដីកាការពារទាំងអស់នេះអាចត្រូវបានស្នើសុំ ក្នុងនាមជនរងគ្រោះ តែនៅពេលដែលជនរងគ្រោះយល់ព្រមតែប៉ុណ្ណោះ។

## កិច្ចការពារ ដែលអាចបង្គាប់បញ្ជាទៅលើ

មាត្រា ២៥ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ បានចែងថា តុលាការមានសិទ្ធិកំណត់បញ្ជា ដូចខាងក្រោមនេះ៖

- ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ។
- ហាមចូលទៅជិត ឬចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច។
- ហាមជនមុខសញ្ញាទាក់ទងជាមួយជនរងគ្រោះ តាមផ្លូវណាមួយ។
- ហាមបំផ្លាញទ្រព្យ ឬចាត់ចែងលក់ទ្រព្យរបស់ជនរងគ្រោះ ឬញាតិសាលោហិតរបស់ជនរងគ្រោះ។
- បំបែកជនមុខសញ្ញាពីលំនៅឋានរួម ឬបំបែកជនរងគ្រោះ បើមានការស្នើសុំ។ ក្នុងករណីពិសេស ជនរងគ្រោះអាចបង្វែរចេញបាន ដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ។

បើយល់ថាជាការចាំបាច់សម្រាប់ការពារ ឬរៀបចំសុវត្ថិភាព សុខភាព និងសុខុមាលភាពជនរងគ្រោះ តុលាការអាចបង្គាប់ ដោយចាត់វិធានការបន្ថែមទៀត ដូចតទៅ៖

- បញ្ជាឱ្យភ្នាក់ងារនគរបាល ឬកងរាជអាវុធហត្ថណាម្នាក់ការពារបេតិកភណ្ឌផ្ទាល់ខ្លួនរបស់ជនរងគ្រោះ។
- សម្រេចអំពីការថែរក្សាកូន និងអំពីសិទ្ធិទៅសួរសុខទុក្ខកូន ដោយគិតយ៉ាងខ្ពស់បំផុតពីសិទ្ធិ និងផលប្រយោជន៍នៃកុមារនោះ។
- បញ្ចប់កាតព្វកិច្ចហិរញ្ញវត្ថុនៃជនរងគ្រោះ ចំពោះជនមុខសញ្ញា។
- កំហិតឱ្យជនមុខសញ្ញាផ្តល់ជំនួយហិរញ្ញវត្ថុ ឱ្យជនរងគ្រោះដោយផ្អែកតាមលទ្ធភាពធនធាននៃជនមុខសញ្ញា។

ឧទាហរណ៍៖ *លោកស្រី ធី តែងតែត្រូវបានប្តីរបស់គាត់វាយដំ។ ចុងក្រោយ នាងមិនអាចទ្រាំទ្របានតទៅទៀត នាងក៏រាយការណ៍ទៅនគរបាល ហើយ ក្រោយពីការស៊ើបសួររួច សំណុំរឿងនេះត្រូវបានបញ្ជូនទៅជំនុំជម្រះ។ មេធាវីរបស់លោកស្រី ធី ផ្តល់ដំបូន្មានឱ្យគាត់ដាក់ពាក្យបណ្តឹង ដោយស្នើសុំថា ប្តីរបស់គាត់មិនអាចចូលទៅក្នុងផ្ទះគាត់ គាត់សុំគ្រប់គ្រងកូន និងសុំឱ្យប្តីរបស់គាត់បង់ប្រាក់អាហារកាតព្វកិច្ច សម្រាប់រយៈពេលនេះ។ តាមការស្នើសុំរបស់គាត់ មេធាវីរបស់លោកស្រី ធី ក៏ចាប់ផ្តើមដំណើរការដាក់ពាក្យប្តឹងសុំលែងលះគ្នាផងដែរ។*

## អានុភាពនៃដីកាការពារ

ដីកាការពារមានអានុភាពភ្លាម ក្រោយពេលចេញដោយតុលាការរួចមក។ លើសពីនេះ ដីកាការពារនេះ មានអានុភាពបង្គាប់បញ្ជាទៅលើជនមុខសញ្ញា អាជ្ញាធរមានសមត្ថកិច្ច និងជនដែលពាក់ព័ន្ធនឹងរឿងក្តីនេះ។

នៅក្នុងករណី ដែលភាគីណាមួយមិនសុខចិត្តនឹងដីកាការពារនេះ ភាគីនោះ អាចដាក់ពាក្យប្តឹងជំទាស់ ទៅតុលាការឱ្យពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងយូរ ២ ខែ ចាប់ពីថ្ងៃចេញដីកាការពារនេះ ( *មាត្រា ៣០ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥*)។

# ជំពូកទី ៨ - អាពាហ៍ពិពាហ៍ និងការលែងលះគ្នា

ការវិភាគអំពីការលែងលះគ្នា ដោយសង្កត់ធ្ងន់ទៅលើជំហានទាំងឡាយ ដើម្បីកំណត់អំពីក្របខ័ណ្ឌច្បាប់ណា ដែលអាចយកទៅអនុវត្តចំពោះប្រភេទផ្សេងៗនៃការលែងលះគ្នា។

## អាពាហ៍ពិពាហ៍

ក្រមរដ្ឋប្បវេណី ត្រូវបានអនុម័តនៅថ្ងៃទី ០៥ ខែតុលា ឆ្នាំ ២០០៧ និងត្រូវបានប្រកាសឱ្យប្រើដោយច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី នៅថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១១។

នៅប្រទេសកម្ពុជា ប្រជាពលរដ្ឋ តែងតែមានការភាន់ច្រឡំ រវាងអាពាហ៍ពិពាហ៍ពេញលេញតាមផ្លូវច្បាប់ និងអាពាហ៍ពិពាហ៍ជាលក្ខណៈប្រពៃណី។ ប៉ុន្តែ បើយើងពិនិត្យមើលទៅលើផលវិបាកតាមផ្លូវច្បាប់នៃអាពាហ៍ពិពាហ៍ ពាក្យថា សហព័ទ្ធ ឬប្ដី និងប្រពន្ធ គឺនិយាយយោងទៅលើបុរសម្នាក់ និងស្ត្រីម្នាក់ ដែលបានចុះបញ្ជីអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃក្រុមប្រឹក្សាឃុំ-សង្កាត់ ( *យោងតាមមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី*)។

ឧទាហរណ៍៖ *លោក វណ្ណៈ និងកញ្ញា ធីតា បានរៀបការនឹងគ្នាតាមបែបប្រពៃណី ប៉ុន្តែពួកគេទាំងពីរនាក់បានភ្លេចទៅចុះបញ្ជីអាពាហ៍ពិពាហ៍របស់ខ្លួន នៅក្រុមប្រឹក្សាឃុំ-សង្កាត់។ បើតាមផ្លូវច្បាប់ ពួកគេមិនបានរៀបការនឹងគ្នានោះទេ ហើយពួកគេទាំងពីរនាក់ ក៏មិនអាចត្រូវបានចាត់ទុកថាជាប្ដីប្រពន្ធស្របច្បាប់បានដែរ។*

ឧទាហរណ៍៖ *លោក សុភាព និងកញ្ញា បុផាណា មិនបានរៀបការនឹងគ្នាតាមបែប ប្រពៃណីទេ ប៉ុន្តែ ពួកគេទាំងពីរនាក់បានព្រមព្រៀងគ្នាថា នឹងរស់នៅជាមួយគ្នាជាប្ដីប្រពន្ធ ហើយបានទៅចុះបញ្ជីអាពាហ៍ពិពាហ៍របស់ខ្លួនតាមផ្លូវច្បាប់ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ បើយោងតាមច្បាប់ លោក សុភាព និងនាង បុផាណា គឺជាសហព័ទ្ធ ស្របច្បាប់។*

√

ក្រសួងកិច្ចការនារី គួរតែលើកទឹកចិត្តស្ត្រីឱ្យទៅចុះបញ្ជីអាពាហ៍ពិពាហ៍របស់ខ្លួន ហើយជូនដំណឹងដល់ពួកគេ អំពីផលវិបាកនៃការមិនទៅចុះបញ្ជីអាពាហ៍ពិពាហ៍។ អាពាហ៍ពិពាហ៍ពេញលេញតាមផ្លូវច្បាប់ ផ្តល់សិទ្ធិនៅក្នុងការកាន់កាប់ទ្រព្យសម្បត្តិរួម ការទទួលបានអាហារកាតព្វកិច្ច និងការជួយឧបត្ថម្ភកូន។ ប្រសិនបើអាពាហ៍ពិពាហ៍របស់ពួកគាត់មិនត្រូវបានចុះបញ្ជីទេ តុលាការ អាចអនុញ្ញាតឱ្យភាគីទាំងពីរផ្តាច់សង្វាស ប្រសិនបើមានមូលហេតុស្របតាមច្បាប់កំណត់។ ចំពោះការបែងចែកទ្រព្យសម្បត្តិរួម គឺតុលាការទុកលទ្ធភាពឱ្យគូភាគីទាំងពីរយល់ព្រម ក្នុងការបែងចែកទ្រព្យសម្បត្តិរួមនេះ ប៉ុន្តែ បើភាគីណាមួយមិនយល់ព្រមទេនោះ តុលាការអាចសម្រេចបែងចែកទ្រព្យសម្បត្តិរួម ទៅតាមឆន្ទានុសិទ្ធិរបស់តុលាការ។ ចំណែកការបែងចែកកូន និងអាហារកាតព្វកិច្ចចិញ្ចឹមកូន ក៏ដូចជាចំណុចខាងលើដែរ បើភាគីទាំងពីរមិនឯកភាពគ្នាទេ តុលាការនឹងសម្រេចតាមឆន្ទានុសិទ្ធិ និងស្របតាមនីតិវិធីច្បាប់។

ប្តីប្រពន្ធណា ដែលមានបំណងចង់រៀបការនឹងគ្នា ពួកគេអាចរៀបការដោយសេរី។ ប៉ុន្តែ មានលក្ខខណ្ឌមួយចំនួន ដែលត្រូវបំពេញនៅក្នុងក្រមរដ្ឋប្បវេណី។

### ១. លក្ខខណ្ឌទាក់ទងនឹងអាយុ

បើយោងតាមមាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណី បានឱ្យដឹងថា បុរស និងនារី ដែលមិនទាន់ដល់នីតិភាព (*អាយុ ១៨ ឆ្នាំ*) មិនអាចរៀបអាពាហ៍ពិពាហ៍នឹងគ្នាបានឡើយ។ ប៉ុន្តែ ប្រសិនបើភាគីម្ខាងដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជន ដែលមានអាយុមិនតិចជាង ១៦ ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយមានការយល់ព្រមពីអ្នក ដែលមានអំណាចមេបា ឬអាណាព្យាបាល សម្រាប់អនីតិជននោះ។ ប្រសិនបើភាគីម្ខាងជាអនីតិជន មានបំណងចង់រៀបអាពាហ៍ពិពាហ៍ គេត្រូវតែបំពេញនូវលក្ខខណ្ឌ ដូចខាងក្រោមនេះ៖

- អនីតិជននោះត្រូវមានអាយុយ៉ាងតិច ១៦ ឆ្នាំឡើងទៅ
- ភាគីម្ខាងទៀត ដែលដល់នីតិភាព

- ចំពោះភាគី ដែលជាអនីតិជន ត្រូវតែមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជននោះ (*មាត្រា ៩៥៣ នៃក្រមរដ្ឋប្បវេណី*)។ ប្រសិនបើអ្នក ដែលមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជននោះ បដិសេធចំពោះការរៀបអាពាហ៍ពិពាហ៍របស់អនីតិជនដោយគ្មានមូលហេតុត្រឹមត្រូវ អនីតិជននោះអាចដាក់ពាក្យស្នើសុំទៅតុលាការ ឱ្យសម្រេចជំនួសអ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលរបស់ខ្លួនបាន (*មាត្រា ៩៥៣ នៃក្រមរដ្ឋប្បវេណី*)។ ប៉ុន្តែ អនីតិជន ដែលមានអាយុ ១៦ ឆ្នាំ ឬ ១៧ ឆ្នាំ ដែលអាចទ្រទ្រង់ជីវភាពដោយឯករាជដោយខ្លួនឯងបាន ហើយមានបំណងចង់រៀបអាពាហ៍ពិពាហ៍ អាចដាក់ពាក្យស្នើសុំអត្តាធិកាពទៅតុលាការបាន។ ក្រោយពេល ដែលអនីតិជនបានទទួលអត្តាធិកាពពីតុលាការហើយ អនីតិជននោះត្រូវបានចាត់ទុកថាដល់នីតិភាពហើយ។ ហេតុដូច្នេះហើយ អនីតិជននោះ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយពុំចាំបាច់មានការយល់ព្រម ពីអ្នក ដែលមានអំណាចមេបា ឬអាណាព្យាបាលឡើយ។

## ២. លក្ខខណ្ឌទាក់ទងនឹងសមត្ថភាព

សមត្ថភាពបង្ហាញឆន្ទៈ គឺជាមូលដ្ឋានគ្រឹះក្នុងការធ្វើឱ្យកើតមាននូវអាពាហ៍ពិពាហ៍នេះឡើង។ ហេតុដូច្នេះហើយ ប្រសិនបើភាគីណាមួយមានបំណងចង់រៀបអាពាហ៍ពិពាហ៍ បុគ្គលនោះត្រូវតែជាជន ដែលមានសមត្ថភាពបង្ហាញឆន្ទៈ។ ប៉ុន្តែ ប្រសិនបើជននោះមិនមានសមត្ថភាពបង្ហាញឆន្ទៈ ក្នុងកម្រិតអប្បបរមាទេ គឺ មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ជនដែលមានវិបត្តិផ្នែកស្មារតី នៅក្រោមរបបអាណាព្យាបាលទូទៅ គឺមិនអាចមានសមត្ថភាព បង្ហាញឆន្ទៈ ហើយខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន គឺមិនអាចរៀបអាពាហ៍ពិពាហ៍បានទេ។ ប៉ុន្តែប្រសិនបើជននោះ មានសមត្ថភាពបង្ហាញឆន្ទៈក្នុងកម្រិតអប្បបរមា ដែលចាំបាច់សម្រាប់ការរៀបអាពាហ៍ពិពាហ៍ គឺអាចរៀបអាពាហ៍ពិពាហ៍បាន ដោយពុំចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ (*មាត្រា ៩៥៤ នៃក្រមរដ្ឋប្បវេណី*)។

ឧទាហរណ៍៖ *លោក វាសនា មានអាយុ ២៥ ឆ្នាំ និងកញ្ញា លីនដា មានអាយុ ២០ ឆ្នាំ មានគម្រោងរៀបការនឹងគ្នា។ នៅថ្ងៃមួយ លោក វាសនា បានជួបប្រទះនូវគ្រោះថ្នាក់ចរាចរ បណ្ដាលឱ្យប៉ះទង្គិចផ្នែកស្មារតី ហើយមិនអាចដឹងខុសត្រូវបាន។ ហេតុដូច្នេះហើយ ទើបមានការប្រកាសដាក់ លោក វាសនា នៅក្រោមរបបអាណាព្យាបាលទូទៅនៃម្ដាយមីង។ រយៈពេល ៣ ខែក្រោយមក ស្ថានភាពរបស់លោកបានល្អប្រសើរឡើងវិញ ប៉ុន្តែ មិនទាន់ជាសះស្បើយនៅឡើយ។ ក្នុងករណីបែបនេះ ប្រសិនបើលោក វាសនា អាចបង្ហាញឆន្ទៈរៀបអាពាហ៍ពិពាហ៍ជាមួយកញ្ញា ដាលីន បាននៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នោះលោក វាសនា និងកញ្ញា ដាលីន អាចរៀបអាពាហ៍ពិពាហ៍បាន ដោយមិនចាំបាច់មានការយល់ព្រមពីម្ដាយមីងរបស់លោក វាសនា ឡើយ។*

## ៣. លក្ខខណ្ឌទាក់ទងនឹងទ្វេពន្ធភាព

ទ្វេពន្ធភាព (*មានប្រពន្ធពីរ ឬប្ដីពីរ*) ត្រូវបានហាមឃាត់ (*មាត្រា ៩៤៩ នៃក្រមរដ្ឋប្បវេណី*)។ ហេតុដូច្នេះហើយ បុរស និងស្ត្រី ដែលមានប្ដី ឬប្រពន្ធ ហើយមិនទាន់បានរំលាយ ចំណងអាពាហ៍ពិពាហ៍មុន មិនអាចរៀបអាពាហ៍ពិពាហ៍ជាថ្មីទៀតបានឡើយ។ ការបំពានទៅលើបម្រាមនេះ នឹងត្រូវទទួលទណ្ឌកម្មជាទោសព្រហ្មទណ្ឌ។ ការរៀបអាពាហ៍ពិពាហ៍ជាថ្មីទៀតបានលុះត្រាតែចំណងអាពាហ៍ពិពាហ៍មុន ត្រូវបានរំលាយរួចហើយ (*មាត្រា ៤ នៃច្បាប់ស្ដីពីឯកពន្ធភាព ឆ្នាំ ២០០៦*)។

ឧទាហរណ៍៖ *លោក វណ្ណៈ និងនាង ធីតា ដែលមិនបានទៅចុះបញ្ជីអាពាហ៍ពិពាហ៍របស់ខ្លួននៅក្រុមប្រឹក្សាឃុំ-សង្កាត់ បានសម្រេចចិត្តរស់នៅបែកគ្នា។ ជាគោលការណ៍ អ្នកទាំងពីរមានសិទ្ធិរៀបការបាន។*

ឧទាហរណ៍៖ *លោក សុភាព និងនាង បុផាណា ដែលបានទៅចុះបញ្ជីអាពាហ៍ពិពាហ៍របស់ខ្លួន នៅក្រុមប្រឹក្សាឃុំ-សង្កាត់នោះ មិនមានការសប្បាយចិត្តនោះទេ។ លោក សុភាព ចង់ចាកចេញពីនាង បុផាណា ហើយទៅរៀបការជាមួយស្ត្រីកំណាន់របស់គាត់។ លោក សុភាព មិនអាចរៀបការជាមួយស្ត្រីកំណាន់របស់ខ្លួន ដោយមិនលែងលះគ្នានៅតុលាការជាមុនបានទេ។*

ប្រសិនបើស្ត្រី ដែលបានដាក់ពាក្យប្ដឹងសុំលែងលះគ្នាជាមួយប្ដី មានបំណងចង់រៀបការជាថ្មីទៀតនោះ គឺច្បាប់តម្រូវឱ្យស្ត្រី ដែលបានដាក់ពាក្យប្ដឹងសុំលែងលះគ្នានោះ ត្រូវរង់ចាំក្នុងរយៈពេល ១២០ ថ្ងៃ បន្ទាប់ពីចំណងអាពាហ៍ពិពាហ៍មុន ត្រូវបានរំលាយ ឬលុបចោល។ បន្ទាប់ពីរយៈពេលនេះកន្លងផុតទៅ ស្ត្រីនោះអាចរៀបអាពាហ៍ពិពាហ៍ជាថ្មីទៀតបាន។ ក្នុងករណីដែលស្ត្រីនោះមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត នៅក្នុងអំឡុងពេលដែលច្បាប់បានហាមឃាត់ លុះត្រាតែស្ត្រីនោះមានលិខិតបញ្ជាក់ពីគ្រូពេទ្យថា ស្ត្រីនោះគ្មានផ្ទៃពោះទេ (*មាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី*)។

## ៤. លក្ខខណ្ឌទាក់ទងនឹងញាតិភាព

ការរៀបអាពាហ៍ពិពាហ៍ គឺមិនអាចធ្វើទៅបានឡើយ រវាងញាតិលោហិតផ្ទាល់ (*ដូចជា កូន/ចៅ ឬឪពុកម្ដាយ/ជីដូនជីតា*) ឬបងប្អូនបង្កើត (*ដូចជា សាខាញាតិលោហិតក្នុងបីថ្នាក់*) (*មាត្រា ៩៥១ នៃក្រមរដ្ឋប្បវេណី*)។

## ៥. លក្ខខណ្ឌទាក់ទងនឹងភេទ

បើទោះបីជាក្រមរដ្ឋប្បវេណី មិនបានហាមឃាត់យ៉ាងច្បាស់លាស់អំពីការរៀបអាពាហ៍ពិពាហ៍ ចំពោះអ្នកដែលមានភេទដូចគ្នាក៏ដោយ ក៏គេបានសន្មតជាទូទៅថា ការរៀបអាពាហ៍ពិពាហ៍ចំពោះអ្នកដែលមានភេទដូចគ្នា មិនអាចធ្វើឡើងបានទេ នៅក្រោមច្បាប់កម្ពុជា។

## ការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍[៩]

មុនពេលរៀបអាពាហ៍ពិពាហ៍ បុរស និងស្ត្រីត្រូវធ្វើលិខិតបញ្ជាក់អំពីភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ ដោយមិនជាប់ពាក់ព័ន្ធជាមួយបុគ្គលណាម្នាក់ឡើយ។ បន្ទាប់មក បុរស និងស្ត្រីនោះត្រូវដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ ទៅមន្ត្រីអត្រានុកូលដ្ឋាននៃក្រុមប្រឹក្សាឃុំ-សង្កាត់នៃលំនៅឋានរបស់ស្ត្រី (*មាត្រា ២៨ នៃអនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០*)។ បន្ទាប់ពីមន្ត្រីអត្រានុកូលដ្ឋានទទួលបានពាក្យស្នើសុំនេះរួចហើយ មន្ត្រីអត្រានុកូលដ្ឋាននោះ ត្រូវចេញលិខិតអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ និងប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលនឹងត្រូវយកទៅបិទផ្សាយជាសាធារណៈនៅក្នុងរយៈពេល ១០ ថ្ងៃ នៅលំនៅឋាន ឬឃុំ-សង្កាត់ខាងភាគីស្ត្រី និងបុរស ដើម្បីឱ្យភាគីទីបី (តតិយជន) អាចប្ដឹងជំទាស់បាន។ បន្ទាប់ពីរយៈពេល ១០ ថ្ងៃបានកន្លងផុតទៅ ការប្ដឹងជំទាស់មិនអាចធ្វើឡើងតទៅទៀតបានទេ ហើយអាពាហ៍ពិពាហ៍នោះ អាចប្រព្រឹត្តទៅបាន។

---

៩ អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្ដីពីអត្រានុកូលដ្ឋាន ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០០

ចំពោះការចុះបញ្ជីអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ បុរស និងស្ត្រី ដែលបានរៀបអាពាហ៍ពិពាហ៍ ត្រូវទៅចុះបញ្ជីអាពាហ៍ពិពាហ៍របស់ខ្លួននៅក្នុងសៀវភៅអាពាហ៍ពិពាហ៍នៅក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយមានសាក្សីគ្រប់ការ ២ នាក់។ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់សំបុត្រអាពាហ៍ពិពាហ៍មួយច្បាប់ ដល់ប្តីប្រពន្ធនោះ។

## អានុភាពនៃអាពាហ៍ពិពាហ៍

ប្តីប្រពន្ធ អាចប្រើនាមត្រកូលរបស់ប្តី ឬប្រពន្ធ ឬអាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន (*មាត្រា ៩៦៥ នៃក្រមរដ្ឋប្បវេណី*)។

ប្តី និងប្រពន្ធមានករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក (*មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណី*) ពួកគេមានសេរីភាពក្នុងការជ្រើសរើសមុខរបររបស់ខ្លួន និងចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ និងសង្គម ដោយឯករាជបាន (*មាត្រា ៩៦៧ នៃក្រមរដ្ឋប្បវេណី*)។

លុះត្រាតែប្តីប្រពន្ធបានឯកភាពគ្នា នៅក្នុងកិច្ចព្រមព្រៀងមួយ នៅមុន ឬក្រោយការរៀបអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិរបស់សហព័ទ្ធទាំងពីរស្ថិតនៅក្រោមប្រព័ន្ធទ្រព្យសម្បត្តិរួម ដែលកំណត់ដោយច្បាប់ (*មាត្រា ៩៦៩ និងមាត្រា ៩៧០ នៃក្រមរដ្ឋប្បវេណី*)។ ប្រព័ន្ធទ្រព្យសម្បត្តិរួម ដែលកំណត់ដោយច្បាប់នេះ មានបញ្ញត្តិដូចខាងក្រោមនេះ៖

- ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ (*មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី*)។
- ប្តីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយ ដែលកើតចេញពីអាពាហ៍ពិពាហ៍ ដោយពិចារណាទៅលើទ្រព្យសម្បត្តិ/ប្រាក់ចំណូល (*មាត្រា ៩៧១ នៃក្រមរដ្ឋប្បវេណី*)។

ប្តីប្រពន្ធ ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា។ ប្រសិនបើពួកគេ មិនអាចឯកភាពគ្នាអំពីការគ្រប់គ្រងទ្រព្យសម្បត្តិរួមទេនោះ ពួកគេអាចទាមទារទៅតុលាការឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិរួមនេះបាន (*មាត្រា ៩៧៤ នៃក្រមរដ្ឋប្បវេណី*)។ ទ្រព្យសម្បត្តិរួមនេះ មិនអាចយកទៅលក់ ឬធ្វើការចាត់ចែងផ្សេងទៀត ដោយគ្មានការយល់ព្រម ពីប្តីប្រពន្ធទាំងសងខាងបានឡើយ (*មាត្រា ៩៧៦ នៃក្រមរដ្ឋប្បវេណី*)។

ទ្រព្យសម្បត្តិដោយឡែក ត្រូវបានកំណត់ដូចខាងក្រោមនេះ៖

ក). ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍។

ខ). ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

គ). ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិ ដែលបានកំណត់ក្នុងចំណុច (ក) និងចំណុច (ខ) ខាងលើនេះ (*មាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណី*)។

## មោឃភាពនៃអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍នឹងត្រូវចាត់ទុកជាមោឃៈ តែក្នុងករណីដូចខាងក្រោមនេះ៖

- ប្រសិនបើគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ រវាងភាគីដោយសារការភាន់ច្រឡំលើមនុស្ស ការបង្ខំ និងមូលហេតុផ្សេងទៀត។

ឧទាហរណ៍៖ *ឪពុកម្តាយបានបង្ខិតបង្ខំកូនស្រីរបស់ខ្លួនឱ្យរៀបការជាមួយបុរសម្នាក់ដែលនាងមិនស្រឡាញ់។*

- ប្រសិនបើភាគី មិនបានអនុវត្តតាមនីតិវិធីរៀបអាពាហ៍ពិពាហ៍ឱ្យបានត្រឹមត្រូវ។ ប៉ុន្តែ ប្រសិនបើគ្រាន់តែមានវិការៈតែបន្តិចបន្តួច ទៅលើនីតិវិធីប៉ុណ្ណោះទេ អានុភាពនៃអាពាហ៍ពិពាហ៍នេះ មិនត្រូវបានរាំងដោយសារមូលហេតុនោះឡើយ (*មាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណី*)។

ឧទាហរណ៍៖ *លោក ចិន្តា និងនាង ឡែន បានរៀបការនឹងគ្នាដោយពេញលេញតាមផ្លូវច្បាប់ ប៉ុន្តែ ក្រោយមក ពួកគេបានដឹងថា សាក្សីម្នាក់ក្នុងចំណោមសាក្សីគ្រប់ការទាំងពីរនាក់របស់ពួកគេ គឺជាអនីតិជន ដែលមានអាយុត្រឹមតែ ១៧ ឆ្នាំ តែប៉ុណ្ណោះ នៅក្នុងពេលរៀបការនោះ។ នេះគឺមិនមែនជាកំហុសធ្ងន់ធ្ងរមួយទៅលើនីតិវិធីរៀបអាពាហ៍ពិពាហ៍នោះទេ ហើយអាពាហ៍ពិពាហ៍នេះត្រូវបានចាត់ទុកថាមានសុពលភាពតាមផ្លូវច្បាប់។*

## ការលុបចោលអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ អាចត្រូវបានលុបចោល ក្នុងករណីដូចខាងក្រោមនេះ៖

### ១. អាពាហ៍ពិពាហ៍ ដែលមិនត្រឹមត្រូវតាមច្បាប់ (*មាត្រា ៩៥៩-៩៦៣ នៃក្រមរដ្ឋប្បវេណី*)

- អាពាហ៍ពិពាហ៍ ដែលត្រូវបានធ្វើឡើងជាមួយអនីតិជន ដោយគ្មានការអនុញ្ញាតត្រឹមត្រូវ។
- អាពាហ៍ពិពាហ៍ ដែលត្រូវបានធ្វើឡើងរវាងញាតិពន្ធ ដែលបានហាមឃាត់។
- ប្រសិនបើការរៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត ត្រូវបានចុះបញ្ជីនៅក្នុងអំឡុងពេល ដែលចំណងអាពាហ៍ពិពាហ៍មុនមិនទាន់ត្រូវបានរំលាយ។
- ប្រសិនបើការរៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត ត្រូវបានចុះបញ្ជីនៅក្នុងអំឡុងពេលដែលច្បាប់បានហាមឃាត់ (ស្ត្រីត្រូវនៅមេម៉ាយ រយៈពេល ១២០ ថ្ងៃ)។ ក្នុងករណីនេះ សហព័ទ្ធរបស់ភាគី ឬសហព័ទ្ធមុននោះ អាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានដែរ។

### ២. អាពាហ៍ពិពាហ៍ ដែលធ្វើឡើងដោយការឆបោក ឬការគំរាម (*មាត្រា ៩៦៣ នៃក្រមរដ្ឋប្បវេណី*)

អាពាហ៍ពិពាហ៍ ដែលធ្វើឡើងដោយការឆបោក ឬការគំរាម អាចត្រូវបានលុបចោល។ សិទ្ធិទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍របស់ជនរងគ្រោះនៃការឆបោក ឬការគំរាមនេះត្រូវរលត់ បន្ទាប់ពីរយៈពេល ៣ ខែបានកន្លងផុត ចាប់តាំងពីភាគីបានរកឃើញការឆបោក ឬបានរួចផុតពីការគំរាម ឬប្រសិនបើភាគីបានធ្វើសច្ចានុមតិ នៅក្នុងពេលក្រោយមក បានព្រមព្រៀងរៀបអាពាហ៍ពិពាហ៍។

### អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍ ពុំមានអានុភាពទៅលើអតីតកាលឡើយ។ វាមានន័យថា ការលុបចោលនោះ នឹងមានអានុភាពតែទៅលើអនាគតកាលតែប៉ុណ្ណោះ ហើយមិនអាចស្តារស្ថានភាពរបស់ខ្លួនឡើងវិញ មុនពេលរៀបអាពាហ៍ពិពាហ៍បានឡើយ (*មាត្រា ៩៦៤ នៃក្រមរដ្ឋប្បវេណី*)។

ឧទាហរណ៍៖ *កូន ដែលកើតនៅក្នុងពេលដែលអាពាហ៍ពិពាហ៍ត្រូវបានលុបចោល នៅតែជាកូនស្របច្បាប់របស់ឪពុក ដែលដូចជាកើតនៅក្នុងពេលអាពាហ៍ពិពាហ៍ផងដែរ។*

# ការលែងលះគ្នា

នៅក្នុងដំណើរការនីតិវិធីលែងលះគ្នា ច្បាប់មិនតម្រូវឱ្យមានមេធាវីនោះទេ ប៉ុន្តែ គេផ្តល់យោបល់ថា គួរមានមេធាវីម្នាក់ជាការប្រសើរ ពីព្រោះដំណើរការនីតិវិធីនេះ អាចមានភាពស្មុគស្មាញ។

ភាគី ដែលបានរៀបអាពាហ៍ពិពាហ៍ អាចជ្រើសរើសនីតិវិធី សម្រាប់ការលែងលះគ្នាដូចខាងក្រោមនេះ៖

### ១. ការដាក់ពាក្យស្នើសុំលែងលះគ្នាទៅក្រុមប្រឹក្សាឃុំ-សង្កាត់

ប្តី ឬប្រពន្ធអាចដាក់ពាក្យស្នើសុំលែងលះគ្នាទៅក្រុមប្រឹក្សាឃុំ-សង្កាត់ នៅខាងលំនៅឋាន ឬទីសំណាក់របស់ខ្លួនបាន។ ក្រោយពេលទទួលបានពាក្យស្នើសុំលែងលះគ្នាហើយ ក្រុមប្រឹក្សាឃុំ-សង្កាត់មានកាតព្វកិច្ចធ្វើការផ្សះផ្សាគូភាគីឱ្យសះជាគ្នាវិញបាន ក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំនេះ។ ប្រសិនបើក្នុងរយៈពេល ១៥ ថ្ងៃនេះ គូភាគីមិនអាចសះជានឹងគ្នាវិញបានទេ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបញ្ជូនពាក្យបណ្តឹងលែងលះគ្នានេះទៅតុលាការជាបន្ទាន់។

### ២. ការដាក់ពាក្យបណ្តឹងលែងលះគ្នាទៅតុលាការ

ប្តី និង/ឬប្រពន្ធអាចដាក់ពាក្យបណ្តឹងលែងលះគ្នា ទៅសាលាដំបូងរាជធានី-ខេត្ត ដោយផ្ទាល់តែម្តង ដែលមានសមត្ថកិច្ចនៅខាងលំនៅឋាន ឬទីសំណាក់របស់គូភាគី ស្របតាមមាត្រា ១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៧ និងមាត្រា ៩៨២ នៃក្រមរដ្ឋប្បវេណី។

ចំពោះករណីលែងលះគ្នា ប្រាក់ប្រដាប់ក្តីមានចំនួន ៥៥.០០០ រៀល (*យោងតាមមាត្រា ៦០ ចំណុចទី ៣ និងមាត្រា ៦១ ចំណុចទី ១ ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៧*)។

## ការលែងលះគ្នាដោយការព្រមព្រៀង

ភាគី ដែលបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ អាចដាក់ពាក្យបណ្តឹងលែងលះគ្នាទៅតុលាការ ប្រសិនបើភាគីនៃការលែងលះគ្នានោះបានព្រមព្រៀងលែងលះគ្នាដោយស្ម័គ្រចិត្ត។ តុលាការអាចសម្រេចឱ្យភាគីនោះ លែងលះគ្នាបាន ប្រសិនបើតុលាការរកឃើញថា ភាគីនោះមានបំណងពិតប្រាកដ ដើម្បីរំលាយចំណងអាពាហ៍ពិពាហ៍របស់ខ្លួនមែន (*មាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី*)។

សូមកត់សម្គាល់ថា គេមិនអាចរំលាយចំណងអាពាហ៍ពិពាហ៍ តាមការព្រមព្រៀងគ្នាដោយគ្មានសាលក្រមពីតុលាការបានឡើយ។ មានតែសេចក្ដីសម្រេចពីតុលាការតែប៉ុណ្ណោះ ដែលអាចរំលាយចំណងអាពាហ៍ពិពាហ៍ ដែលបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់បាន។

ឧទាហរណ៍៖ *លោក តុលា បានរៀបការជាមួយនាង នារី ហើយពួកគេបានរស់នៅជាមួយគ្នាអស់រយៈពេល ១ ឆ្នាំ។ ជាអកុសល ពួកគេរស់នៅមិនចុះសម្រុងនឹងគ្នា ហើយពួកគេបានព្រមព្រៀងគ្នាដើម្បីលែងលះ។ បន្ទាប់ពីបានពិនិត្យសំណុំរឿងលែងលះគ្នានេះ ហើយបានរកឃើញថា គូភាគីមានបំណងពិតប្រាកដដើម្បីលែងលះគ្នា តុលាការសម្រេចចេញដីកាអនុញ្ញាតឱ្យពួកគេលែងលះគ្នា។*

## ការដាក់ពាក្យបណ្ដឹងលែងលះគ្នា ដោយសហព័ទ្ធតែម្ខាង

ប្រសិនបើសហព័ទ្ធតែម្ខាងដាក់ពាក្យបណ្ដឹងលែងលះគ្នា តុលាការអាចអនុញ្ញាតឱ្យលែងលះគ្នាបាន លុះត្រាតែពាក្យបណ្ដឹងលែងលះគ្នានោះ មានមូលហេតុមួយនៅក្នុងចំណោមមូលហេតុទាំងឡាយ ដូចខាងក្រោមនេះ៖

- ប្រសិនបើសហព័ទ្ធម្ខាងទៀត ប្រព្រឹត្តអំពើផិត។

  ឧទាហរណ៍: *ប្ដីបានលួចមានប្រពន្ធទីពីរ ឬទៅរកនារីរកស៊ីផ្លូវភេទ។*

- ប្រសិនបើបានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ។

  ឧទាហរណ៍: *បន្ទាប់ពីរយៈពេល ១ ឆ្នាំនៃចំណងអាពាហ៍ពិពាហ៍ ប្ដីបានបោះបង់ប្រពន្ធចោល ដោយគ្មានផ្ដល់មូលហេតុ។*

- ប្រសិនបើមិនដឹងច្បាស់ថា សហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាង ១ ឆ្នាំ។

  ឧទាហរណ៍: *នាវាដែលប្ដីបានធ្វើការ ត្រូវបានលិច។ សាកសពរបស់គាត់មិនត្រូវបានគេរកឃើញអស់រយៈពេល ១ ឆ្នាំ បន្ទាប់ពីនាវានោះ បានលិច។*

- ប្រសិនបើសហព័ទ្ធម្ខាងទៀត បានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍។

ឧទាហរណ៍៖ *បន្ទាប់ពីរយៈពេល ៣ ខែនៃចំណងអាពាហ៍ពិពាហ៍ ប្ដីបានបដិសេធត្រឡប់មកផ្ទះវិញ អស់រយៈពេលជាង ១ ឆ្នាំ ។*

- ករណីផ្សេងៗទៀត ដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទាន/ផ្សះផ្សាគ្នាឡើងវិញបាន។

ឧទាហរណ៍៖ *ប្រពន្ធបានវិលត្រឡប់ទៅរស់នៅជាមួយម្ដាយរបស់នាងវិញ ដោយយកកូនទៅជាមួយផង ។ នាងបដិសេធត្រឡប់មកផ្ទះវិញ ដោយសារតែប្ដីវាយដំនាង ។*

## មូលហេតុនៃការបដិសេធការលែងលះគ្នា

បើទោះបីជាក្នុងករណី ដែលបានកំណត់ខាងលើនេះក៏ដោយ ប្រសិនបើតុលាការយល់ឃើញថា ការលែងលះគ្នានោះនឹងបណ្ដាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ន្ធ ឬកូនក្រលំបាកយ៉ាងខ្លាំង ឬមានការឈឺចាប់ ដែលពុំអាចទ្រាំទ្របាន តុលាការអាចច្រានចោលការទាមទារលែងលះគ្នា ( *មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី*) ។

តុលាការ ក៏អាចច្រានចោលការទាមទារលែងលះគ្នាផងដែរ ប្រសិនបើគូភាគី ដែលទាមទារការលែងលះគ្នានោះ បានធ្វេសប្រហែសយ៉ាងខ្លាំង នៅក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នា និងការជួយសង្គ្រោះសហព័ទ្ធម្ខាងទៀត *(មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី)*។

## ការចាត់ចែងរក្សាការពារ

តុលាការ អាចចេញដីកាសម្រេចបង្គាប់ឱ្យធ្វើការចាត់ចែងរក្សាការពារ (អធិបញ្ញាជាបណ្ដោះអាសន្ន) ចំពោះការបំបែកលំនៅ ( *តើនរណាព្រមទាំងកូនផងដែរនឹងត្រូវរស់នៅទីកន្លែងណា*) ការគ្រប់គ្រងថែរក្សាកូន និងសិទ្ធិទៅសួរសុខទុក្ខកូន ការគ្រប់គ្រងរក្សាទ្រព្យសម្បត្តិ ការជួយគាំទ្រផ្នែកហិរញ្ញវត្ថុ ចំពោះសហព័ទ្ធ ( *អាហារកាតព្វកិច្ច*) បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ ( *ការចែករំលែកការចំណាយនៅក្នុងគ្រួសារ*) និងសោហ៊ុយចិញ្ចឹមបីបាច់កូន តាមការដាក់ពាក្យស្នើសុំរបស់ភាគី ឬដោយឆន្ទានុសិទ្ធិបាន ( *មាត្រា ៩៨៣ នៃក្រមរដ្ឋប្បវេណី*) ។

## ដីកាសម្រេចលែងលះគ្នាជាស្ថាពរ

គូភាគីមិនគួរដាក់តែពាក្យបណ្ដឹងលែងលះគ្នានោះទេ ពួកគេគួរតែដាក់ពាក្យបណ្ដឹងទាមទារសេចក្ដីសម្រេចពីតុលាការ ទៅលើបញ្ហាទាំងឡាយ ដូចខាងក្រោមនេះផងដែរ៖

ក). ការបែងចែកទ្រព្យសម្បត្តិ *(មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី)*

ទ្រព្យសម្បត្តិរួមក្នុងចំណងអាពាហ៍ពិពាហ៍ នឹងត្រូវបែងចែក។ ប្រសិនបើគូភាគីពុំអាចព្រមព្រៀងគ្នាទៅលើការបែងចែកទ្រព្យសម្បត្តិទេ តុលាការនឹងបែងចែក តាមវិធីដូចខាងក្រោមនេះ (*មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី*) គូភាគីនីមួយៗ ត្រូវទទួលបានទ្រព្យសម្បត្តិដោយឡែក ដែលមិនមែនជាទ្រព្យសម្បត្តិរួម (*មាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណី*) គូភាគីនីមួយៗត្រូវទទួលបានទ្រព្យសម្បត្តិរួមចំនួនពាក់កណ្ដាល (*១ ភាគ ២*) លុះត្រាតែតុលាការ តាមការដាក់ពាក្យស្នើសុំ សម្រេចដោយផ្អែកទៅលើស្ថានភាពពិសេសនានា។

ឧទាហរណ៍: *ប្រសិនបើប្ដីមិនអាចចេញអាហារកាតព្វកិច្ចបានទេនោះ ប្រពន្ធអាចស្នើសុំការគ្រប់គ្រងផ្ទះទាំងមូល (មិនមែនតែពាក់កណ្ដាលនោះទេ)។ តុលាការអាចពិចារណា អំពីការពិត ដែលថាប្ដីពុំអាចចេញអាហារកាតព្វកិច្ចបាននេះ គឺជាស្ថានភាពពិសេសមួយ។*

ខ). សេចក្ដីសម្រេចអំពីអាហារកាតព្វកិច្ចចំពោះសហព័ទ្ធ *(មាត្រា ៩៨៣ នៃក្រមរដ្ឋប្បវេណី)*

គ). សេចក្ដីសម្រេចអំពីសោហ៊ុយចិញ្ចឹមកូន *(មាត្រា ៩៨៣ និងមាត្រា ១០៤០ ចំណុចទី ២ និងចំណុចទី ៦ នៃក្រមរដ្ឋប្បវេណី)*

ឃ). សេចក្ដីសម្រេចអំពីការគ្រប់គ្រងថែរក្សាកូន *(មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី)*

ឪពុកម្ដាយ ដែលគ្រប់គ្រងថែរក្សាកូន (*ដែលមានអំណាចមេបា*) ត្រូវមានកាតព្វកិច្ចដើម្បីពិគ្រោះយោបល់ជាមួយនឹងឪពុកម្ដាយម្ខាងទៀត (*ដែលគ្មានអំណាចមេបា*) ក្នុងករណីនៃការសម្រេច ដែលទាក់ទងនឹងការសិក្សាអប់រំរបស់កូន ការផ្លាស់ប្ដូរទីសំណាក់របស់កូនទៅខេត្តមួយផ្សេងទៀត មុខរបរ/វិជ្ជាជីវៈរបស់កូន ការព្យាបាលជំងឺរបស់កូន ការចាត់ចែងទ្រព្យសម្បត្តិរបស់កូន និងបញ្ហាសំខាន់ៗផ្សេងៗទៀត (*មាត្រា ១០៤២ នៃក្រមរដ្ឋប្បវេណី*)។

ង). សិទ្ធិរបស់ឪពុកម្ដាយ ដែលមិនរស់នៅជាមួយកូន
*(មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី)*

ប្រសិនបើការដាក់ពាក្យបណ្ដឹងលែងលះគ្នា មិនបានភ្ជាប់មកជាមួយនូវបណ្ដឹងសុំនូវការបង្គាប់ទាំងនេះទេនោះ តុលាការមិនអាចចាត់ចែងឱ្យគូភាគីបានឡើយ។

## មត៌ក[10]

ស្ត្រី និងបុរសមានសិទ្ធិស្មើគ្នា នៅក្នុងការទទួលបានមត៌ក។

### ការបែងចែងមត៌កតាមច្បាប់

ប្រសិនបើគ្មានបណ្តាំ ដែលមានសុពលភាពទេនោះ មត៌កត្រូវតែបែងចែក ស្របតាមច្បាប់ (*ការបែងចែកមត៌កតាមច្បាប់ យោងតាមមាត្រា ១១៥៦-១១៦៧ នៃក្រមរដ្ឋប្បវេណី*)។ បើយោងតាមមាត្រា ៩៧៣ ទ្រព្យសម្បត្តិ ដែលប្តីប្រពន្ធទាំងសងខាង ឬម្ខាងបានធ្វើលទ្ធកម្ម ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ជាគោលការណ៍ គឺជាទ្រព្យសម្បត្តិរួម។ ដូច្នេះ ប្រសិនបើ ប្តី ឬប្រពន្ធណាម្នាក់ទទួលមរណៈភាព ពាក់កណ្តាលនៃទ្រព្យសម្បត្តិនោះ គឺជារបស់សហព័ទ្ធ ដែលនៅរស់ ហើយពាក់កណ្តាលទៀត គឺជាមត៌ក។

ប្តីម្នាក់បានស្លាប់ ដោយមានប្រពន្ធ ដែលបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ និងកូនចំនួនពីរនាក់។ នៅពេលស្លាប់ ប្តីនោះមានដីមួយឡូ គោ ៣ ក្បាល និងលុយចំនួន ៣,០០០ ដុល្លារ។ ទ្រព្យសម្បត្តិរបស់គាត់ទាំងអស់នេះ ត្រូវស្ថិតនៅក្រោមទ្រព្យរួម។ ហេតុដូច្នេះហើយប្រពន្ធ គឺជាម្ចាស់កម្មសិទ្ធិទៅលើទ្រព្យសម្បត្តិទាំងអស់នេះ ក្នុងចំនួនពាក់កណ្តាល។រីឯទ្រព្យសម្បត្តិចំនួនពាក់កណ្តាលផ្សេងទៀត ត្រូវធ្វើការបែងចែកជាចំណែកមត៌កស្មើគ្នារវាងកូន និងប្រពន្ធនោះ។ ការបែងចែកចំណែកមត៌កនេះ មានដូចខាងក្រោមនេះ៖

ប្រពន្ធ:

- ចំនួន ២ ភាគ ៣ នៃដី មានន័យថា
  (*ទ្រព្យសម្បត្តិរួមចំនួនពាក់កណ្តាល និងចំណែកមត៌កចំនួន ១ ភាគ ៦*)
- គោចំនួន ២ ក្បាល មានន័យថា
  (*ទ្រព្យសម្បត្តិរួមចំនួនពាក់កណ្តាល និងចំណែកមត៌កចំនួន ១ ភាគ ៦*) និង
- ទឹកប្រាក់ចំនួន ៣,០០០ ដុល្លារ មានន័យថា
  (*ទ្រព្យសម្បត្តិរួមចំនួនពាក់កណ្តាល និងចំណែកមត៌កចំនួន ១ ភាគ ៦*)។

---

10 កំណត់សម្គាល់: ពាក្យមត៌កនេះ គឺជាពាក្យសម្រាយនៃពាក្យសន្តតិកម្ម ដែលបានប្រើប្រាស់នៅក្នុងក្រមរដ្ឋប្បវេណី ដែលត្រូវបានអនុម័តនៅថ្ងៃទី ០៥ ខែតុលា ឆ្នាំ ២០០៧ និងត្រូវបានប្រកាសឱ្យប្រើដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី នៅថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១១។

កូនៈ

- ម្នាក់ៗទទួលបានដីចំនួន ១ ភាគ ៦
- ម្នាក់ៗទទួលបានគោចំនួនពាក់កណ្ដាល មានន័យថា (គោមួយក្បាល គឺជាទ្រព្យសម្បត្តិរួម) និង
- ម្នាក់ៗទទួលបានទឹកប្រាក់ចំនួន ៥០០ ដុល្លារ។

## មត៌កមានសំបុត្របណ្ដាំ

មនុស្សមានសេរីភាព នៅក្នុងការងាកចេញពីការអនុវត្តតាមប្រព័ន្ធបែងចែកមត៌កតាមច្បាប់ តាមរយៈសំបុត្របណ្ដាំ ដែលបានរៀបរាប់ថាតើនរណាខ្លះ នឹងទទួលបានចំណែកមត៌ករបស់ខ្លួនអ្វីខ្លះ។ សំបុត្របណ្ដាំគួរតែធ្វើឡើង ដោយស្របតាមច្បាប់ ដែលតម្រូវឱ្យអនុវត្ត ដូចបានរៀបរាប់ចាប់ពីមាត្រា ១១៦៨ រហូតដល់មាត្រា ១២២៩ នៃក្រមរដ្ឋប្បវេណី។ ប៉ុន្តែ សេរីភាពនៃការបែងចែកមត៌ក តាមសំបុត្របណ្ដាំនេះ ត្រូវបានដាក់កម្រិតដោយសារតែមានភាគបម្រុង ដូចបានរៀបរាប់នៅក្នុងមាត្រា ១២៣០ នៃក្រមរដ្ឋប្បវេណី។

ប្ដីម្នាក់បានស្លាប់។ ប្ដីនោះបានបន្សល់ទុកនូវសំបុត្របណ្ដាំមួយ ដែលមានសុពលភាព ដែលក្នុងនោះ គាត់មិនបានលើកឡើងអំពីការបែងចែកមត៌ក ឱ្យកូនស្រីរបស់គាត់ឡើយ។ គាត់ចង់ឱ្យកូនប្រុស និងប្រពន្ធរបស់គាត់ទទួលបានមត៌កទាំងអស់នេះ។ បើយោងតាមមាត្រា ១២៣០ នៃក្រមរដ្ឋប្បវេណី បានឱ្យដឹងថា កូនស្រីនៅតែមានសិទ្ធិទទួលបានមត៌កចំនួន ១ ភាគ ១២ មានន័យថា (*ចំនួនពាក់កណ្ដាល តាមការបែងចែកមត៌ក តាមច្បាប់*)។

# ឧបសម្ព័ន្ធទី ១ - ឯកសារយោង


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ឆ្នាំ ២០១៣)។ *នីតិវិធីមុនពេលជំនុំជម្រះ និងពេលជំនុំជម្រះ, សៀវភៅក្បួន សម្រាប់នីតិវិធីព្រហ្មទណ្ឌនៅក្នុងតុលាការកម្ពុជា។*

គណៈកម្មាធិការស្ត្រីកម្ពុជា, CAMBOW (ឆ្នាំ ២០០៧)។ *អំពើហិង្សាលើស្ត្រីៈ តើច្បាប់កម្ពុជារើសអើងលើស្ត្រីយ៉ាងដូចម្តេច។*

មជ្ឈមណ្ឌលអភិវឌ្ឍសង្គម (CSD) (ឆ្នាំ ២០០៨)។ *សៀវភៅក្បួនអំពីការជំនុំជម្រះត្រឹមត្រូវ។*

ក្រុមប្រឹក្សាដើម្បីកំណែទម្រង់ច្បាប់ និងតុលាការ (ឆ្នាំ ២០១១), *សៀវភៅព័ត៌មានអំពីសេវាសាធារណៈ, សេវាទាក់ទងនឹងវិស័យយុត្តិធម៌ និងមជ្ឈត្តកម្ម (ភាគទី ១)។*

Fulu, E., Warner, X., Miedema, S., Jewkes, R., Roselli, T. and Lang, J. (ឆ្នាំ ២០១៣)។ *តើហេតុអ្វីបានជាបុរសមួយចំនួន ប្រព្រឹត្តអំពើហិង្សាលើស្ត្រី ហើយតើយើងអាចទប់ស្កាត់វា ដោយរបៀបណា? ការរកឃើញបែបគុណភាព ចេញពីការសិក្សាពហុប្រទេសរបស់អង្គការសហប្រជាជាតិស្តីពីបុរស និងអំពើហិង្សានៅទ្វីបអាស៊ី និងតំបន់ប៉ាស៊ីហ្វិក។ ទីក្រុងបាងកកៈ អង្គការ* UNDP, UNFPA, UN Women *និងអង្គការ* UNV *។*

កិច្ចសហប្រត្តិការអភិវឌ្ឍអាល្លឺម៉ង់ជីអាយហ្សិត GIZ (អតីតជីធីហ្សិត GTZ) ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួងកិច្ចការនារី (ឆ្នាំ ២០០៥)។ *អំពើហិង្សាក្នុងគ្រួសារៈ សៀវភៅបណ្តុះបណ្តាល ដើម្បីលើកកម្ពស់ការយល់ដឹង។*

អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (ឆ្នាំ ២០១៣)។ *ការធ្វើអាជីវកម្មផ្លូវភេទបែបពាណិជ្ជកម្មលើកុមារនៅកម្ពុជា និងការឆ្លើយតបរបស់ប្រព័ន្ធយុត្តិធម៌សាធារណៈ។ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ។*

អង្គការលីកាដូ, សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (ឆ្នាំ ២០០៦)។ *អំពើហិង្សាលើស្ត្រី*។

ក្រសួងកិច្ចការនារី (ឆ្នាំ ២០០៧)។ *កំណត់ពន្យល់អំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, ប្រវត្តិ, ទស្សនទាន និងសេចក្តីពន្យល់ សម្រាប់ការបកស្រាយ, រាជរដ្ឋាភិបាលកម្ពុជា*។

អង្គការសន្តិភាព និងអភិវឌ្ឍ និងវិទ្យាស្ថានបើកទូលាយ (ឆ្នាំ ២០១០)។ *សៀវភៅណែនាំសម្រាប់ស្ត្រី*។

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួងកិច្ចការនារីនៃរាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ ២០០៩)។ *អំពើហិង្សាក្នុងគ្រួសារ, សៀវភៅបណ្តុះបណ្តាល សម្រាប់មន្ត្រីវិជ្ជាជីវៈតុលាការ*។

*ច្បាប់រដ្ឋបាលទូទៅ ឆ្នាំ ២០០១ ។*

ការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្ម UNODC (ឆ្នាំ ២០១០), សៀវភៅក្បួនអំពីការឆ្លើយតបប្រកបដោយប្រសិទ្ធភាពរបស់នគរបាល ចំពោះអំពើហិង្សាលើស្ត្រី, អង្គការសហប្រជាជាតិ, ទីក្រុងញ៉ូយ៉ក ។

# ឧបសម្ព័ន្ធទី ២ - រចនាសម្ព័ន្ធរបស់តុលាការ



# ឧបសម្ព័ន្ធទី ៣ - ឋានានុក្រមច្បាប់



# ឧបសម្ព័ន្ធទី ៤ - តារាងលំហូរនៃនីតិវិធីព្រហ្មទណ្ឌ (ករណីមិនជាក់ស្តែង)

ដើមបណ្តឹង = ជនរងគ្រោះ ឬមន្ត្រីរដ្ឋាភិបាល ដែលទទួលបានការអនុញ្ញាត

ប្តឹងមន្ត្រីនគរបាលយុត្តិធម៌
(មាត្រា ៧២-៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ជូនដំណឹងដល់ជនរងគ្រោះ

ការស៊ើបអង្កេតរបស់នគរបាល
(មាត្រា ៧៤ នៃក្រមព្រហ្មទណ្ឌ)

ការស៊ើបអង្កេតបឋមដោយព្រះរាជអាជ្ញា
បើយល់ឃើញថា ជាការចាំបាច់ (មាត្រា ៤០ និង
មាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ចោទប្រកាន់ដោយព្រះរាជអាជ្ញា
(មាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ច្រានចោលដោយព្រះរាជអាជ្ញា
(មាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

បទឧក្រិដ្ឋ ឬបទមជ្ឈិម

បទមជ្ឈិម

បទលហុ ឬបទមជ្ឈិម

ការបើកការស៊ើបសួរ
ដោយចៅក្រមស៊ើបសួរ
(មាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ការបង្ហាញខ្លួនភ្លាម
(មាត្រា ៤៧ នៃក្រម
នីតិវិធីព្រហ្មទណ្ឌ)

ដីកាកោះហៅបញ្ជូនទៅ
ជំនុំជម្រះផ្ទាល់ (មាត្រា ៤៦
នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ការលើកលែងការចោទប្រកាន់
ដោយចៅក្រមស៊ើបសួរ (មាត្រា ២៤៦
នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ការជំនុំជម្រះ

# ឧបសម្ព័ន្ធទី ៥ - តារាងលំហូរនៃនីតិវិធីព្រហ្មទណ្ឌ (ករណីជាក់ស្តែង)



ព្រះរាជាណាចក្រកម្ពុជា

ជាតិ - សាសនា - ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

អង្គភាព:..................

លេខ:..................................

លាក់ការណ៍សំងាត់

## ឯកសារពិនិត្យការរំលោភផ្លូវភេទ

(ស្ត្រីរងគ្រោះ: ពិនិត្យដោយគ្រូពេទ្យផ្នែកសម្ភព និង រោគស្ត្រី, បុរស: ពិនិត្យដោយគ្រូពេទ្យទូទៅបាន)

-ឯកសារពិនិត្យការរំលោភផ្លូវភេទ ត្រូវរក្សាទុកជាសំណៅដើមនៅក្នុងអង្គភាពដើម រឺ គណៈកម្មការ កោសល្យវិច័យខេត្ត-ក្រុង ។ ឯកសារនេះ មានចំនួន ៧ ទំព័រ គឺ ពី ទំព័រទី ១ ដល់ ទី ៧ ។

-គណៈកម្មការកោសល្យវិច័យខេត្ត-ក្រុង អាចប្រគល់លិខិតចំលងចំនួនមួយច្បាប់បាន លុះត្រាតែមានលិខិតស្នើសុំជាលាយល័ក្ខអក្សរពី: នគរបាលយុត្តិធម៌ដែលមានតួនាទីស៊ើបអង្កេតរឿងក្តី, ចៅក្រម, ព្រះរាជអាជ្ញា និង មេធាវីជនរងគ្រោះ ។ ឯកសារថតចំលងជូននេះត្រូវរក្សាទុកក្នុងស្រោមសំបុត្របិទជិត និង បោះត្រាពីលើមាត់ស្រោមបិទស្រោមសំបុត្រ ដើម្បីធានារក្សាការសំងាត់ ។

-អង្គភាពប្រតិបត្តិ:.................................................. ទូរស័ព្ទ..........................................

-គណៈកម្មការកោសល្យវិច័យខេត្ត-ក្រុង:.................................. ទូរស័ព្ទ..........................................

ទូរសារ.................................. អ៊ីមែល..........................................

-គណៈកម្មការកោសល្យវិច័យ ក្រសួងសុខាភិបាល: ទូរស័ព្ទ..........................................

ទូរសារ.................................. អ៊ីមែល..........................................

ទីស្តីការក្រសួងសុខាភិបាល លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ... ទូរស័ព្ទ-ទូរសារ: [illegible]

# ឯកសារពិនិត្យការរំលោភផ្លូវភេទ

នាម និង គោត្តនាមជនរងគ្រោះ:..............................ឈ្មោះហៅក្រៅ....................ភេទ: ប្រុស ☐ ស្រី ☐

ថ្ងៃ.ខែ.ឆ្នាំកំណើត: ......./......./......... អាស័យដ្ឋានបច្ចុប្បន្ន:..............................

..............................លេខកូដ.................... ទូរស័ព្ទលេខ..............................

ថ្ងៃ.ខែឆ្នាំ.ចូលមកពិនិត្យ:....../....../.......... ពេលម៉ោង:.................... ទីកន្លែងពិនិត្យ:..............................

**ករណីសង្ស័យរំលោភផ្លូវភេទ:** (ផ្តល់ដោយជនរងគ្រោះ)

- ☐ ការរំលោភសេពសន្ថវៈ (Rape)
- ☐ ការរំលោភសេពសន្ថវៈដោយសមាជិកក្នុងក្រុមគ្រួសារ (Incest)
- ☐ ការបៀតបៀនកេរ្តិ៍ខ្មាស (Indecent Assault)
- ☐ ការរំលោភផ្លូវភេទផ្សេងទៀត:..............................

ថ្ងៃ.ខែ.ឆ្នាំ. នៃការរំលោភ:....../....../.......... ម៉ោង:..............

**អ្នកបញ្ជូនជនរងគ្រោះមកជាមួយជនរងគ្រោះ**

- ☐ ខ្លួនឯង (Self) ☐ ប៉ូលិស (Police)
- ☐ មិត្តភក្ត្រ (Friend) ☐ ញាតិ (ជាអ្វី)..............................
- ☐ ផ្សេងទៀតបញ្ជាក់:..............................

ឈ្មោះ ..............................

ទូរស័ព្ទ:..............................

## ការយល់ព្រមចំពោះការពិនិត្យវេជ្ជសាស្ត្រ

(អានជូនអ្នកជំងឺស្តាប់ដោយសាក្សី)

ខ្ញុំបាទ.នាងខ្ញុំ យល់ព្រមទាំងស្រុងលើការពិនិត្យផ្នែកវេជ្ជសាស្ត្រនេះ រួមទាំងការពិនិត្យប្រដាប់បន្តពូជ និង កត់ត្រាទុកជាឯកសារអំពីលទ្ធផលនៃការពិនិត្យនេះ ។ ខ្ញុំបាទ.នាងខ្ញុំអនុញ្ញាតឱ្យៈ ប្រមូលយកវត្ថុសំណាក-វត្ថុវិភាគចាំបាច់ទាំងអស់ សំរាប់យកទៅធ្វើតេស្ត នៅក្នុង មន្ទីរពិសោធន៍ និង ការថតយករូបភាពជាចាំបាច់ ដើម្បីបង្ហាញស្នាមដែលពាក់ព័ន្ធនឹងហេតុផលនៃការពិនិត្យវេជ្ជសាស្ត្រនេះផងដែរ ។

ថ្ងៃទី......ខែ..........ឆ្នាំ..............

ហត្ថលេខា ឬស្នាមមេដៃស្តាំជនរងគ្រោះ

ជនរងគ្រោះឈ្មោះ ..............................

**អ្នកអមដំណើរជាមួយអ្នកជំងឺ**

- ☐ ខ្លួនឯង ☐ ប៉ូលិស ☐ មិត្តភក្ត្រ
- ☐ ញាតិ (ត្រូវជាអ្វី)..............................
- ☐ ផ្សេងទៀតបញ្ជាក់:..............................

..............................

ថ្ងៃទី......ខែ..........ឆ្នាំ..............

ហត្ថលេខា ឬ ស្នាមមេដៃស្តាំសាក្សី

សាក្សីជនរងគ្រោះឈ្មោះ ..............................

ថ្ងៃទី......ខែ..........ឆ្នាំ..............

ហត្ថលេខារបស់គ្រូពេទ្យ-ពិនិត្យគ្លីនិក

គ្រូពេទ្យឈ្មោះ ..............................

ថ្ងៃ-ខែ-ឆ្នាំ ពិនិត្យគ្លីនិក

......./........../..........

ពេលវេលានៃការចាប់ផ្តើមពិនិត្យ

ម៉ោង:..............................

ពេលវេលានៃការបញ្ចប់ពិនិត្យគ្លីនិក

ម៉ោង:..............................

ថ្ងៃទី......ខែ..........ឆ្នាំ..............

ហត្ថលេខា ឬ ស្នាមមេដៃស្តាំសាក្សីគ្រូពេទ្យ

សាក្សីគ្រូពេទ្យឈ្មោះ ..............................

មុខងារ :..............................

# ការពិនិត្យជនរងគ្រោះ

ឈ្មោះ:............................................................ ទីកន្លែងពិនិត្យ :..................................................

ឈ្មោះគ្រូពេទ្យ :.................................................. ម៉ោងពិនិត្យ :.........................................................

អាស័យដ្ឋានអង្គភាព :.......................................................................................................................

## ១. ការសាកសួរ និង ប្រវត្តិជំងឺ :

១.១-ប្រវត្តិជំងឺពីមុនមក :

ក-បេះដូង : មាន ❑ គ្មាន ❑ ខ-ថ្លើម : មាន ❑ គ្មាន ❑

គ-លើសឈាម : មាន ❑ គ្មាន ❑ ឃ-កាមរោគ : មាន ❑ គ្មាន ❑

ង-វះកាត់ : មាន ❑ គ្មាន ❑ ឃ-ជំងឺផ្លូវចិត្ត : មាន ❑ គ្មាន ❑

ច-ផ្សេងៗ សូមបញ្ជាក់:.......................................................................................................

១.២-ប្រវត្តិរដូវ : មិនទាន់គ្រប់ការ:........... ថ្ងៃខែឆ្នាំមករដូវដំបូង:...................... ថ្ងៃខែមករដូវចុងក្រោយ...................

១.៣-ប្រវត្តិរួមរ័ក្ស : លើកដំបូងថ្ងៃទី......ខែ...........ឆ្នាំ............. លើកចុងក្រោយថ្ងៃទី.......ខែ............ឆ្នាំ.............

១.៤-ប្រវត្តិប្រើមធ្យោបាយពន្យារកំណើត : មធ្យោបាយ ........................ ចំនួន:................ នៅពេលណា.........................

១.៥-ប្រវត្តិផ្ទៃពោះ :

ក-មិនដែលមានផ្ទៃពោះ: មាន ❑ គ្មាន ❑ ខ-ធ្លាប់មានផ្ទៃពោះ : ចំនួន ☐ ដង

គ-ធ្លាប់កើតកូន: ចំនួន ☐ នាក់ ឃ-ធ្លាប់រលូតកូន: ចំនួន ☐ នាក់

១.៦-តើវិធីនៃការរួមរ័ក្សដោយរបៀបណា :

ក-បញ្ចូលលិង្គក្នុងទ្វារមាស មាន ❑ គ្មាន ❑ ខ-បញ្ចូលដៃក្នុងទ្វារមាស មាន ❑ គ្មាន ❑

គ-បញ្ចូលលិង្គក្នុងមាត់ មាន ❑ គ្មាន ❑ ឃ-បញ្ចូលលិង្គក្នុងរន្ធគូថ មាន ❑ គ្មាន ❑

ង-ផ្សេងៗ:.......................................................................................................................

១.៧-អាកប្បកិរិយាក្រោយពេលរំលោភ :

ក-លុកលាងទ្វារមាស មាន ❑ គ្មាន ❑ ខ-បត់ជើងតូច មាន ❑ គ្មាន ❑

គ-បត់ជើងធំ មាន ❑ គ្មាន ❑ ឃ-ងូតទឹក មាន ❑ គ្មាន ❑

ង-ខ្ពុរមាត់ មាន ❑ គ្មាន ❑ ច-ដុសធ្មេញ មាន ❑ គ្មាន ❑

ឆ-ប្តូរសំលៀកបំពាក់ មាន ❑ គ្មាន ❑ ជ-ផ្សេងៗ:..................................................

## ២. ការពិនិត្យគ្លីនិក:

២.១-ការពិនិត្យជាទូទៅ: ប្រើគំនូសតាងតំរូវការសំគាល់ពិតលើរាល់ ស្នាមជាំ, ហើម, ស្នាមរលាត់, ស្នាមដាច់

| | ធម្មតា | មិនធម្មតា (ចូរសរសេរបញ្ជាក់ពីទំហំស្លាកស្នាមនៃរបួស) |
|---|---|---|
| ១- | ☐ ក្បាល | ☐ : ................................ |
| ២- | ☐ មុខ | ☐ : ................................ |
| ៣- | ☐ មាត់ | ☐ : ................................ |
| ៤- | ☐ បំពង់ក | ☐ : ................................ |
| ៥- | ☐ ទ្រូង-ផ្នែកមុខ | ☐ : ................................ |
| ៦- | ☐ ពោះ-ផ្នែកមុខ | ☐ : ................................ |
| ៧- | ☐ ដៃ | ☐ : ................................ |
| ៨- | ☐ ប្រអប់ដៃ | ☐ : ................................ |
| ៩- | ☐ គល់ភ្លៅក្នុង | ☐ : ................................ |
| ១០- | ☐ ជើង | ☐ : ................................ |
| ១១- | ☐ ប្រអប់ជើង | ☐ : ................................ |
| ១២- | ☐ ទ្រូងផ្នែកក្រោយ | ☐ : ................................ |
| ១៣- | ☐ ពោះផ្នែកក្រោយ | ☐ : ................................ |
| ១៤- | ☐ គូថ | ☐ : ................................ |
| ១៥- | ☐ ផ្សេងៗ | ☐ : ................................ |

ចូរគូសគំនូសបង្ហាញពីទីកន្លែង, ទំហំ ជាសង់ទីម៉ែត្រ នៃ ស្លាកស្នាមរបួស



.២-ការពិនិត្យប្រដាប់ភេទផ្នែកខាងក្រៅ :

-ទ្វារមាស (Vulva):

☐ វត្ថុរំអិល Lubrication ☐ ទឹកកាម Semen ☐ ឈាម Blood

☐ ទឹករំអិលភេទ Mucus ☐ ខ្ទុះ Pus ☐ ផ្សេងៗ Others ......................................

-ប្រដាប់ភេទខាងក្រៅ (External genital):

☐ ពេញវ័យ Mature ☐ គ្រប់ការ Pubertal ☐ មិនទាន់គ្រប់ការ Pre-pubertal

-ការពិនិត្យ កត់ត្រារាល់ការឈឺចាប់ និង ហើមពក (Examination record any pain or tenderness)

| | **ធម្មតា** | **មិនធម្មតា** (សូមសរសេរបញ្ជាក់ពីចំណុចស្លាកស្នាម) |
|---|---|---|
| ១- | ☐ ភ្នំសក់ក្រោម Mons | ☐ : ........................................ |
| ២- | ☐ បបូរធំ Labia majora | ☐ : ........................................ |
| ៣- | ☐ បបូរតូច Labia minora | ☐ : ........................................ |
| ៤- | ☐ រន្ធព្រហ្មចារី Introitus | ☐ : ........................................ |
| ៥- | ☐ សន្ទះព្រហ្មចារី Hymen | ☐ : ........................................ |
| ៦- | ☐ ស្នាមតភ្ជាប់ក្រោយ | ☐ : ........................................ |
| ៧- | ☐ សិរ Clitoris | ☐ : ........................................ |
| ៨- | ☐ រន្ធនោម Urethra | ☐ : ........................................ |
| ៩- | ☐ គល់ភ្លៅក្នុង Inner thighs | ☐ : ........................................ |
| ១០- | ☐ ពេរីណេ Perineum | ☐ : ........................................ |
| ១១- | ☐ រន្ធគូថ Anus | ☐ : ........................................ |
| ១២- | ☐ ស្បែកជុំវិញរន្ធគូថ Perianal skin | ☐ : ........................................ |

ចូរគូសសញ្ញាសម្គាល់បញ្ជាក់ពីទីកន្លែង, ទំហំ ជាសង់ទីម៉ែត្រ នៃ ស្លាកស្នាមរបួស




-ការយកសំណាកវត្ថុវិភាគដើម្បីស្រាវជ្រាវរកវត្ថុធាតុនៃ មេរោគកាមរោគ ឬ ទឹកកាម

-នីតិវិធីមុនពេលចាប់ផ្តើមការពិនិត្យផ្នែកខាងក្នុងរោម ត្រូវយកសំណាកការពារ [illegible] និង [illegible] ជាចំណែកបន្ថែមសម្រាប់ការពិនិត្យវិទ្យាសាស្ត្រ និង តុលាការ ។

២.៣-ការពិនិត្យប្រដាប់ភេទផ្នែកខាងក្នុង:

ក-ការពិនិត្យប្រដាប់ភេទដោយចំពុះទា :

| ធម្មតា | មិនធម្មតា (ចូរសរសេរបញ្ជាក់អំពីស្លាកស្នាម) |
|---|---|
| ១- ☐ តុលប៊ីណាក់ | ☐ : ........................................ |
| ២- ☐ មាត់ស្បូន | ☐ : ........................................ |
| ៣- ☐ ភ្នាសទ្វារមាសផ្នែកលើ | ☐ : ........................................ |
| ៤- ☐ ភ្នាសទ្វារមាសផ្នែកក្រោម | ☐ : ........................................ |

ខ-ការពិនិត្យភ្នាសទ្វារមាស Vaginal examination: .

..........................................................................................

..........................................................................................

គ-ការពិនិត្យរន្ធគូថ Rectal examination: .

..........................................................................................

..........................................................................................

ចូរគូសសញ្ញាសម្គាល់ពីកន្លែង ទំហំ ជាមួយនឹងទីតាំង នៃ ស្លាកស្នាមរបួស




**បញ្ជាក់:** ចំពោះជនរងគ្រោះភេទប្រុសត្រូវសរសេរបញ្ជាក់ពីរបួសស្នាមដែលមាន នៅក្នុងសេចក្តីសន្និដ្ឋានខាងក្រោមនេះ

**ការយកវត្ថុវិភាគ:**

| | | | | | |
|---|---|---|---|---|---|
| -រំអិលទ្វារមាស | ☐ | -រំអិលមាត់ស្បូន | ☐ | -ឈាម | ☐ |
| -រំអិលរន្ធគូថ | ☐ | -សក់ | ☐ | -រោម | ☐ |
| -ក្រចក | ☐ | -ផ្សេងៗ បញ្ជាក់ | ☐ : ........................................ | | |

**ការពិនិត្យដោយមន្ទីរពិសោធន៍:**

| | | | |
|---|---|---|---|
| -ពិនិត្យស្រស់ Wet Mount | ☐ | -តេស្តរកគភ៌ Pregnancy Test | ☐ |
| -ពិនិត្យដោយដាក់ពណ៌ Gram Stain | ☐ | -វិភាគទឹកនោម Urine Analysis | ☐ |
| -រកមេជីវិត Sperm Check | ☐ | -តេស្តរកវីរុសហ៊ីវ HIV Test | ☐ |
| -រកមេរោគ-ជំងឺស្វាយ RPR | ☐ | -ផ្សេងៗ Others........................................ | |

**សេចក្តីសន្និដ្ឋាន និង អនុសាសន៍ :**

........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................
........................................................................................................................

# លិខិតយល់ព្រមប្រគល់ព័ត៌មានជូន:

### នគរបាលយុត្តិធម៌ដែលមានតួនាទីស៊ើបអង្កេតរឿងក្តី. តុលាការ. ព្រះរាជអាជ្ញា. មេធាវីជនរងគ្រោះ

ខ្ញុំបាទ.នាងខ្ញុំអនុញ្ញាតឱ្យមន្ទីរពេទ្យ.................................................................................. រឺ វេជ្ជបណ្ឌិត ឈ្មោះ .............................................................. ផ្តល់ព័ត៌មានថតចំលងមួយច្បាប់អំពីឯកសារពិនិត្យការរំលោភផ្លូវភេទ និងរបាយការណ៍មន្ទីរពិសោធន៍ពាក់ព័ន្ធជូន នគរបាលយុត្តិធម៌ដែលមានតួនាទីស៊ើបអង្កេតរឿងក្តី. តុលាការ. ព្រះរាជអាជ្ញា. មេធាវីជនរងគ្រោះ ដែលបានស្នើសុំសំរាប់គោលបំណងនីតិវេជ្ជសាស្ត្រ ។ ក្នុងករណីចាំបាច់គណៈកម្មការកោសល្យវិច័យ ខេត្ត-ក្រុង អាចផ្តល់ឯកសារចំលងនេះ តាមការស្នើសុំជាលាយល័ក្ខអក្សរពី នគរបាលស៊ើបអង្កេត. ចៅក្រម. ព្រះរាជអាជ្ញា មេធាវីជនរងគ្រោះ ។

..............ថ្ងៃទី......ខែ..........ឆ្នាំ............

ហត្ថលេខាវឺ ស្នាមមេដៃស្តាំ-ជនរងគ្រោះ

ញាតិសណ្តានជនរងគ្រោះ :

- ❑ ខ្លួនឯង
- ❑ ឪពុកម្តាយ
- ❑ អាណាព្យាបាល
- ❑ អ្នកដទៃ ( សូមបញ្ជាក់ )

..........................................................

..................ថ្ងៃទី......ខែ..........ឆ្នាំ............

ហត្ថលេខាវឺ ស្នាមមេដៃស្តាំសាក្សី

ឈ្មោះ (ជនរងគ្រោះ)..........................................

ឈ្មោះ (សាក្សី)..........................................

---

បានឃើញ និង ឯកភាព

............ថ្ងៃទី ......ខែ..........ឆ្នាំ............

ហត្ថលេខា-គណៈកម្មការកោសល្យវិច័យ

ខេត្ត-ក្រុង:..........................................

ឈ្មោះប្រធាន..........................................

..................ថ្ងៃទី......ខែ..........ឆ្នាំ..................

ហត្ថលេខា និង ត្រាអង្គភាព

មន្ទីរពេទ្យ-ស្រុកប្រតិបត្តិ...............................

ឈ្មោះប្រធាន...............................................

# ឧបសម្ព័ន្ធទី ៧ - ពាក្យស្នើសុំដីកាការពារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

(ទម្រង់តាមមាត្រា៥៤១ នៃ ក.ន.រ)

**ពាក្យសុំដីកាការពារ**

**សូមគោរពជូនមក**

**លោកប្រធានសាលាដំបូង........**

*សូមជម្រាប*

**ម្ចាស់បំណុល:**

ឈ្មោះ........ ភេទ អាយុ ឆ្នាំ មានអាសយដ្ឋានភូមិ........ ឃុំ/សង្កាត់........
ក្រុង/ស្រុក/ខណ្ឌ........ រាជធានី/ខេត្ត........។

**អ្នកតំណាងដោយអាណត្តិ:**

មេធាវី ........ អត្តលេខ ........ នៃ........ ដែលមានការិយាល័យតាំងនៅផ្ទះលេខ ........
ផ្លូវលេខ........ សង្កាត់........ ខណ្ឌ........ រាជធានី ........។

**កូនបំណុល:**

ឈ្មោះ ........ ភេទ អាយុ ឆ្នាំ មានអាសយដ្ឋានភូមិ........ ឃុំ........ ស្រុក........
ខេត្ត........។

**ទី១. ខ្លឹមសារនៃដីកាសម្រេចដែលទាមទារដោយម្ចាស់បំណុល**

សុំឲ្យតុលាការចេញដីកាការពារដូចតទៅ:

១-ហាមឃាត់មិនឲ្យចុងចម្លើយឈ្មោះ ...... ធ្វើ........................................។

២-ហាមឃាត់មិនអោយចុងចម្លើយឈ្មោះ......ធ្វើ........................................។

៣..............................................................................។

៤..............................................................................។

**ទី២. ទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវការពារ**

រៀបរាប់ដំណើររឿងដែលនាំអោយមានទំនាក់ទំនងគតិយុត្ត (អង្គហេតុ)

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................។

**ទី៣: ភាពចាំបាច់នៃការរក្សាការពារ**

រៀបរាប់ពីភាពចាំបាច់នៃការរក្សាការពារ

..........................................................................................................................................

..........................................................................................................................................

..........................................................................។

អាស្រ័យហេតុនេះសូម **លោកប្រធាន** មេត្តាចេញដីកាការពារតាមការស្នើសុំដោយអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ធ្វើ.......ថ្ងៃទី ...... ខែ ..... ឆ្នាំ ២០១

**ហត្ថលេខា**

# ឧបសម្ព័ន្ធទី ៨ - ទម្រង់ពាក្យបណ្តឹងរបស់ជនរងគ្រោះ

ក្រសួង ក.ក.ន

បានទទួល
លេខ.......................
ថ្ងៃទី.......................
ម៉ោង...១០.....៣០.......
អ្នកទទួល.......................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ពាក្យបណ្តឹង**

នាងខ្ញុំឈ្មោះ ភេទស្រីអាយុ៣៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅភូមិ ឃុំ ស្រុក ខេត្ត ។ លេខទូរស័ព្ទ ។

សូមគោរពជូន
**លោកជំទាវរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី**

*សូមមេត្តាជ្រាប*

**កម្មវត្ថុ:** សំណើសុំឲ្យជួយអន្តរាគមន៍ទៅសាលាដំបូងខេត្ត សុំលែងលះជាមួយ លោក ភេទប្រុស អាយុ៣៨ឆ្នាំ មានទីលំនៅភូមិ ឃុំ ស្រុក ខេត្ត (បច្ចុប្បន្នឃុំខ្លួននៅមន្ទីរឃុំឃាំងខេត្ត ) បែងចែកទ្រព្យសម្បត្តិរួម សុំសិទ្ធិចិញ្ចឹមបីបាច់ថែរក្សាកូន ដោយសុំប្រាក់អាហារកាតព្វកិច្ចចំនួន ម៉ឺន ដុល្លាអាមេរិក( ដុល្លាអាមេរិក) និង សុំអនុវត្តដីកាសម្រេចរក្សាការពារ របស់សាលាដំបូងខេត្ត ចុះថ្ងៃទី ខែ ឆ្នាំ ២០១២ ។

**យោង:** -អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
-សៀវភៅគ្រួសារ
-សំបុត្រអាពាហ៍ពិពាហ៍(ឆ្នាំ២០០៥)
-រូបថត
-ពាក្យបណ្តឹងសុំលែងលះទៅសាលាដំបូងខេត្ត ចុះថ្ងៃទី ខែ ឆ្នាំ ២០១២ របស់ឈ្មោះ
-ដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី ខែ ឆ្នាំ២០១២ របស់សាលាដំបូងខេត្ត
-ឯកសារទ្រព្យសម្បត្តិ(ថតចម្លង)

តបតាមកម្មវត្ថុនិងយោងខាងលើ នាងខ្ញុំសូមគោរពជម្រាបជូន លោកជំទាវ រដ្ឋមន្ត្រី មេត្តាជ្រាបថា នាងខ្ញុំ និងលោក បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាំងពីឆ្នាំ ១៩៩៨ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ(ឆ្នាំ២០០៥) ហើយមានកូនចំនួន៣នាក់ កូនទី១ឈ្មោះ ភេទប្រុស អាយុ១៣ឆ្នាំ កូនទី២ឈ្មោះ ភេទស្រី អាយុ៩ និង កូនទី៣ឈ្មោះ ភេទប្រុស អាយុ៥ឆ្នាំ។ ការរស់នៅរបស់នាងខ្ញុំនិងស្វាមីមានភាពរកាំរកូសជាមួយគ្នាជាយូរមកហើយ មានជេរប្រមាថ វាយដំសឹងតែរាល់ថ្ងៃ រហូតមកដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២ គាត់បានវាយធ្វើបាបនាងខ្ញុំបណ្តាលឲ្យមានរបួសធ្ងន់ធ្ងរ រហូតចូលទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យវិសាលសុខ(រាជធានីភ្នំពេញ)រយៈពេល២ថ្ងៃ បន្ទាប់មកនាងខ្ញុំបាន

មកស្នាក់នៅផ្ទះម្ដាយជាង១ខែ ដោយសារនាងខ្ញុំមិនហ៊ានទៅផ្ទះវិញខ្លាចគាត់វាយធ្វើបាប ។ ក្រោយមកនាងខ្ញុំបានត្រឡប់មករស់នៅភូមិ ឃុំ ស្រុក ខេត្ត ហើយបានជួលផ្ទះដែលស្ថិតនៅជិតផ្ទះដែលនាងខ្ញុំរស់នៅជាមួយប្ដីអស់រយៈពេល៦ខែ ។ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣ នាងខ្ញុំបានឮអ្នកភូមិប្រាប់ថា ប្ដីនាងខ្ញុំបានរៀបចំសែនព្រេនជាមួយឈ្មោះ អាយុ២១ឆ្នាំ ដែលជាអ្នកបំរើរបស់នាងខ្ញុំ ហើយពួកគេបានរស់នៅលើផ្ទះនាងខ្ញុំរហូតមក ។ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ នាងខ្ញុំបានដាក់ពាក្យបណ្ដឹងទៅតុលាការខេត្ត

ស្នើសុំលែងលះជាមួយលោក ជាប្ដី ប៉ុន្តែរហូតមកដល់សព្វថ្ងៃតុលាការមិនទាន់បានដោះស្រាយករណីបណ្ដឹងរបស់នាងខ្ញុំនៅឡើយទេ។ ក្រោយមក ប្ដីនាងខ្ញុំមានរឿងរ៉ាវប៉ះពាល់ដល់អាជ្ញាធរសមត្ថកិច្ច ទើបមានការឃុំខ្លួនគាត់នៅមន្ទីរឃុំឃាំងខេត្ត ហើយគាត់បានជួលគេលក់ដីចំនួនបីកន្លែង គឺដីចំការដែលមានទំហំ ២០ម គុណនឹង ២៦ម នៅភូមិ ដីចំការដែលមានទំហំ ៥ម គុណនឹង ៤០ម នៅភូមិ និងដីចំការដែលមានទំហំ ១០,៥ម គុណនឹង ៥០ម នៅភូមិ ដែលភូមិទាំងបីនេះស្ថិតនៅឃុំ ស្រុក ខេត្ត ដីទាំងបីកន្លែងនេះជាទ្រព្យសម្បត្តិរួមដែលទិញក្នុងតម្លៃ ១០ម៉ឺន ៣ពាន់ដុល្លាអាមេរិក(១៣,០០០ ដុល្លាអាមេរិក) ដូច្នេះទើបនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១២ នាងខ្ញុំបានដាក់ពាក្យស្នើសុំដីកាសម្រេចរក្សាការពារទៅសាលាដំបូងខេត្ត ចំនួន ៤ចំណុចគឺ ៖

ចំណុចទី១៖ ហាមឃាត់ឈ្មោះ មិនឲ្យអោយលក់ដូរ ជួលបញ្ចាំ ធ្វើអំណោយ ឬផ្ទេរសិទ្ធិនូវផ្ទះលេខ១២៣ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត

ចំណុចទី២៖ សុំបើកសោរទ្វារផ្ទះ និងទ្វាររបងដើម្បីឲ្យដើមចោទ និងកូនៗបានរស់នៅធម្មតាវិញ

ចំណុចទី៣៖ សុំបែកលំនៅសង្វាសពីចុងចំលើយដោយឲ្យចុងចំលើយទៅរស់នៅលំនៅដ្ឋានផ្សេង

ចំណុចទី៤៖ សុំសិទ្ធិគ្រប់គ្រងកូន ៣នាក់ ។

ប៉ុន្តែតុលាការបានចេញសេចក្ដីសម្រេចចំនួន៣ចំណុចគឺ៖

ចំណុចទី១៖ ហាមឃាត់ឈ្មោះ ចុងចំលើយ និងជនដទៃទៀត មិនឲ្យលក់ដូរ ជួល បញ្ចាំ ធ្វើអំណោយ ឬផ្ទេរសិទ្ធិនូវផ្ទះលេខ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត ជាបណ្ដោះអាសន្ន ។

ចំណុចទី២៖ អនុញ្ញាតឲ្យឈ្មោះ ដើមចោទចូលទៅរស់នៅក្នុងផ្ទះស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត ជាធម្មតាដូចស្ថានភាពដើមវិញ ។

ចំណុចទី៣៖ លើកចោលការសុំឲ្យចុងចំលើយបែកលំនៅទៅរស់នៅទីផ្សេង ប៉ុន្តែចុងចំលើយត្រូវរក្សាសុវត្ថិភាព មិនឲ្យកើតមានទំនាស់ជាមួយប្រពន្ធ ។

នាងខ្ញុំពុំបានយល់ព្រមទៅលើចំណុចដែលតុលាការសម្រេចទាំងស្រុងឡើយ ហើយចំពោះការអនុវត្តដីកាសម្រេចរក្សាការពារនេះ ប្តីនាងខ្ញុំមិនបានធ្វើតាមចំណុចទាំងអស់នេះឡើយ ហើយបានជេរប្រមាថជៀលត្បិះនាងខ្ញុំដោយសំដីអសុរសសព្វបែបយ៉ាង និងជះទឹកបបរស្រោចលើខ្លួននាងខ្ញុំ កន្លងមកនាងខ្ញុំបានខិតខំប្រឹងប្រែងរកស៊ីចិញ្ចឹមកូនតែម្នាក់ឯងទាំងលំបាកវេទនា ដោយប្តីនាងខ្ញុំគិតតែពីដើរសប្បាយមានស្រីធ្វើបាបប្រពន្ធកូនគ្មានមេត្តា និងព្រហ្មវិហារធម៌បន្តិចឡើយ ។ នាងខ្ញុំបានសន្សំដៃព្រាក់កាស ខំលក់ដូរទាំងយប់ទាំងថ្ងៃទើបបាននៅសល់ទ្រព្យសម្បត្តិមួយចំនួន ហើយនាងខ្ញុំបារម្ភខ្លាចក្រែងប្តីនាងខ្ញុំចេញពីមន្ទីរឃុំឃាំងវិញគាត់នឹងត្រឡប់មកផ្ទះហើយធ្វើបាបនាងខ្ញុំនិងកូន និងលក់ទ្រព្យសម្បត្តិយកទៅចិញ្ចឹមស្រីអស់ ទើបនាងខ្ញុំ សូមលោកជំទាវ រដ្ឋមន្ត្រី មេត្តាជួយអន្តរាគមន៍ទៅតុលាការខេត្ត ឲ្យអនុវត្តទៅតាមនីតិវិធីច្បាប់ កុំពន្យាពេលតទៅទៀតលើករណីប្តឹងសុំលែងលះប្តីប្រពន្ធ បែងចែកទ្រព្យសម្បត្តិរួម សុំសិទ្ធិចិញ្ចឹមបីបាច់ថែរក្សាកូនទាំង៣នាក់ដោយសុំអាហារកាតព្វកិច្ចចំនួន ម៉ឺនដុល្លាអាមេរិច( , ដុល្លាអាមេរិច) និងសុំឲ្យអនុវត្តដីកាសម្រេច រក្សាការពាររបស់សាលាដំបូងខេត្ត ចុះថ្ងៃទី ខែ ឆ្នាំ២០១២ ។

ចំណែកទ្រព្យសម្បត្តិដែលនាងខ្ញុំមាន នាងខ្ញុំសូមជម្រាបជូនដូចខាងក្រោមនេះ និងសូមឲ្យតុលាការមេត្តាផ្តល់យុត្តិធម៌ក្នុងការបែងចែកឲ្យនាងខ្ញុំនិងកូនស្របទៅតាមច្បាប់ ។

នាងខ្ញុំមានទ្រព្យសម្បត្តិរួមដូចខាងក្រោមនេះ ៖

១/ ដីនៅឃុំ . ស្រុក ខេត្ត ៖

-ដីភូមិដែលមានទំហំបណ្តោយ ៣០ម ទទឹង ៦ម និងមានផ្ទះថ្មពីរជាន់ទំហំ បណ្តោយ ២៥ម ទទឹង៥ម ទីតាំងនៅភូមិ ។

-ដីតូបសម្រាប់លក់សាច់ជ្រូក មានទំហំបណ្តោយ៣,៥មទទឹង ១,៥ម ទីតាំងនៅភូមិ

-ដីភូមិទំហំ ៥០ម គុណនឹង ៧០ម ទីតាំងនៅភូមិ ។

-ដីភូមិនិងផ្ទះ ដែលមានទំហំ ១៧ម ទទឹង ៥,៥ម ទីតាំងនៅភូមិ ។

-ដីភូមិដែលមានទំហំ ៤,៥ម គុណនឹង ២៥ម ទីតាំងនៅភូមិ

-ដីស្រែប្រាំងទំហំ ២ហិចតា៦កុង(២៦០អា) ទីតាំងនៅភូមិ ។

-ដីទំហំ ១ហិចតា ៤កុង(១៤០អា) ទីតាំងនៅភូមិ ។

-ដីទំហំ ៥០អា ទីតាំងនៅភូមិ

-ដីស្រែទំហំ ២ហិចតា ទីតាំងនៅភូមិ

២/នៅឃុំ ស្រុក . ខេត្ត ៖

-ដីភូមិនិងផ្ទះដែលមានទំហំបណ្តោយ៣១មទទឹង៥ម ទីតាំងនៅភូមិ ។

៣/ឃុំ ស្រុក ខេត្ត ៖

-ដីស្រែប្រាំង ដែលមានទំហំ ១៥កុង(១ហិចតាកន្លះ) ទីតាំងនៅភូមិ

៤/ឃុំ ស្រុក ខេត្ត ៖

-ដីចំការ ដែលមានទំហំ ២០ម គុណនឹង ២៦ម ទីតាំងភូមិ ។ លោក បានលក់នៅថ្ងៃទី ខែ ឆ្នាំ ២០១៣ ។

-ដីចំការ ទំហំ ៥ម គុណនឹង ៤០ម ទីតាំងនៅភូមិក្តីកណ្តាល។ លោក បានលក់នៅថ្ងៃទី ខែ ឆ្នាំ២០១៣ ។

-ដីចំការ ទំហំ ១០,៥ម គុណនឹង ៥០ម ទីតាំងនៅភូមិ ។ លោក បានលក់នៅថ្ងៃទី ខែ ឆ្នាំ ២០១៣ ។

៥/ឃុំ ស្រុក ខេត្ត ៖

-ដីស្រែប្រាំង ដែលមានទំហំ ៤០អា ទីតាំងភូមិ ។

-ដីស្រែប្រាំង ដែលមានទំហំ ១១កុង(១ហិចតា១០អា) ទីតាំងភូមិ ។

-ដីស្រែទំហំ ៤០អា ទីតាំងនៅភូមិ

៦/ឃុំព្រះស្តេច ស្រុក ព្រះស្តេច ខេត្តព្រៃវែង

-ដីស្រែប្រាំង ដែលមានទំហំ ៦កុង(៦០អា) ទីតាំងភូមិ

៧/ឃុំ ស្រុក ខេត្ត ៖

-ដីស្រែប្រាំង ដែលមានទំហំ ៣ហិចតា ទីតាំងនៅភូមិ

-ដីស្រែប្រាំង ទំហំ ៣ហិចតា ទីតាំងនៅភូមិ

៨/ឃុំ ស្រុក ខេត្ត ៖

-ដីទំហំ ៣០ម គុណនឹង ៤០ម (ជាដីព្រាំង) ទីតាំងនៅភូមិ

៩/បញ្ជីឈ្មោះអ្នកដែលបានសងមាសទៅលោក ។

១០/រថយន្តម៉ាក Lexus Rx 300 ស្លាកលេខ ភ្នំពេញ

១១/ម៉ូតូម៉ាក Honda Dream 125 ស្លាកលេខ ភ្នំពេញ

១២/ជំពាក់បំណុលលោកស្រី ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ចំនួន ម៉ឺន ដុល្លាអាមេរិច ( . ដុល្លាអាមេរិច) ។

អាស្រ័យហេតុនេះ នាងខ្ញុំសូម លោកជំទាវ រដ្ឋមន្ត្រី មេត្តាជួយអន្តរាគមន៍តាមសំណើរបស់នាងខ្ញុំ ដោយក្តីអនុគ្រោះ ។

សូម លោកជំទាវ រដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១៣

ស្នាមមេដៃស្តាំ



# ឧបសម្ព័ន្ធទី ៩ - ទម្រង់លិខិតអន្តរាគមន៍ របស់លោកជំទាវរដ្ឋមន្ត្រី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី

លេខ..................ក.ន.ន

**សូមជម្រាបជូន**
**លោកប្រធាន សាលាដំបូងខេត្ត**

**កម្មវត្ថុ** : សំណើសុំជួយដោះស្រាយលើករណីរឿងក្ដីរបស់លោកស្រី ទៅលើចំណុចដូចខាងក្រោម ៖
១/ សុំលែងលះប្ដីឈ្មោះ
២/ សុំសិទ្ធិគ្រប់គ្រងកូនទាំងបីនាក់
៣/ សុំទាមទារប្រាក់អាហារកាតព្វកិច្ចចំនួន . ( ម៉ឺន) ដុល្លារអាមេរិច
៤/ សុំបែងចែកទ្រព្យសម្បត្តិរួមជា២ចំណែកស្មើគ្នា ។

**យោង** : - លិខិតពាក្យបណ្ដឹងលេខ កកន ចុះថ្ងៃទី ខែ ឆ្នាំ២០១៣ របស់ លោកស្រី

- ឯកសារពាក់ព័ន្ធមួយចំនួន ។

សេចក្ដីដូចបានជម្រាបជូនក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំ សូមជម្រាប លោកប្រធាន សាលាដំបូងខេត្ត ជ្រាបថា ក្រសួងកិច្ចការនារីបានទទួលពាក្យបណ្ដឹងរបស់លោកស្រី អាយុ៣៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅភូមិ ឃុំ ស្រុក ខេត្ត ប្ដីឈ្មោះ អាយុ៣៨ឆ្នាំ(បច្ចុប្បន្នឃុំខ្លួននៅមន្ទីរឃុំឃាំងខេត្ត ) ស្នើសុំឲ្យជួយអន្តរាគមន៍មកសាលាដំបូងខេត្ត សុំជួយដោះស្រាយករណីបណ្ដឹងរបស់លោកស្រីពាក់ព័ន្ធនឹងចំណុចខាងលើ ព្រោះលោកស្រីព្រួយបារម្ភខ្លាចក្រែងប្ដីរបស់លោកស្រីជួលគេឲ្យលក់ដី និងទ្រព្យសម្បត្តិមួយចំនួន ដែលជាទ្រព្យរួមយកទៅចំណាយផ្ទាល់ខ្លួនអស់ ដោយសារឯកសារទ្រព្យសម្បត្តិទាំងអស់នោះ នៅលើម្ដាយបង្កើតរបស់ប្ដីគាត់ ។ ម្យ៉ាងទៀត បច្ចុប្បន្នលោកស្រី មានជីវភាពក្រីក្រលំបាកហើយត្រូវចិញ្ចឹមកូនទាំងបីនាក់ម្នាក់ឯង និងត្រូវការចាំបាច់នូវប្រាក់កាសមួយចំនួន ដើម្បីយកទៅសងបំណុលដែលជំពាក់គេកាលនៅរួមរស់ជាមួយប្ដីឲ្យទាន់ពេលវេលា បើមិនដូច្នោះទេ នឹងត្រូវបាត់បង់ទាំងប្រាក់កក់ និងទ្រព្យសម្បត្តិដើមផងដែរ ។ ក្រសួងកិច្ចការនារី បានតាមដានរឿងនេះឃើញថា លោកស្រី ទទួលរងនូវអំពើហិង្សាផ្លូវចិត្ត និងផ្លូវកាយជាយូរឆ្នាំមកហើយ គ្មានសង្ឃឹមថានឹងអាចរួបរួមគ្នាជាមួយប្ដីឡើងវិញបានឡើយ ទើបស្នើសុំ លោកប្រធាន សាលាដំបូងខេត្ត ជួយដោះស្រាយករណីរឿងក្ដី

អាគារលេខ ៣ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន (ភ្នំពេញ)
ទូរស័ព្ទ/ទូរសារ : (០២៣) [illegible]
ទូរស័ព្ទ : (០២៣) [illegible]

របស់លោកស្រី ដោយផ្តោតទៅលើកំរិតរស់នៅរបស់លោកស្រី និងផលប្រយោជន៍របស់កូនទាំងបីនាក់ ដោយក្តីអនុគ្រោះ ។

អាស្រ័យហេតុនេះ សូម លោកប្រធាន សាលាដំបូងខេត្ត ជួយជំនុំជម្រះរឿងក្តីនេះឲ្យបានឆាប់ តាមការគួរ ។

សូម លោកប្រធាន ទទួលនូវការគោរពអំពីខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១៣

រដ្ឋមន្ត្រី

**ក្រសួងកិច្ចការនារី**

ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ ៣
សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Tel/Fax: + 855 23 88 07 37
Email:mwa@online.com.khwww.mowa.gov.kh
www.facebook.com/mowa.gov.kh